ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការចាប់ខ្លួន អៀង សារី និង អៀង ធីរិទ្ធ គឺជាជ័យជម្នះមួយសម្រាប់ប្រជាជនកម្ពុជា
- ការស្លាប់ដោយការអត់អាហារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

អៀង សារី ថតដោយ ស៊ាំង ឃុ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩៥ ខែវិច្ឆិកា ឆ្នាំ២០០៧

# ស្វែងរកការពិត

លេខ៩៥ ខែវិច្ឆិកា ឆ្នាំ២០០៧

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ : ការចាប់ខ្លួន អៀង សារី និង អៀង ធីរិទ្ធ ..........................១
◆ យុត្តិធម៌និងអំពើពុករលួយនៅតុលាការខ្មែរក្រហម ..............................៣
ផ្នែកឯកសារ
◆ មរតកដែលទទួលបានពីរបបកម្ពុជាប្រជាធិបតេយ្យ .............................៥
ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ
◆ គុកខ្មែរក្រហម ........................................................................១០
◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ...........................................១៦
◆ តម្លៃនៃការនិយាយពីជម្លោះអតីតកាល ........................................២៣
ផ្នែកច្បាប់
◆ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា .........៣០
◆ សេចក្ដីប្រកាសព័ត៌មាន ........................................................៤៣
◆ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ..........................................៤៣
វេទិកាពិភាក្សាសាធារណៈ
◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ....................................៥៣
ទំព័រស្រាវជ្រាវរកគ្រួសារ
◆ បទពិសោធន៍របស់ ស្រេង ធា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ...៥៩





**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ចន ឆរឆីអារី, ដេវ ពង្សវ៉ាស៊ី, ឌី ខាំបូលី, ដ៊ីទីល ក្រូឌឹម, ដេហ្វ ក៉ាឡេនហ្សីរឡា, អែន ហៃនដែល, អេតែល ហ៊ីហ្កូនេត, ធា សីនឌី, **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ ៖** ព្រុំ ដល្លា និង ជា ដល្លា **និពន្ធនាយករង ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុដល **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន តារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# ការចាប់ខ្លួន អៀង សារី និង អៀង ធីរិទ្ធ គឺជាជ័យជម្នះមួយសម្រាប់ប្រជាជនកម្ពុជា

ប្រជាជនកម្ពុជាតែងតែនិយាយដល់របបកម្ពុជាប្រជាធិបតេយ្យដែលទទួលខុសត្រូវក្នុងការស្លាប់បាត់បង់ជីវិតមនុស្សអស់ជិតមួយភាគបួននៃប្រជាជនខ្មែរនៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ថាជាការទទួលខុសត្រូវរបស់ «បន ប៉ុល ពត និង អៀង សារី» ។ មានមនុស្សមួយចំនួនតូចបានស្គាល់អំពីអត្តសញ្ញាណរបស់មេដឹកនាំសម្ងាត់របស់របបកម្ពុជាប្រជាធិបតេយ្យនៅក្រោយពេលដែលរបបនេះដុតរលត់ទៅ តែអ្នកទាំងនោះស្គាល់ អៀង សារី នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ។ ដោយឈ្មោះគាត់នៅបន្ទាប់ពី ប៉ុល ពត (អ្នកទាំងពីរជាបងប្អូនថ្លៃ) ប្រជាជនកម្ពុជាស្គាល់ អៀង សារី យ៉ាងច្បាស់ថា ជាមេដឹកនាំម្នាក់ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។

អៀង សារី ក្លាយជាជនកុម្មុយនីស្តក្លៀវក្លា នៅខណៈពេលដែល ប៉ុល ពត កំពុងរៀននៅទីក្រុងប៉ារីសនៅទសវត្សរ៍ឆ្នាំ១៩៥០ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី មានតួនាទីជាឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីការបរទេស ។ បន្ទាប់ពីបានរត់គេចខ្លួនទៅតំបន់ខ្មែរក្រហមនៅក្រុងប៉ៃលិនដែលសម្បូរដោយធនធានធម្មជាតិដូចជាត្បូង និងព្រៃឈើ នៅក្បែរព្រំដែនថៃក្នុងឆ្នាំ១៩៧៩ អៀង សារី នៅតែមានតួនាទីខ្ពស់ក្នុងចលនាខ្មែរក្រហមរហូតដល់ឆ្នាំ១៩៨២ ទោះបីជាគាត់ត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏ដោយ ។ នៅឆ្នាំ១៩៩៦ អៀង សារី ទទួលបាននូវការលើកលែងទោសពីព្រះបាទនរោត្តម សីហនុ ទៅតាមសំណើរបស់សហនាយករដ្ឋមន្ត្រី ហ៊ុន សែន និង ព្រះអង្គម្ចាស់រណឫទ្ធិ ដើម្បីជាថ្នូរនឹងការចុះចូលជាមួយរដ្ឋាភិបាលដើម្បីទទួលបាននូវសន្តិភាពនិងការផ្សះផ្សាជាតិ ។



អៀង សារី

ភរិយារបស់ អៀង សារី មានឈ្មោះថា អៀង ធីរិទ្ធ ជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីមួយចំនួនតូចដែលបានកាន់អំណាចនៅក្នុងរបបនេះ ។ អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីសង្គមកិច្ចនិងអប់រំ ហើយក៏ជាប្រធានកាកបាទក្រហមនៅក្នុងរបបនេះដែរ ។ គាត់គឺជាស្ត្រីមានសមត្ថភាពម្នាក់ចេញមកពីគ្រួសារស្តុកស្តម្ភ ហើយបានជួប អៀង សារី នៅពេលដែលគាត់កំពុងសិក្សាពីល្ខោនសេកស្ពៀរនៅសកលវិទ្យាល័យស័របោន ប្រទេសបារាំង ។ អៀង ធីរិទ្ធ បានបដិសេធការទទួលស្គាល់ថាគាត់ជាសមាជិកគណៈមជ្ឈិម ដោយបាននិយាយថា គាត់គ្រាន់តែចង់បម្រើប្រទេសជាតិនិងប្រជាជន ហើយមិនដែលចង់បាន «មុខនាទីខ្ពស់» ឡើយ ។ អៀង ធីរិទ្ធ ក៏បានអះអាងផងដែរថា បើពុំមានការពេញចិត្តពីសំណាក់អ្នកដែលបានចូលរួមក្នុងចលនាបដិវត្តន៍នោះ ប្រទេសកម្ពុជាប្រហែលជាបាត់បង់ពីផែនទីពិភពលោកនេះទៅហើយ ។



អៀង ធីរិទ្ធ

អ្នកទាំងពីរនេះបានបដិសេធដូចជនដៃដល់ជាច្រើនទៀតចំពោះការប្រព្រឹត្តខុស ហើយហាក់ដូចជាពុំមានការសោកស្តាយ ឬវិប្បដិសារីបន្តិចសោះឡើយ ។ នៅឆ្នាំ១៩៩៩ អៀង ធីរិទ្ធ បានសរសេរទៅកាសែតក្នុងស្រុកដោយលើកសរសើរអ្នកទាំងឡាយណាដែលបានចេញពីផ្ទះដ៏ស្កឹមស្កៃរបស់ខ្លួនទៅរស់នៅក្នុងព្រៃនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ដើម្បីការពារមាតុប្រទេស ។ អៀង ធីរិទ្ធ មិនដែលទទួលយកឥទ្ធិពលពីបដិវត្តន៍ ម៉ៅ ដែលកសិករគួរតែជាអ្នកគ្រប់គ្រងប្រទេសនោះទេ ។

ប៉ុន្តែប្តីប្រពន្ធនេះ ដែលឋិតក្នុងវ័យ៧០ មិនធ្វើតាមឧត្តមគតិរបស់ខ្លួនទេ ផ្ទុយទៅវិញអ្នកទាំងពីរបានរើសយកការរស់នៅទាន់សម័យរបស់អ្នកដែលខ្លួនបានកោតសរសើរខាងលើនេះទៅវិញ ។ អ្នកទាំងពីរមានផ្ទះវីឡាមានតម្លៃមួយខ្នងនៅទីក្រុងភ្នំពេញ ហើយតែងតែទៅពិនិត្យសុខភាពនៅទីក្រុងបាងកក ប្រទេសថៃ ។ អ្នកទាំងពីរឥឡូវនេះជាអ្នកគោរពព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ហើយបានកសាងចេតិយមួយនៅវត្តជិតផ្ទះ ។ អ្នកទាំងពីរហាក់ដូចជាភ្លេចថាបក្សកុម្មុយនីស្តកម្ពុជាបានលុបបំបាត់ព្រះពុទ្ធសាសនា ដោយចាត់ទុកថាជាសាសនា «ប្រតិកិរិយា» ដូចសាសនាផ្សេងទៀតដែរ ។

ប្រជាជនកម្ពុជាឆាប់មានប្រតិកម្មចំពោះអ្នកទាំងពីរដោយនិយាយថា ប្តីប្រពន្ធនេះឋិតនៅក្នុងចំណោមអ្នកបង្កើត «វាលពិឃាត»នៅប្រទេសកម្ពុជា អ្នកទាំងពីរបម្រើបដិវត្តន៍ដើម្បីយកតែឈ្មោះប៉ុណ្ណោះ ។ អ្នកទាំងពីរមានជីវិតសុខស្រួលនិងមានឯកសិទ្ធិ តែប្រជាជនកម្ពុជាភាគច្រើននៅតែរកចំណូលបានតិចជាងមួយដុល្លាក្នុងមួយថ្ងៃ ។ អ្នកក្រីក្រ ដែលឈ្មោះនេះបង្កើតឡើងដោយបដិវត្តន៍ ហើយឥឡូវនេះប្រហែលជាក្រជាងពេលមុននិងនៅតែគ្មានអំណាចនោះ គឺដោយសារអ្នកទាំងពីរនេះឯង ។ ខ្មែរក្រហមបានបន្សល់ឲ្យយើងនូវសោកនាដកម្មធ្ងន់ធ្ងរមួយនៅឆ្នាំ១៩៧៩ ដោយសារតែប្រព័ន្ធអប់រំ សាសនា ធនាគារ ជំនួញ ទូរគមនាគមន៍ និងកសិកម្មត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ។ ប្រជាជនរស់រានជីវិតប្រហែលជា៧៥ភាគរយ ជាស្ត្រីមេម៉ាយដែលចាប់ផ្តើមកសាងជីវិតរបស់ខ្លួនឡើងវិញដោយដៃទទេ ។

អៀង សារី, អៀង ធីរិទ្ធ, ប៉ុល ពត, នួន ជា, ខៀវ សំផន និងអ្នកផ្សេងទៀតបានធ្វើឲ្យប្រជាជនកម្ពុជាទាំងអស់ (លើកលែងតែក្រុមគ្រួសាររបស់ខ្លួន) ក្លាយជាកសិករនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនទាំងអស់ត្រូវបានបង្ខំឲ្យធ្វើស្រែនិងកសាងប្រព័ន្ធធារាសាស្ត្រ តែផ្ទុយទៅវិញប្រជាជនជាច្រើនស្លាប់ដោយអត់អាហារ ឬក៏ស្លាប់ដោយធ្វើការហួសកម្លាំង ឬដោយជំងឺ ។ អៀង ធីរិទ្ធ បានចុះទៅមូលដ្ឋានជាច្រើនដងដើម្បីត្រួតពិនិត្យគម្រោងកសាងប្រព័ន្ធទឹកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយពិតជាបានឃើញពីលទ្ធផលរបស់នយោបាយក្នុងរបបនោះ ។ បដិវត្តន៍អាចនឹងបាត់បង់ទៅ ប៉ុន្តែផលប៉ះពាល់នៅតែមានជាមួយយើងមកដល់សព្វថ្ងៃនេះ ។

ការចាប់ខ្លួន អៀង សារី និង អៀង ធីរិទ្ធ នៅថ្ងៃទី១២ ខែវិច្ឆិកា ជាទីបញ្ចប់នេះនឹងផ្តល់នូវជ័យជម្នះដល់ប្រជាជនកម្ពុជា ។ ប្តីប្រពន្ធនេះមានការផ្លាស់ប្តូរបន្តិចបន្តួច ហើយដែលនៅតែមិនយល់ពីការឈឺចាប់របស់ជនរងគ្រោះ នឹងត្រូវនាំយកមកទទួលខុសត្រូវរឿងនេះ ហើយយើងទាំងអស់គ្នានឹងឃើញយុត្តិធម៌កើតមានឡើងនៅក្នុងតុលាការច្បាប់ ។ ការចាប់ខ្លួនមេដឹកនាំខ្មែរក្រហមដែលមិនអាចប៉ះពាល់បាន ដោយមូលហេតុនយោបាយ គឺជាសារមួយដ៏មានឥទ្ធិពលសម្រាប់ប្រជាជនកម្ពុជា ហើយនឹងផ្តល់ឲ្យយើងនូវក្តីសង្ឃឹមថាប្រទេសយើងនឹងធ្វើដំណើរឆ្ពោះទៅរកអនាគតល្អប្រសើរ ។ **ឆាំង យុ**



អៀង សារី និង អៀង ធីរិទ្ធ

# យុត្តិធម៌ និង អំពើពុករលួយនៅតុលាការខ្មែរក្រហម

យុត្តិធម៌នៅប្រទេសកម្ពុជាឋិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ម្តងទៀត បន្ទាប់ពីការផ្សព្វផ្សាយពេលថ្មីៗនេះអំពីការត្រួតពិនិត្យយ៉ាងល្អិតល្អន់ទៅលើរឿងរ៉ាវកើតឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការត្រួតពិនិត្យធ្វើឡើងដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិដែលផ្តល់ថវិកា ៦,៤លានដុល្លារអាមេរិកសម្រាប់តុលាការ បានចោទប្រកាន់ពីការរើសបុគ្គលិកមិនសមស្របនៅអង្គជំនុំជម្រះវិសាមញ្ញ ការបង្កើនប្រាក់បៀវត្សរ៍ដោយមិនសមហេតុផល និងការគ្រប់គ្រងមិនល្អកើតមាននៅអង្គជំនុំជម្រះវិសាមញ្ញ ។ ការសន្និដ្ឋានរបស់អ្នកត្រួតពិនិត្យធ្វើឡើងដោយមិនហ្មត់ចត់ៈ ប្រសិនបើតុលាការនេះមិនធ្វើការកែទម្រង់ឲ្យបានត្រឹមត្រូវ កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិនឹងពិចារណាលើការដកខ្លួនចេញ ។ មន្ត្រីកម្ពុជាទទួលស្គាល់កំហុស ប៉ុន្តែអះអាងថា កំហុសទាំងនោះមិនធ្វើឲ្យប៉ះពាល់ដល់ដំណើរការតុលាការទាំងមូលនោះទេ ។ បន្ទាប់ពីការចរចាមួយទស្សវត្សរ៍ពោរពេញដោយការលំបាក មន្ត្រីអន្តរជាតិក៏មិនគិតគូរខ្វាំងអំពីការត្រឡប់ទៅកិច្ចចរចា ដូចនេះវាពន្យារពេលដល់ការរកយុត្តិធម៌ ។

នៅអំឡុងពេលចរចាអំពីតុលាការនេះ ខ្ញុំនិងបុគ្គលផ្សេងទៀតបានអះអាងថាសហគមន៍អន្តរជាតិមិនគួរគិតទៅដល់ភាពល្អឥតខ្ចោះដែលអាចបាត់បង់រឿងល្អនោះទេ ។ តុលាការចម្រុះមួយនឹងមានការលំបាកគ្រប់គ្រង ហើយចៀសមិនផុតពីមានភាពតានតឹង និងការប៉ះទង្គិចគ្នាដោយថាហេតុរវាងមន្ត្រីអង្គការសហប្រជាជាតិនិងមន្ត្រីក្នុងស្រុក ។ មន្ត្រីអង្គការសហប្រជាជាតិខ្វះខាតចំណេះដឹងលម្អិត និងភាសារបស់កម្ពុជា ចំណែកឯមន្ត្រីក្នុងស្រុកវិញខ្វះចំណេះដឹងខាងច្បាប់អន្តរជាតិ ។ វាក៏មានការលំបាកផងដែរក្នុងការភ្ជាប់ច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ និងនិតិវិធីច្បាប់កម្ពុជានិងនិតិវិធីច្បាប់អន្តរជាតិ ។ សង្ខេបមក តុលាការចម្រុះវានឹងមិនអនុវត្តតាមច្បាប់ «យ៉ាងខ្ជាប់ខ្ជួន» ឬក៏មានប្រសិទ្ធភាពដូចតុលាការអន្តរជាតិនៅទីក្រុងឡាអេនោះទេ ប៉ុន្តែវាជាការថ្លឹងថ្លែងមួយក្នុងការគិតទៅដល់វិធីផ្សេងៗដើម្បីសម្រេចគោលបំណងយុត្តិធម៌ ការផ្សះផ្សានិងការអភិវឌ្ឍន៍ ។

ពិនិត្យលើទិដ្ឋភាពជារួមអង្គជំនុំជម្រះបន្តកិច្ចការរបស់ខ្លួនខ្ជាប់ខ្ជួនដើម្បីនាំយកចុងចោទសំខាន់ៗមកកាន់សវនាការ ។ ដូចដែលបានរំពឹងទុកប្រការនេះធ្វើមិនឲ្យមានការឈប់ចាប់កើនឡើងថែមទៀត ។ សំខាន់ជាងនេះទៅទៀតនោះ ភាគច្រើនរឿងរ៉ាវទាំងនេះមិនមែនជាឧបសគ្គដល់សុចរិតភាពជាមូលដ្ឋានរបស់ដំណើរការនេះឡើយ ។ ឧទាហរណ៍ ការចេញបញ្ជារបស់តុលាការឲ្យឃុំខ្លួន ឌុច និង នួន ជា បង្កប់ន័យមិនច្បាស់លាស់មួយផ្នែកផ្អែកលើការអនុវត្តន៍គោលការណ៍ប្រព័ន្ធច្បាប់ខុសគ្នា ។ ភាសាបីប្រើប្រាស់ជាផ្លូវការសព្វថ្ងៃគឺភាសាខ្មែរ អង់គ្លេស និងបារាំង ដោយថាហេតុគេចមិនផុតពីកំហុសនិងអសមត្ថភាពក្នុងការបកប្រែ ។ ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះមិនទាន់បានបង្កើតយន្តការគ្រប់គ្រាន់ក្នុងការចែកផ្សាយឯកសារដល់មន្ត្រីតុលាការដែលពាក់ព័ន្ធ ។ ក្នុងពេលជាមួយគ្នានេះ ការតែងតាំងចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេងជាប្រធានសាលាឧទ្ធរណ៍ធ្វើឲ្យមានបញ្ហាលើកឡើងទាក់ទងនឹងទំនាស់ផលប្រយោជន៍ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏រឿងរ៉ាវបែបនេះវានឹងមិនធ្វើឲ្យប៉ះពាល់ដល់ដំណើរការចាប់ផ្តើមតុលាការថ្មីមួយនេះដែរ ។

អំពើពុករលួយជារឿងផ្សេងពីនេះ ។ ការប្រើប្រាស់ថវិកាខុស ការផ្តល់សំណូក និងការប្រើប្រាស់ខ្សែបណ្តាញដើម្បីចូលធ្វើការទាំងអស់នេះមិនមែនជាប្រភេទ «មិនគ្រប់លក្ខណៈ» ដែលសហគមន៍អន្តរជាតិ និងសាធារណជនកម្ពុជាទូទៅគួរតែគិតថារឿងនេះមិនមែនជាដំណើរការលំបាកក្នុងការគ្រប់គ្រងដំណើរការតុលាការចម្រុះ និងដំណើរការព្រហ្មទណ្ឌមានសភាពស្មុគស្មាញ ។ ប្រសិនបើការចោទរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ជាការពិតនោះ មន្ត្រីខ្លះបានរំលោភអំណាចរបស់ខ្លួន ។ រដ្ឋាភិបាលកម្ពុជានិងសហគមន៍ដែលជាអ្នកផ្តល់ជំនួយ គួរតែបញ្ចុះបញ្ចូលជាបន្ទាន់គណៈកម្មាធិការពិសេសមួយឬស្ថាប័នស្រដៀងគ្នានេះដើម្បីស៊ើបអង្កេតការចោទប្រកាន់នេះបន្ថែមទៀត ។ អំពើពុករលួយនឹងធ្វើឲ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់សមត្ថភាពរបស់តុលាការក្នុងការធ្វើជាគំរូដល់នីតិរដ្ឋក្នុងប្រទេសកម្ពុជា ហើយក៏ជាការប្រមាថធ្ងន់ធ្ងរ មួយដល់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យដែលបានរង់ចាំយុត្តិធម៌អស់រយៈពេលបីទសវត្សរ៍មក

ហើយ ។ ពុករលួយបន្តឡើងដោយមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញដែលខ្លួនឯងផ្ទាល់ក៏ជាអ្នករស់រានជីវិតពីរបបខ្មែរក្រហមដែរនោះ វានឹងជាការក្បត់គួរឲ្យឈឺចាប់មួយ ។

ការបញ្ចប់អំពើពុករលួយក្នុងប្រព័ន្ធតុលាការ គឺជាគោលបំណងមួយដែលអង្គជំនុំជម្រះវិសាមញ្ញគួរតែស្វះស្វែងដើម្បីសម្រេចគោលបំណងនេះ ។ អំពើពុករលួយកើតឡើងជាសាមញ្ញក្នុងសង្គមកម្ពុជា ហើយមានការចូលរួមពីមនុស្សក្នុងស្រុកនិងអន្តរជាតិ ហើយក្លាយជាផលប៉ះពាល់រាលដាលដល់អភិបាលកិច្ចនិងការរីកលូតលាស់របស់ប្រទេសទៀតផង ។ អង្គការតម្លាភាពអន្តរជាតិក្នុងពេលថ្មីៗនេះបានចាត់ទុកប្រទេសកម្ពុជាក្នុងចំណាត់ថ្នាក់ទី១៦២ ក្នុងចំណោមប្រទេសទាំង១៧៩ដែលមានអំពើពុករលួយច្រើនបំផុតនៅលើពិភពលោក ។ ក្នុងដំណើរទស្សនកិច្ចនៅប្រទេសកម្ពុជាក្នុងពេលថ្មីៗនេះរបស់ប្រធានធនាគារពិភពលោក លោក រ៉ូប៊ែត ហ្ស៊ូលីក បានសង្កត់ធ្ងន់លើអំពើពុករលួយនេះដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់គម្រោងអភិវឌ្ឍន៍ជាច្រើនក្នុងប្រទេសនេះ ។ អំពើពុករលួយបន្ថយការជឿទុកចិត្តលើកិច្ចសន្យា និងសិទ្ធិលើទ្រព្យសម្បត្តិបន្ថយការវិនិយោគបរទេសស្របច្បាប់និងបង្អាក់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ហើយក៏ធ្វើឲ្យមានភាពអយុត្តិធម៌កើតមានឥតឈប់ឈរនៅថ្នាក់មូលដ្ឋានដែរ ។ អង្គការឃ្លាំមើលពិភពលោកបានចេញរបាយការណ៍ស្តីពីអំពើពុករលួយក្នុងការប្រមូលយកធនធានខស្សាហកម្មដោយបានផ្តល់ភ័ស្តុតាងចំពោះការរំលោភធ្វើឡើងចំពោះសហគមន៍ ប្រជាជនកម្ពុជា ជនបទ និងបរិស្ថាន ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត អំពើពុករលួយនឹងធ្វើឲ្យបាត់បង់ចំណូលដល់ប្រជាជនកម្ពុជាសាមញ្ញចំពោះការរកឃើញប្រេងកាតនៅក្នុងប្រទេសកម្ពុជាក្នុងពេលថ្មីៗនេះ ។

អំពើពុករលួយមិនត្រូវបានធ្វើឲ្យខូចខាតដល់តុលាការខ្មែរក្រហម ឬក៏ការអភិវឌ្ឍន៍ប្រទេសកម្ពុជាក្នុងពេលអនាគតទេ ។ ជាការពិតណាស់ដែលថារាជរដ្ឋាភិបាលកម្ពុជាដើរតួនាទីសំខាន់ក្នុងការលុបបំបាត់ ។ តុលាការខ្មែរក្រហមផ្តល់ឱកាសមួយក្នុងការបង្ហាញការធ្វើឲ្យប្រសើរឡើងរបស់រដ្ឋាភិបាលកម្ពុជាលើអភិបាលកិច្ចនិងប្រព័ន្ធច្បាប់ដែលនឹងទទួលបានកិត្តិនាមនិងការវិនិយោគជាច្រើនទៀត ។ ភាពទន់ខ្សោយ និងបរាជ័យនៃដំណើរការអង្គជំនុំជម្រះវិសាមញ្ញនឹងនាំមកនូវការបាត់បង់កេរ្តិ៍ឈ្មោះនិងបំផ្លាញជំហររបស់ប្រទេសនៅក្នុងតំបន់និងការគ្រប់គ្រងស្របច្បាប់ជាសាធារណៈ ។

អ្នកផ្តល់ជំនួយសំខាន់ៗដល់តុលាការនេះ ក៏ចាំបាច់ចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះដែរ ដែលគួរតែបង្កើតការងារហើយបន្តធ្វើការដោយមិនយោគយល់ក្នុងការចោទប្រកាន់អំពើពុករលួយនេះ បើទោះបីជាទង្វើនេះបន្តឡើងដោយបុគ្គលិកកម្ពុជា ឬបុគ្គលិកអន្តរជាតិក៏ដោយ ។ បន្ថែមលើការបង្កើតគណៈកម្មាធិការចម្រុះដើម្បីត្រួតពិនិត្យលើការចោទពីបទប្រព្រឹត្តអំពើអាក្រក់បែបនេះ អ្នកផ្តល់ជំនួយគួរតែទទូចឲ្យមានការកែតម្រូវជាបន្ទាន់ចំពោះការទទួលខុសទាំងឡាយដែលកើតមាន ។ លើសពីនេះទៀតនោះអ្នកផ្តល់ជំនួយគួរតែបញ្ជាក់ឲ្យច្បាស់ដល់មន្ត្រីខាងអង្គការសហប្រជាជាតិនិងខាងរដ្ឋាភិបាលថា បញ្ហាពុករលួយមិនមែនជាកលល្បិចសម្រាប់បំភ័ន្តនោះទេ ។ វាជារឿងមួយក្នុងចំណោម «វិធីប្រើប្រាស់ជំនួយដើម្បីបញ្ចប់អំពើពុករលួយ» មួយចំនួន ប្រសិនបើមិនបានដោះស្រាយភ្លាមៗ ហើយលទ្ធផលនឹងប៉ះពាល់មិនត្រឹមតែតុលាការនោះទេ ។ រដ្ឋាភិបាលលោកខាងលិចមិនអាចដោះស្រាយបញ្ហាដូចនេះតែម្នាក់ឯងបានឡើយ ។ ប្រទេសជប៉ុនត្រូវតែប្រើតួនាទីនាំមុខរបស់ខ្លួនដែលជាអ្នកផ្តល់ជំនួយសំខាន់ដល់តុលាការនេះ ហើយប្រទេសចិននិងប្រទេសនៅអាស៊ីអាគ្នេយ៍មិនគួរអនុញ្ញាតឲ្យរឿងនេះកើតឡើងដោយមិនយកចិត្តទុកដាក់ដូចដែលខ្លួនតែងតែជួបប្រទះនៅអតីតកាលនោះទេ ។

ការយករឿងអំពើពុករលួយជារឿងនាំមុខ វាជាជំហរមួយប្រកបដោយភាពគ្រោះថ្នាក់ ។ ការតវ៉ាច្រើនអំពីរឿងនេះវាធ្វើឲ្យមានការប៉ះពាល់ដល់ការពន្យារពេលម្តងទៀត ឬការបញ្ឈប់ដំណើរតុលាការ ។ ទោះជាយ៉ាងណាក៏ដោយ អំពើពុករលួយជារឿងមួយមិនគួរមិនយកចិត្តទុកដាក់នោះទេ ។ អង្គជំនុំជម្រះមិនអាចធ្វើឲ្យអ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យបៀមទុកការរំលោភបំពានដែលខ្លួនធ្លាប់រងទុក្ខនោះឡើយ ។ អ្វីដែលតុលាការនេះអាចធ្វើគឺផ្តល់ការវិនិច្ឆ័យដោយយុត្តិធម៌ និងធ្វើឲ្យប្រព័ន្ធច្បាប់មួយប្រសើរឡើងដែលនឹងការពារសិទ្ធិប្រជាជនកម្ពុជានៅពេលអនាគត ។ នេះជាបទដ្ឋានមួយដែលតុលាការគួរតែប្រកាន់យក ។

**ចន ឆរឆីអារី**

**ទីប្រឹក្សាច្បាប់មជ្ឈមណ្ឌលឯកសារកម្ពុជា**

# មរតកដែលទទួលបានពីរបបកម្ពុជាប្រជាធិបតេយ្យ

កំពតជាខេត្តមួយដែលមានព្រំប្រទល់ជាប់មាត់សមុទ្រព្រម ទាំងកោះនិងភ្នំមួយចំនួនទៀត ។ ទាំងអស់នេះជាកត្តាអំណោយ ផលសំខាន់សម្រាប់ការរស់នៅនិងការប្រកបមុខរបររកស៊ីរបស់ ប្រជាជនក្នុងខេត្តនេះ ។ មុនឆ្នាំ១៩៧៥ ខេត្តកំពតជាមូលដ្ឋាន យុទ្ធសាស្ត្រដ៏សំខាន់សម្រាប់ខ្មែរក្រហមលាក់ខ្លួននិងជាកន្លែងផ្គត់ផ្គង់ ស្បៀងនិងគ្រឿងសញ្ញុំធទៅឲ្យក្រុមអ្នកតស៊ូដើម្បីធ្វើការប្រឆាំង នឹងរដ្ឋាភិបាលលន់នល់ ។ ប្រជាជនដែលរស់នៅក្នុងខេត្តនេះត្រូវ ខ្មែរក្រហមចាត់ទុកថាជាអ្នកដែលគាំទ្រនិងរួមចំណែកយ៉ាងសំខាន់ ក្នុងចលនារំដោះប្រទេសជាតិរហូតទទួលបានជោគជ័យនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ក្រោយថ្ងៃជ័យជម្នះ ខ្មែរក្រហមបាន បញ្ចូលខេត្តនេះទៅក្នុងតំបន់៣៥ភូមិភាគនិរតី ។ អ្នកដែលមានតួនាទី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដូចជាគណៈកង គណៈស្រុក និង គណៈតំបន់ភាគច្រើនត្រូវបានជ្រើសចេញពីប្រជាជនរស់ដែលនៅ ក្នុងតំបន់នេះ ។ សឿន ក៏ជាយុទ្ធជនសកម្មម្នាក់របស់របបនេះដែរ ហើយគាត់បានពិការដៃឆ្វេងក្នុងខណៈពេលឡើងសមរភូមិប្រយុទ្ធ ជាមួយទាហានរដ្ឋាភិបាល លន់ នល់ ។ ពេលដែលសុំឲ្យគាត់រំឭក អំពីបទពិសោធន៍ដែលគាត់បានឆ្លងកាត់នៅក្នុងរបបនោះ សឿន ហាក់ដូចជារារែកក្នុងចិត្ត ប៉ុន្តែបន្តិចក្រោយមកគាត់ក៏យល់ព្រម ដោយបង្ហាញពីអារម្មណ៍ស្មោះត្រង់របស់គាត់ថា ដើម្បីជាប្រវត្តិ សាស្ត្រសម្រាប់អ្នកជំនាន់ក្រោយ ។

ប៉ា សឿន មានស្រុកកំណើតនៅក្នុងឃុំភ្នំលាវ ស្រុក កំពង់ត្រាច ខេត្តកំពត (បច្ចុប្បន្នសង្កាត់អង្គោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប) ។ ឪពុកឈ្មោះ ប៉ា សែប អាយុ៨៧ឆ្នាំ និង ម្តាយ ឈ្មោះ យឹម សុទ្ធ អាយុ៧៨ឆ្នាំ ។ អ្នកមានគុណទាំងពីរបានស្លាប់ អស់ទៅហើយដោយសារជំងឺ ។

ថ្ងៃមួយនៅខណៈពេលជិះកង់ទៅដល់មុខសាលា សឿន ងឿងឆ្ងល់យ៉ាងខ្លាំងដោយឃើញលោកគ្រូ-អ្នកគ្រូនាំគ្នាមកឈរ នៅមុខខ្លោងទ្វារ ហើយលើកដៃធ្វើជាសញ្ញាប្រាប់សិស្សទាំងអស់ ឲ្យត្រឡប់ទៅផ្ទះរៀងៗខ្លួនវិញ ព្រោះមានការផ្ទុះអាវុធនៅទីរួម ស្រុកកំពង់ត្រាច ។ បន្ទាប់មកលោកគ្រូ-អ្នកគ្រូទាំងអស់នាំគ្នា ឡើងជិះម៉ូតូរ៉ឺម៉កសំដៅទៅទិសខាងកើតវិញ ។ ចាប់តាំងពីពេល នោះមកគ្មានគ្រូណាម្នាក់មកបង្រៀនទៀតទេ ។ សឿន រៀនបាន ត្រឹមថ្នាក់ទី៧ពី (សង្គមចាស់) នៅសាលាបឋមសិក្សាពងទឹក ហើយ ក៏ឈប់រៀនដើម្បីជួយសម្រាលការងារឪពុកម្តាយនៅឯភូមិទូល ស្រងាំ ជាតំបន់ប្រទាញប្រទង់គ្នារវាងខ្មែរក្រហមនិងទាហានរដ្ឋា-ភិបាលលន់នល់ ។ ប្រជាជនជាច្រើនគ្រួសារក្នុងភូមិត្រូវគ្រប់គ្រង ដោយខ្មែរក្រហមហើយក្នុងរយៈពេលនោះមានមនុស្សចម្លែកៗចុះ មកឃោសនាពីគោលជំហរបដិវត្តន៍ប្រឆាំងពួកនាយទុននិងចក្រពត្តិ អាមេរិក និងបានចាត់តាំងអ្នកដឹកនាំក្នុងភូមិជាបន្តបន្ទាប់ទៀត ។

ក្រោយពេលខ្មែរក្រហមរំដោះបានភូមិទូលស្រងាំទាំងមូល ក្រុមគ្រួសាររបស់ សឿន ត្រូវប្រធានកងជម្លៀសឲ្យទៅរស់នៅ ភូមិស្រែជៀស ឃុំស្រែជៀស ស្រុកកំពង់ត្រាច ខេត្តកំពត ដោយ ប្រាប់ថានៅភូមិទូលស្រងាំត្រូវការរៀបចំសាជាថ្មី ។ ដោយគ្មានដី សម្រាប់ធ្វើស្រែចម្ការ ឪពុកម្តាយរបស់ សឿន បានប្រមូលលុយ កាក់បន្តិចបន្តួចដែលសន្សំបានកាលពីមុនសង្គ្រាមធ្វើជាដើមទុន ប្រកបមុខរបរលក់ស៊ុត ព្រោះថាក្នុងភូមិស្រែជៀស ការដោះដូរ ទំនិញជាលុយកាក់មិនទាន់មានការហាមឃាត់នៅឡើយ ។ ចំណែក សឿន ត្រូវនៅផ្ទះជួយដាំបាយ ស្រោចដំណាំនិងមើលប្អូនតូចៗ ។ នៅភូមិស្រែជៀសបាន២ឆ្នាំ អង្គការក៏បានអនុញ្ញាតឲ្យគ្រួសារ ដែលបានជម្លៀសទាំងអស់ត្រឡប់មករស់នៅភូមិកំណើតវិញ ។

## កូនប្រុសដើមទ្រូង៩ហត្ថ

សឿន បានត្រឡប់មករស់នៅលើផ្ទះចាស់មួយខ្នងក្នុងភូមិ ទូលស្រងាំជាមួយបីគ្រួសារផ្សេងទៀត ។ គ្រួសារ សឿន ពុំមាន អង្ករគ្រប់គ្រាន់សម្រាប់បរិភោគទេ ដូច្នេះ សឿន ត្រូវដើរបោច ស្រូវយកបុកដាំបាយបន្ថែម ។ មួយរយៈក្រោយមក ទើបមាន គ្រួសារអ្នកភូមិដែលខ្មែរក្រហមជម្លៀសទៅរស់នៅតំបន់ឆ្ងាយ តាំងពីឆ្នាំ១៩៧៤ ក៏វិលត្រឡប់មករស់នៅក្នុងភូមិនេះដែរ ។ ខ្មែរក្រហមចាប់ផ្តើមបែងចែកមនុស្សជាក្រុមៗតាមវ័យដែលមាន

ក្រុមកុមារ ក្រុមយុវជន និងក្រុមមនុស្សចាស់ដើម្បីធ្វើការងារប្រវាស់ដៃ ។ លើសពីនោះ មានការប្រមូលចានឆ្នាំង រទេះ គោនិងក្របីដាក់ក្នុងសហករណ៍រួមនិងហូបបាយរួម ។ សឿន ត្រូវប្រធានភូមិឈ្មោះ ទាប ជ្រើសរើសឲ្យចូលក្នុងកងយុវជនភូមិ ។ ដូច្នេះ សឿន ត្រូវចូលរួមប្រជុំនិងរៀនសូត្រវគ្គបណ្ដុះបណ្ដាលនយោបាយផ្សេងៗក្រោមការបង្ហាត់បង្រៀនពីឈ្មោះ ខែម ជាប្រធានកងយុវជន ។ វគ្គបណ្ដុះបណ្ដាលនេះជាវគ្គបំពាក់បំប៉នគោលជំហរប្រឆាំងនឹងពួកសក្តិភូមិនាយទុន ។ ជាញឹកញាប់ ខែម តែងតែនិយាយក្រើនរំឭកដល់សិក្ខាកាមទាំងអស់ថា៖ «យើងជាកូនប្រុសដើមទ្រូង៩ហត្ថមិនត្រូវនៅសម្ងំសុខនៅក្រោយនោះទេ រៀមច្បងយើងខំតស៊ូបង្ហូរញើស បង្ហូរឈាមនៅសមរភូមិមុខ យើងត្រូវតែធ្វើជាទំពាំងស្នងឫស្សី យើងត្រូវតែជួយគ្នា» ។ ដើម្បីបង្ហាញថាខ្លួនជាកូនប្រុសដើមទ្រូង៩ហត្ថ ហើយគួបផ្សំការលំបាកក្នុងការងារលើកទំនប់ជីកប្រឡាយនិងរបបអាហារមិនគ្រប់គ្រាន់ សឿន ក៏សម្រេចចិត្តសុំលាឪពុកម្ដាយចូលបម្រើបដិវត្តន៍ ។ នៅពេលចូលដំបូង ខែម ចាប់ផ្ដើមបែងចែកយុវជនជាក្រុមដោយក្នុងមួយក្រុមមានសមាជិក១២នាក់ ។ ក្រុមរបស់ សឿន ទទួលភារកិច្ចដើរយាមល្បាតនៅភូមិអង្កោល ភូមិព្រៃតាកុយ និងភូមិភ្នំលាវ ស្ថិតក្នុងឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ។ ក្រៅពីនេះ សឿន មានកាតព្វកិច្ចហាត់ពីវិធីកាន់កាំភ្លើង រត់ប្រមៀលខ្លួន លូន ក្រាបនៅតាមវាលស្រែ ។ រីឯរបបអាហារ យុវជនត្រូវដោះស្រាយដោយខ្លួនឯង គឺដើរសុំតាមផ្ទះរបស់អ្នកភូមិហូប ។ បន្ទាប់ពីហាត់បានកន្លះខែ ក៏មានព្រឹត្តិការណ៍វាយប្រយុទ្ធគ្នាធំមួយរវាងទាហានលន់នល់ ពួកធីវគី និងខ្មែរក្រហមនៅខាងជើងទីរួមស្រុកកំពង់ត្រាច ។ សឿន ត្រូវបញ្ជូនទៅចាំស្ទាក់បាញ់ទាហានបាក់ទ័ពលន់នល់ និងធីវគី នៅខាងត្បូងទីរួមស្រុកកំពង់ត្រាច ។ ប៉ុន្តែដោយសារ សឿន មិនធ្លាប់ឡើងវាយនៅសមរភូមិ ម្យ៉ាងខ្លាចគ្រាប់កាំភ្លើង សឿន ក៏រត់ត្រឡប់មកនៅភូមិភ្នំលាវវិញ ។

## កងវរៈ១២៦

ចុងឆ្នាំ១៩៧៤ មានការជ្រើសរើសយុវជននៅតាមភូមិនានាឲ្យចូលបម្រើទ័ព ហើយយុវជនដែលបានជ្រើសរើសត្រូវបញ្ជូនទៅហាត់ក្បួនយុទ្ធសាស្ត្រនៅបន្ទាយប្រមូលផ្ដុំជិតវត្តកំពង់ត្រឡាចខាងលិចផ្សារដំណាក់ចង្កើរមុននឹងឡើងសមរភូមិប្រយុទ្ធ ។ ប៉ុន្តែដោយពុំទាន់មានការបែងចែកជាក្រុម ជាកងនិងមេដឹកនាំច្បាស់លាស់ យុវជនមួយចំនួនបានរត់ចោលជួរ ។ ក្រោយមកខ្មែរក្រហមក៏ចាប់ផ្ដើមរៀបចំបែងចែកជាកងជាវរៈនិងកងពលដើម្បីងាយស្រួលគ្រប់គ្រង ។

សឿន រត់ចោលជួរមករស់នៅភូមិភ្នំលាវបានមួយរយៈក៏ត្រូវឈ្មោះ នី, អាន និង បាន ដែលជាមេកងរយជ្រើសរើសឲ្យចូលធ្វើទ័ពស្រុកកំពង់ត្រាចវិញ ។ បន្ទាប់មក ស៊ាន ជាគណៈស្រុកកំពង់ត្រាច បានចាត់តាំង សឿន ឲ្យទៅយាមការពារតាមមាត់ឆ្នេរកែប ។ ក្នុងឆ្នាំ១៩៧៣ ពេលកំពុងដើរល្បាតប្រចាំការកងម៉ារីនរបស់ទាហានលន់នល់និងធីវគីបានចូលមកវាយឆ្មក់ពីទិសខាងត្បូង ។ ដោយមិនអាចទប់ទល់បាន សឿន ក៏រត់គេចទៅលាក់ខ្លួននៅបន្ទាយស្ថិតនៅជិតវត្តកំពង់ត្រឡាចខាងជើងផ្សារដំណាក់ចង្កើរ ។ រស់នៅក្នុងបន្ទាយបានមួយរយៈ សឿន ក៏ត្រូវបញ្ចូលទៅក្នុងកងវរៈ១២៦ ក្រោមការគ្រប់គ្រងរបស់ អាំ ជាប្រធានវរៈ ។ ក្នុងបន្ទាយមានកងវរៈ១២៦និងកងអនុសេនាធំបីកងទៀតសរុបទាំងអស់មានកងទ័ពជាង៤០០នាក់ ។ នៅក្នុងបន្ទាយ សឿន មានកាតព្វកិច្ចហាត់រៀនក្បួនយុទ្ធសាស្ត្របាញ់កាំភ្លើង ហើយពេលយប់ទទួលភារកិច្ចឡើងវាយឆ្មក់ទីតាំងបន្ទាយទាហានលន់នល់នៅសេះសនិងកំពង់ហ្លួង ខេត្តកំពត ។

## ពិការដៃនៅសមរភូមិ

ឆ្នាំ១៩៧៤ សឿន ត្រូវរបួសពិការដៃម្ខាងក្នុងពេលឡើងសមរភូមិអណ្ដូងទឹកខាងលិចខេត្តកំពត ។ សឿន បានរំឭកថាពេលនោះបន្ទាប់ពីឡើងវាយនៅសមរភូមិរោងចក្រស៊ីម៉ង់ត៍ចក្រីទីង ក្រកេះ គាត់ក៏ដកមកឈរជើងនៅបន្ទាយវិញ ។ ថ្ងៃមួយមានរៀបចំពិធីជប់លៀងអបអរជូនដំណើរកងទ័ពមុនចេញទៅប្រយុទ្ធ ។ ពិធីនេះចប់នៅម៉ោង១១យប់ សឿន ក៏ត្រូវបញ្ជូនទៅវាយនៅសមរភូមិអណ្ដូងទឹកខាងលិចទីរួមខេត្តកំពត ។ ខណៈពេលគាត់លើកកាំភ្លើងបម្រុងនឹងបាញ់ ទាហានលន់នល់បានបាញ់រះមកលើគាត់មុន ហើយត្រូវដៃឆ្វេងបណ្ដាលឲ្យបាក់តែម្ដង ។ សឿន ត្រូវបានបញ្ជូនទៅសង្គ្រោះជីវិតនៅស្ទឹងកែវ (ពេទ្យតំបន់៣៥) ដោយកាណូតបើកឆ្លងតាមទឹកឈូតាំងពីយប់រហូតម៉ោង៧ព្រឹក

ទើបទៅដល់មន្ទីរពេទ្យនោះ ។ មន្ទីរពេទ្យមានរោងបួនល្វែងសង់នៅក្នុងព្រៃឫស្សី ។ សឿន ត្រូវបញ្ជូនទៅចូលក្នុងរោងវះកាត់ដែលមាន តាគុយ ជាប្រធានមន្ទីរពេទ្យជាអ្នកវះកាត់ ។ បន្ទាប់មក សឿន ត្រូវបញ្ជូនទៅសម្រាកនៅរោងផ្សេងមួយទៀតដែលពេញណែនដោយអ្នករបួស ភាគច្រើនជាកងទ័ពមានបុរសនិងស្ត្រីចម្រុះគ្នាសរុបទាំងអស់ប្រហែល១០០នាក់ ។ ចំណែកថ្នាំពេទ្យសម្រាប់ព្យាបាលគឺជាជំនួយរបស់បារាំងនិងមួយភាគធំជាជំនួយមកពីប្រទេសចិន ។ ចំពោះអ្នកស្លាប់ត្រូវយកទៅកប់នៅទីវាលមួយខាងលិចមន្ទីរពេទ្យ ។ សឿន ទទួលបានរបបអាហារ៣ពេលក្នុងមួយថ្ងៃ ពេលព្រឹកបាយ ពេលថ្ងៃបបរគ្រឿង និងពេលល្ងាចហូបបាយម្តងទៀត ក្រៅពីនោះមានរបបទឹកដោះគោនិងបន្ថែមបំប៉នសុខភាពបន្ថែមទៀត ។ សឿន បានទទួលការថែទាំដោយយកចិត្តទុកដាក់ពីសំណាក់គ្រូពេទ្យនៅទីនោះ ។ រហូតដល់ឆ្នាំ១៩៧៥ សឿន បានទទួលដំណឹងពីអ្នកធ្វើការខាងសេដ្ឋកិច្ចដែលដឹកស្បៀងនិងថ្នាំមកផ្គត់ផ្គង់មន្ទីរពេទ្យស៊ឹងកែវប្រាប់ថា កងទ័ពបដិវត្តន៍រំដោះបានទីក្រុងភ្នំពេញទាំងស្រុងហើយ ។ សឿន សប្បាយរីករាយយ៉ាងខ្លាំង គាត់សង្ឃឹមថានឹងបានវិលត្រឡប់ទៅរស់ជួបជុំឪពុកម្តាយនៅស្រុកកំណើតវិញ ។ ផ្ទុយទៅវិញ សឿន បែរជាត្រូវបញ្ជូនទៅកន្លែងផ្សេងបន្តទៀត ។

បន្ទាប់ពីរំដោះខេត្តកំពតបានមួយសប្តាហ៍ មានកប៉ាល់មួយគ្រឿងបានមកទទួល សឿន ចេញពីមន្ទីរពេទ្យស៊ឹងកែវដើម្បីយកទៅព្យាបាលបន្តនៅមន្ទីរពេទ្យខេត្តកំពតវិញ ។ សឿន សម្រាកព្យាបាលបានរយៈពេលមួយខែ គ្រូពេទ្យក៏បញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យវរៈ១២៦នៅស្រុកកំពង់ត្រាចជាកន្លែងដែលគាត់ធ្លាប់ធ្វើការពីមុន ។ សឿន ស្នាក់នៅព្យាបាលរហូតដល់ជាសះស្បើយ ទើប ដាន់ ប្រធានពេទ្យវរៈបានអនុញ្ញាតឲ្យគាត់ចេញពីមន្ទីរពេទ្យត្រឡប់ទៅកាន់អង្គភាពវិញ ហើយត្រូវឈរជើងនៅកែប ។ ឆ្លៀតឱកាសនោះ សឿន បានឆ្លៀតចូលសួរសុខទុក្ខឪពុកម្តាយនៅក្នុងភូមិទួលស្រង៉ាំ ។ តាមផ្លូវ សឿន ភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយបានឃើញប្រព័ន្ធភ្លឺស្រែនិងប្រឡាយទឹកខ្វាត់ខ្វែងទើបលើកថ្មីៗ ។ សឿន រំពុកថាពេលគាត់ទៅដល់ផ្ទះម្តាយគួញត្អែរប្រាប់ថា «ពេលកូនមិននៅផ្ទះ មេកងបានឲ្យម៉ែមើលក្មេងៗ និងធ្វើដីមិនដែលមានពេលទំនេរទេ» ហើយម្តាយគាត់បានសុំកុំឲ្យគាត់ត្រឡប់ទៅអង្គភាពវិញអី ប៉ុន្តែ សឿន មិនព្រមដោយស្នាក់នៅបានតែ២យប់ក៏បន្តដំណើរទៅកែបទៀត ។ ពេលទៅដល់ សឿន ត្រូវបញ្ជូនឲ្យទៅនៅប្រចាំការនៅប៉ុស្តិ៍ជាមួយនិរសារមួយចំនួនដើម្បីទាក់ទងកងទ័ពដែលឈរជើងការពារនៅតាមកោះ ។ អង្គភាពវរៈ១២៦ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ លន់ ជាប្រធានថ្មី (ព្រោះ អាំ ត្រូវឡើងទៅធ្វើជាគណៈខេត្តកំពត) ។ ដោយមើលឃើញថា សឿន បាត់បង់សមត្ថភាពការងារ លន់ បានឲ្យយោបល់ថា៖ «មិត្តឯងពិការដៃអ៊ីចឹងមិនអាចកាន់កាំភ្លើងបានទេ ដូច្នេះមិត្តឯងត្រូវផ្លាស់ទៅនៅមន្ទីរពិការវិញ» ។ នៅមន្ទីរពិការមានជនពិការគ្រប់ប្រភេទខ្វះខ្វាក់ខ្វិន សរុបទាំងអស់មានប្រមាណជា១០០នាក់ ដែលមាន ខន ពិការជើងម្ខាង ជាប្រធានមន្ទីរ ។ ចំពោះការងារនៅមន្ទីរពិការនេះមានបែងចែកទៅតាមសមត្ថភាពរបស់អ្នកពិការដូចជាអ្នកពិការជើងទាំងពីរត្រូវវេរអំបោះនិងវេញខ្សែគោ ។ ចំណែក សឿន ពិការដៃម្ខាងតែអាចដើរបានមានភារកិច្ចរែកទឹកដាក់ពាងនិងរែកទឹកស្រោច ខ្ទឹម ដាំស្ពៃ និងជី ។ នៅទីនោះ សឿន ក៏ដូចជនពិការដទៃទៀតបានទទួលរបបអាហារបីពេលក្នុងមួយថ្ងៃដោយមានត្រីសាច់ បន្លែដែលដាំនៅក្នុងមន្ទីរនិងបន្ថែមដងដែរ ។ ដោយមានពេទ្យនារី៣នាក់នៅប្រចាំការព្យាបាលនិងផ្តល់ថ្នាំឲ្យអ្នកជំងឺលេបយ៉ាងទៀងទាត់ពេលវេលា ។ ចំពោះអ្នកឈឺធ្ងន់ត្រូវបញ្ជូនបន្តទៅព្យាបាលនៅមន្ទីរពេទ្យខេត្តកំពត (មន្ទីរពេទ្យតំបន់៣៥) ។

## ផ្លាស់ទៅធ្វើការនៅសៀមរាប

ខែ៣ ឆ្នាំ១៩៧៧ តាអាំ ប្រធានក្រុងកំពតបានធ្វើការជ្រើសរើសមនុស្សនៅក្នុងមន្ទីរពិការ ដើម្បីឲ្យទៅធ្វើការនៅខេត្តសៀមរាប(ភូមិភាគឧត្តរ) ។ ក្នុងនោះមាន សឿន និងយុទ្ធជន៤នាក់ទៀតត្រូវបានជ្រើសរើសនិងកងទ័ពពីមន្ទីរផ្សេងៗទៀតសរុបទាំងអស់មានជាង១០០នាក់ ។ បន្ទាប់មករថយន្តសេអឹមសេ១០គ្រឿងបានមកទទួលយកទៅ ដោយមាន កង ចាប ជាគណៈតំបន់៣៥និងនិរសាររបស់គាត់អមដំណើរ ។ ទៅដល់ភ្នំពេញត្រង់ម្តុំ អគារវែងបិទកញ្ចក់គណៈប្រតិភូមួយក្រុមចេញមកទទួលស្វាគមន៍និងរៀបចំបែងចែកកន្លែងស្នាក់នៅឲ្យអ្នកពិការទាំងអស់ ហើយផ្តល់របបអាហារបីពេលក្នុងមួយថ្ងៃ ហើយរៀនរាល់ពេល

ល្ងាចមានបែកបារីឲ្យម្នាក់មួយកញ្ចប់ទៀតផង ។ ៥ថ្ងៃក្រោយមក សឿន ត្រូវបញ្ជូនបន្តទៅខេត្តកំពង់ចាម ហើយស្នាក់នៅផ្ទះម៉ូតបារាំងដែលស្ថិតនៅខាងត្បូងស្ពានជាប់មាត់ទន្លេ រីឯរបបអាហារមានបីពេលក្នុងមួយថ្ងៃដូចនៅភ្នំពេញដែរ ។ ស្នាក់នៅបានមួយសប្តាហ៍ ក្រុមរបស់ សឿន ក៏បន្តដំណើរទៅខេត្តសៀមរាបទៀត ។ ទៅដល់ខេត្តសៀមរាប ជាតិ ដែលជាអ្នកគ្រប់គ្រងសណ្ឋាគារបឹងកាឡូ (សម័យលន់នល់) បានចេញមកទទួល កង ចាប ឲ្យទៅស្នាក់នៅបន្ទប់ខាងលើ ។ ចំណែកកងទ័ពពិការទាំងអស់ត្រូវដើររកកន្លែងស្នាក់នៅរៀងៗខ្លួននៅក្នុងបរិវេណផ្នែកខាងក្រោមសណ្ឋាគារនិងដើររកអង្ករ-ម្ហូបថែមទៀត ។ សឿន និងមិត្តភក្តិបាននាំគ្នាទៅស្នាក់នៅក្នុងបន្ទប់ទំនេរមួយនៅក្បែររោងចិញ្ចឹមគោ ។

នៅថ្ងៃបន្ទាប់ កង ចាប ដែលទើបតែងតាំងជាគណៈភូមិភាគឧត្តរថ្មី បានអញ្ជើញគណៈកង គណៈឃុំនិងគណៈស្រុកក្នុងខេត្តសៀមរាបទាំងអស់មកចូលរួមប្រជុំ រួមទាំងអ្នកពិការដែលទើបនឹងមកដល់ថ្មីផងដែរ ។ កង ចាប បានឡើងខទ្ទេសនាមឈ្មោះកងទ័ពពិការឲ្យចុះទៅធ្វើការតាមស្រុកនានាដោយក្នុងមួយស្រុកមានពី៣ទៅ៤នាក់ ហើយថែមទាំងបានផ្តែផ្តាំនិងសំណូមពរឲ្យគណៈស្រុកទាំងអស់រួមសហការនិងដោះស្រាយការរស់នៅអាហារហូបចុកដល់អ្នកទាំងអស់នេះផង ។

## ការងារពាណិជ្ជកម្មស្រុក

សឿន បានទទួលការចាត់តាំងឲ្យទៅធ្វើការនៅស្រុកក្រឡាញ់ ក្នុងឋានៈជាប្រធានមន្ទីរពាណិជ្ជកម្មស្រុក និងមាននាទីទទួលខុសត្រូវការជម្លៀសប្រជាជនចាស់ទាំង៧ឃុំក្នុងស្រុកក្រឡាញ់ឲ្យទៅនៅរស់កន្លែងផ្សេង ដោយបញ្ចូលអ្នកថ្មីមកវិញក្រោមការគ្រប់គ្រងរបស់តំបន់និងគណៈស្រុកឈ្មោះ ចិន អតីតប្រធានគុក (ខេត្តកំពត) ។ សឿន បានបញ្ជាឲ្យកងទ័ពក្រោមបញ្ជាដើរគាស់ឃ្លាំងទំនិញដែលស្តុកទុកតាំងពីឆ្នាំ១៩៧៥ នៅផ្សារកំពង់ថ្កូវនិងផ្សារក្រឡាញ់ រួចដឹកជញ្ជូនទំនិញទាំងអស់តាមរទេះគោយកមកដាក់ក្នុងឃ្លាំងពាណិជ្ជកម្មស្រុកនិងមួយចំនួនចែកឲ្យប្រជាជនប្រើប្រាស់ ។ នៅមន្ទីរពាណិជ្ជកម្ម សឿន ក៏ធ្លាប់ត្រូវបានអញ្ជើញឲ្យទៅចូលរួមទទួលគណៈប្រតិភូមា គឺឧត្តមសេនីយ៍ អ៊ូ ណេវិន និងគណៈប្រតិភូចិន ឈិន យ៉ុងគួយ នៅព្រលានយន្តហោះខេត្តសៀមរាប ដែលមកទស្សនកិច្ចនៅប្រាសាទអង្គរវត្តនិងអាងក្រពើ ។ ដំណើរទស្សនកិច្ចនេះ អមដំណើរដោយ កង ចាប ។

ក្រោយពីត្រឡប់មកធ្វើការទីនេះបានមួយរយៈ ក៏មានព្រឹត្តិការណ៍ចាប់មេភូមិ គណៈឃុំ និងគណៈស្រុករងឈ្មោះ បាន ។ កង ចាប បានបញ្ជាឲ្យតាចិនប្រើល្បិចហៅអ្នកទាំងនោះទៅប្រជុំនៅស្រុក ហើយធ្វើការចាប់ខ្លួននិងបញ្ជូនទៅដាក់គុកនៅសៀមរាបតែម្តង ដោយចោទប្រកាន់ថាមានគម្រោងក្បត់យកទ្រព្យសម្បត្តិរបស់អង្គការមកទុកជាកម្មសិទ្ធផ្ទាល់ខ្លួននិងធ្វើបាបប្រជាជន ។

## ប្រធានកងរយ

ក្រោយពីចាប់ខ្លួនប្រធានភូមិ គណៈឃុំ និងគណៈស្រុក សឿន មានតួនាទីមួយទៀតគឺធ្វើជាប្រធានកងរយគ្រប់គ្រងកងទ័ពចំនួន១០០នាក់និងមើលការខុសត្រូវប្រជាជននៅក្នុងឃុំទឹកជុំនិងឃុំចាប់ដៃលើកប្រព័ន្ធប្រឡាយទឹកបញ្ចូលស្រែ ។ នៅទីនោះ សឿន ទទួលបានការគោរពនិងស្រលាញ់ពីប្រជាជនដោយសារគាត់មានការយោគយល់ច្រើន ដូចជាពេលឃើញស្ត្រីកូនខ្ចីមកធ្វើការងារធ្ងន់គាត់អនុញ្ញាតឲ្យត្រឡប់ទៅកន្លែងវិញ ។ ទន្ទឹមនឹងនេះ សឿន ក៏មានសិទ្ធិចាប់ខ្លួនអ្នកដែលប្រឆាំងនឹងអង្គការដែរ នៅពេលមានការរាយការណ៍ពីប្រធានក្រុម ប្រធានកង មេភូមិ គណៈឃុំ ឬមានបញ្ជាពីថ្នាក់លើ ។ ជនដែលត្រូវបានចាប់ខ្លួនត្រូវបញ្ជូនយកទៅដាក់គុកនៅមន្ទីរសន្តិសុខភ្នំទ្រង់បាត ស្ថិតក្នុងស្រុកក្រឡាញ់ក្រោមការគ្រប់គ្រងរបស់ប្រធានគុកឈ្មោះ សៀត អ្នកទោសដែលស្លាប់ក្នុងគុកនេះត្រូវដុតចោលជាមួយអង្កាម ។ សៀត ក្រោយមកត្រូវបានចាប់បញ្ជូនទៅដាក់គុកខេត្តសៀមរាបដែរ ពីបទចោទប្រកាន់ថាចាប់រំលោភអ្នកទោស ។

ក្រៅពីការងារមើលខុសត្រូវប្រជាជនលើកប្រឡាយ សឿន មានភារកិច្ចដឹកជញ្ជូនអង្ករ ត្រី សាច់ និងបន្លែពីស្រុកក្រឡាញ់យកទៅឲ្យ កង ចាប ។ ថ្ងៃមួយ សឿន បានទទួលបញ្ជាពីថ្នាក់លើឲ្យកម្ទេចប្រជាជន១៧មេសានៅក្នុងស្រុកក្រឡាញ់ទាំងអស់ដោយចោទប្រកាន់ថាក្បត់បដិវត្តន៍ ។ សឿន ក៏បានធ្វើរបាយការណ៍វាយជាអក្សរលីលេខផ្ញើទៅកាន់ស្រុក ហើយស្រុកក៏បញ្ជូនបន្តទៅតំបន់ក្នុងគោលបំណងជួយអ្នកទាំងនោះ ។ របាយការណ៍នោះមានខ្លឹមសារថា «តាមការពិនិត្យដាក់ស្តែងពួក១៧មេសា មិនមាន

សកម្មភាពប្រឆាំងអ៊ីទេ ពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេខិតខំបំពេញការងារទៅតាមផែនការរបស់បក្ស និងអប់រំគោលជំហរបដិវត្តន៍បានល្អ ។ ដោយសាររបាយការណ៍របស់ សឿន បានធ្វើឲ្យប្រជាជន ១៧មេសា ទាំងអស់រួចផុតពីការសម្លាប់ ។

ដោយមើលឃើញពីគុណសម្បត្តិនិងការងារល្អ នៅខែឧសភា ឆ្នាំ១៩៧៨ កង ចាប បានផ្សំផ្គុំ សឿន និងក្មួយស្រីបង្កើតឈ្មោះ ខុម ធ្វើការក្នុងមន្ទីរពេទ្យខេត្តសៀមរាបជាប្តីប្រពន្ធ ។ ដើម្បីងាយស្រួលទៅមកផ្ទះនិងនៅជិតកន្លែងធ្វើការរបស់ សឿន ផង កង ចាប បានផ្លាស់ ខុម ពីមន្ទីរពេទ្យខេត្តសៀមរាបឲ្យមកធ្វើការនៅមន្ទីរពេទ្យស្រុកក្រឡាញ់វិញ ។

## ជាប់ទោសព្រោះជាប់ពាក់ព័ន្ធខ្សែរយៈខ្មាំង

ចុងឆ្នាំ១៩៧៨ កង ចាប ត្រូវបានអង្គការចាប់ខ្លួននៅខណៈពេលគាត់ឡើងទៅប្រជុំនៅភ្នំពេញ ហើយតំណែងរបស់គាត់ត្រូវជំនួសដោយ តាម៉ុក ។ មកដល់ដំបូង តាម៉ុក បានហៅគណៈឃុំគណៈស្រុកប្រជុំជាច្រើនដង ហើយរិះគន់អ្នកទាំងនោះនៅចំពោះមុខថា ធ្វើការមិនបានល្អនិងមិនគិតគូរពីរបបហូបចុកនិងការរស់នៅរបស់ប្រជាជន ។ ៧ថ្ងៃក្រោយ តាម៉ុក បានបញ្ជាឲ្យក្រុមរបស់ សឿន យកឡានមកទទួលមេកង គណៈឃុំ គណៈស្រុក រួមទាំង សឿន និងប្រពន្ធ ដោយប្រាប់ថាផ្លាស់ទៅធ្វើការនៅខេត្តបាត់ដំបង ម្តង ព្រោះធ្វើការនៅទីនេះយូរហើយ ។ រថយន្តបានដឹក សឿន និងប្រពន្ធឆ្ពោះមកកាន់ស្រុកស្វាយស៊ីសុផុន រួចបន្តយកមកដាក់នៅវត្តមួយជិតស្ទឹងស្លាគូ ។ នៅថ្ងៃបន្ទាប់ សឿន និងប្រពន្ធត្រូវបញ្ជូនឲ្យទៅស្នាក់នៅក្នុងមន្ទីរសាធារណការស្ទឹងស្លាគូជាកន្លែងដែលគេបោះបង់ចោលកាលពីសម័យសង្រ្គាម ។ នៅទីនេះមានប្រធានម្នាក់ជាអ្នកគ្រប់គ្រង សឿន មានភារកិច្ចដើរពិនិត្យមើលទឹកក្នុងស្រែ ឃ្វាលគោ ដើររកស្មៅឲ្យគោ ចិញ្ចឹមទា និងភ្ជួរស្រែ ។ ក្រោយមក សឿន ត្រូវដកឲ្យទៅធ្វើការនៅដីទួលមួយកន្លែងនៅកណ្តាលស្ទឹងស្លាគូដែលមានទឹកព័ទ្ធជុំវិញ ។ ចំណែកប្រពន្ធរបស់គាត់ត្រូវអង្គការបញ្ជូនឲ្យទៅប្រូតស្រូវនិងធ្វើជីនៅក្នុងកងនារីដែលមានចម្ងាយ២គីឡូម៉ែត្រពីកន្លែងគាត់ធ្វើការ ។ ២ខែក្រោយមក កងទ័ពវៀតណាមវាយចូលដល់ស្លាគូ សឿន និងប្រពន្ធបាននាំគ្នារត់ភៀសខ្លួនទៅទិសខាងលិច ។

## ត្រឡប់មករស់នៅភូមិកំណើត

តាមការឃោសនារបស់ពួកខ្មែរក្រហមថា កងទ័ពវៀតណាមចូលមកកាប់សម្លាប់ប្រជាជន និងចាប់ស្ត្រីរំលោភ សឿន ក៏នាំប្រពន្ធរត់ឡើងលើភ្នំលះបង់និងដីរីរមៀល ។ មួយរយៈក្រោយមក ដោយសារពុំមានអាហារហូបគ្រប់គ្រាន់ សឿន បានសម្រេចចិត្តទៅរស់នៅស្រុកកំណើតខាងប្រពន្ធនៅភូមិអង្គប្រាសាទ ឃុំអង្គប្រាសាទ ស្រុកគិរីវង្ស ខេត្តតាកែវ ។ រហូតដល់ចុងឆ្នាំ១៩៧៩ សឿន បានផ្លាស់ទីលំនៅមករស់នៅភូមិទួលស្រងាំ សង្កាត់អង្កោលខ័ណ្ឌដំណាក់ចង្អេីរ ក្រុងកែបវិញ ដោយប្រកបរបរធ្វើស្រែ និងទិញស៊ុតពីផ្សារពាមយកទៅលក់នៅខេត្តកំពត ហើយឆ្លៀតពេលទំនេរចុះទៅនេសាទនៅត្រើយកោះ ។

ដោយនៅក្នុងភូមិមិនសូវមានអ្នកចេះអក្សរ សឿន ត្រូវបានអ្នកភូមិសំណូមពរឲ្យជួយបង្រៀនអក្សរក្មេងៗ ។ សឿន បានយកបរិវេណខាងក្រោមផ្ទះរបស់គាត់ធ្វើជាសាលាបង្រៀនក្រោមការឧបត្ថម្ភជាសម្ភារៈនិងប្រាក់កាសពីក្រសួងអប់រំ ។ ក្រោយមកក្រសួងអប់រំបានសាងសង់សាលាបឋមសិក្សាទួលស្រងាំមួយខ្នង ប៉ុន្តែ សឿន អាចបង្រៀននៅសាលារៀនថ្មីនេះបានតែក្នុងនាមជាគ្រូជាប់កិច្ចសន្យាប៉ុណ្ណោះ ព្រោះថាគាត់គ្មានសញ្ញាប័ត្រគរុកោសល្យ ។ បន្ទាប់ពីចប់កិច្ចសន្យា សឿន ក៏មកធ្វើការជាបុគ្គលិកចុះបញ្ជីអត្រានុកូលដ្ឋានប្រជាជនក្នុងភូមិវិញ ។

សព្វថ្ងៃ សឿន គ្មានប្រកបមុខរបបរអ្វីផ្សេងក្រៅពីធ្វើស្រែដើម្បីបំពេញជីវភាពខ្វះខាតប្រចាំថ្ងៃនិងចិញ្ចឹមកូន៨នាក់នៅក្នុងបន្ទុកឡើយ ។ សឿន បានបន្ថែមថា ទោះបីក្នុងរបបខ្មែរក្រហមគាត់ធ្លាប់បានហូបឆ្អែត មានតួនាទីធំនិងគ្មានបងប្អូនស្លាប់ក្នុងរបបនេះក៏ដោយ ក៏របបនេះ បានបន្សល់ទុកនូវមរតកមួយដែលនៅជិតជាប់ក្នុងអារម្មណ៍និងខ្លួនរបស់គាត់ជារៀងរហូតគឺភាពពិការដៃឆ្វេងនេះតែម្តង ដែលជាហេតុធ្វើគាត់មិនអាចធ្វើការធ្ងន់ៗបានដូចបុរសពេញលក្ខណៈ ។ ទន្ទឹមនឹងនេះ សឿន សំណូមពរឲ្យតុលាការនាំយកមេដឹកនាំខ្មែរក្រហមដែលបញ្ជាឲ្យធ្វើអំពើទាំងនេះមកកាត់ទោសដើម្បីរកយុត្តិធម៌ជូនប្រជាជននិងធ្វើយ៉ាងណាកុំឲ្យមានការគុំកួនគ្នាទៅថ្ងៃក្រោយដើម្បីឲ្យប្រជាជនអាចរស់នៅក្នុងសុខសន្តិភាព ។

**សោម ប៊ុនថន**

# គុកខ្មែរក្រហម

## ខេត្តស្វាយរៀង

### ស្រុកចន្ទ្រា

### ១) មន្ទីរសន្តិសុខបន្ទប់ខ្សាច់



មន្ទីរសន្តិសុខបន្ទប់ខ្សាច់

មន្ទីរសន្តិសុខបន្ទប់ខ្សាច់ ស្ថិតនៅភូមិបុស្ស ឃុំមេសថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង ត្រូវបានបង្កើតនៅឆ្នាំ១៩៧៤ ។ មន្ទីរសន្តិសុខនេះមានកន្លែងឃុំឃាំងចំនួន៦ ដែលខ្មែរក្រហមទុកសម្រាប់ដាក់អ្នកទោសគ្រប់ប្រភេទ ។ កងសន្តិសុខបានប្រមូលអ្នកទោសមកពីភូមិនិងឃុំនានាក្នុងស្រុកចន្ទ្រាតាមរបៀបបោកប្រាស់ថាទៅរៀនសូត្រ ។

លោក គង់ វស្សា អាយុ៤៨ឆ្នាំ រស់នៅភូមិពោធិ ឃុំមេសថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង និងជាគណៈស្រុកចន្ទ្រាបាននិយាយថា នៅពេលគាត់វិលត្រឡប់ពីភ្នំពេញមកវិញ កម្មាភិបាលខ្មែរក្រហមបានបញ្ជាឲ្យគាត់ទៅរៀនសូត្រជាមួយអ្នក៦ ទៀតដែលរស់ក្នុងស្រុកភូមិជាមួយគ្នា ។ មួយរយៈក្រោយមក វស្សា និងអ្នក៦ ទៀតបានជាប់ឃុំឃាំងនៅក្នុងផ្ទះមួយដែលមានជញ្ជាំងបាំងជិតឈឹង ព្រមទាំងមានកងសន្តិសុខយាមការពារជុំវិញផង ។ វស្សា និយាយទៀតថា មុនទៅដល់មន្ទីរឃុំឃាំងជនរងគ្រោះបានទទួលការព្រមានដោយពាក្យសម្តីធ្ងន់ៗឲ្យឆ្លើយសារភាពនូវអ្វីដែលខ្លួនធ្លាប់ធ្វើកាលពីមុន ។ វស្សា បាននិយាយគ្រាប់សម្តីកម្មាភិបាលខ្មែរក្រហមថា «បើធ្វើអីត្រូវតែឆ្លើយធ្វើហ្នឹង បើពុំនោះទេច្បាស់ជាត្រូវស្លាប់» ។

នៅឆ្នាំ១៩៧៦ មន្ទីរសន្តិសុខបន្ទប់ខ្សាច់មានឃុំឃាំងអ្នកទោសជាគ្រូបង្រៀន ទាហាន ប៉ូលិស មន្ត្រីរដ្ឋការ សម័យសាធារណរដ្ឋខ្មែរនិងប្រជាជនជម្លៀសពីទីក្រុងភ្នំពេញខ្លះផង ។ នៅពេលថ្ងៃអ្នកទោសទាំងអស់ត្រូវឆ្នាំគុក បញ្ចេញឲ្យទៅធ្វើការងារលើកទំនប់ជីកប្រឡាយ និងជីកស្រះ តាមផែនការដែលអង្គការដាក់ឲ្យអនុវត្ត ។ អ្នកទោសខ្លះបានត្រូវសម្លាប់ ព្រោះតែមិនប្រឹងប្រែងធ្វើការ ។ វស្សា និយាយថា កងសន្តិសុខបានសម្លាប់អ្នកទោសរាល់ថ្ងៃដោយចោទប្រកាន់ថាខ្ជិលប្រអូសនឹងការងារ ។ សាវុធ ជាកងសន្តិសុខរបស់មន្ទីរនេះមានតួនាទីបណ្តើរអ្នកទោសចូលនិងចេញពីមន្ទីរសន្តិសុខ និងជាអ្នកសួរចម្លើយក៏មានចរិតសាហាវម្នាក់ដែរ ។ សាវុធ បានបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ននេះ ។

នៅឆ្នាំ១៩៧៨ មន្ទីរសន្តិសុខបន្ទប់ខ្សាច់ និងអ្នកទោសទាំងអស់បានផ្លាស់ប្តូរទីតាំងទៅកាន់កន្លែងមួយផ្សេងទៀតដែលស្ថិតនៅភាគខាងលិចខេត្តស្វាយរៀង ។ តាំងពីពេលនោះមក វស្សា ពុំដែលឃើញអ្នកទោសណាម្នាក់បានវិលត្រឡប់មកស្រុកកំណើតវិញទេ ។

### ស្រុកកំពង់រោទ៍

### ២) មន្ទីរសន្តិសុខគាណ័រ

ផ្ទះជញ្ជាំងបូកដីមួយខ្នងដំបូលប្រក់ស្លឹកត្រោត ស្ថិតនៅភូមិគាណ័រ ឃុំស្វាយតឿ ស្រុកកំពង់រោទ៍ ត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសួរចម្លើយនិងឃុំឃាំងអ្នកទោស ។ អ្នកទោសជាច្រើននាក់ដែលកងសន្តិសុខចាប់មកពីទីកន្លែងផ្សេងៗ ត្រូវកងឈ្លបយកមកដាក់ឃុំឃាំងនៅក្នុងផ្ទះនេះ ហើយរយៈពេល១ខែក្រោយមកអ្នកទោសទាំងនោះត្រូវឆ្នាំគុកនាំយកទៅសម្លាប់ចោល ។ បរិវេណជុំវិញមន្ទីរសន្តិសុខនេះត្រូវកងសន្តិសុខហាមឃាត់ប្រជាជនមិនឲ្យដើរឆ្លងកាត់ឡើយ ។ មន្ទីរសន្តិសុខគាណ័រស្ថិតនៅ

ភូមិតាណ័រ ឃុំស្វាយតឿ ស្រុកកំពង់រោទ៍ ។

នៅឆ្នាំ១៩៧៨ ប្រជាជនមួយចំនួនដែលរស់នៅតាមព្រំដែនវៀតណាម ត្រូវខ្មែរក្រហមចាប់បញ្ជូលមកក្នុងមន្ទីរសន្តិសុខតាណ័រ ដើម្បីឃុំឃាំង សួរចម្លើយ និងសម្លាប់ចោល ។

## ៣) មន្ទីរសន្តិសុខឫស្សីសាញ់


មន្ទីរសន្តិសុខឫស្សីសាញ់

មន្ទីរសន្តិសុខឫស្សីសាញ់ស្ថិតនៅក្នុងភូមិឫស្សីសាញ់ ជាមន្ទីរសន្តិសុខធំជាងគេនៅស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។ មន្ទីរសន្តិសុខនេះមានឃុំឃាំងអ្នកទោសភាគច្រើនជាបុរសដែលអង្គការចោទប្រកាន់ថា បានក្បត់នឹងអង្គការ មានគំនិតចង់បំផ្លាញបដិវត្តន៍ ។ល ។ មន្ទីរសន្តិសុខឫស្សីសាញ់ មានមន្ទីរសន្តិសុខតូចៗជាច្រើនទៀតជាចំណុះដែលមាននាទីសំខាន់ក្នុងការបញ្ជូនអ្នកទោសដែលសួរចម្លើយដឹងថាមានទោសធ្ងន់ មកកាន់មន្ទីរសន្តិសុខឫស្សីសាញ់ ។ វ៉ា វណ្ណា ជាអតីតអ្នកទោសស្រាលម្នាក់ដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខតូចៗចំណុះឲ្យមន្ទីរសន្តិសុខធំឫស្សីសាញ់ បានអះអាងថា អ្នកទោសជាច្រើននាក់ដែលស្នាក់នៅជាមួយគាត់ ត្រូវកម្មាភិបាលខ្មែរក្រហមផ្លាស់ទៅកាន់មន្ទីរសន្តិសុខឫស្សីសាញ់វិញដោយសារមានទោសធ្ងន់ ។

ពេជ្រ សាវឿន ជាប្រធានក្ដោបក្ដាប់រួមលើមន្ទីរសន្តិសុខទាំងតូចទាំងធំ ។ អនុប្រធានរបស់ ពេជ្រ សាវឿន មានឈ្មោះ សាវ៉ន (បច្ចុប្បន្ននៅរស់ឯស្រុកល្វាឯម ខេត្តកណ្ដាល) និងសមាជិកសំខាន់ពីររូបទៀតឈ្មោះ ជួប និង បូ ។ ចំណែក មាស ផន គឺជាកម្មាភិបាលកាន់កាប់បញ្ជីអ្នកទោសទាំងអស់ដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខឫស្សីសាញ់ ។

អ្នកទោសស្ទើរតែទាំងអស់ដែលជាប់នៅក្នុងមន្ទីរសន្តិសុខនេះត្រូវកងឈ្លបនាំយកទៅសម្លាប់ដាក់ក្នុងរណ្ដៅជាច្រើនដែលជីករួចស្រេច ។ រណ្ដៅទាំងនោះត្រូវប្រជាជនជីកកកាយនៅក្រោយឆ្នាំ១៩៧៩ ដើម្បីយកឆ្អឹងមកដាក់តម្កល់ក្នុងបូជនីយដ្ឋានមួយដែលកសាងឡើងនៅក្នុងបរិវេណអតីតមន្ទីរនេះតែម្ដង ។

ប្រជាជនមូលដ្ឋានជាច្រើននាក់ដែលជាសាក្សីបានបញ្ជាក់ពីភាពសាហាវយង់ឃ្នងរបស់ ពេជ្រ សាវឿន, សាវ៉ន និង មាស ផន ថាបានប្រព្រឹត្តអំពើព្រៃផ្សៃមកលើប្រជាជនដែលធ្លាប់រស់នៅស្រុកភូមិជាមួយគ្នានិងប្រជាជនជម្លៀសមកពីទីក្រុងឲ្យស្លាប់យ៉ាងអាណោចអាធ័ម ។ មាស ផន រាយការណ៍ថា គាត់ជាអ្នកប្រគល់បញ្ជីឈ្មោះអ្នកទោសដែលត្រូវសម្លាប់ទៅឲ្យ សាវ៉ន ឬ កែច ដែលជាអ្នកទទួលបញ្ជាផ្ទាល់ពី ពេជ្រ សាវឿន ក្នុងការតាមចាប់និងបោសសម្អាតខ្មាំងអង្គការក្នុងស្រុកកំពង់រោទ៍ទាំងមូល ។ រហូតមកដល់បច្ចុប្បន្ន មាស ផន នៅមានជីវិតនៅឡើយ ហើយកំពុងរស់នៅក្នុងភូមិសំឡី ឃុំសំឡី ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។

ក្នុងកិច្ចសម្ភាសន៍ជាមួយ មាស ផន ដែលសព្វថ្ងៃគាត់មានអាយុ៦១ឆ្នាំ បានប្រាប់ឲ្យដឹងថា ក្នុងរបបខ្មែរក្រហមគាត់ជាប្រធានក្រុមគ្រប់គ្រងនារី១២នាក់មានភារកិច្ចដឹកនាំបង្កបង្កើនផលនិងដាក់បាយជ្រូកនៅឃុំព្រៃធំ ស្រុកកំពង់រោទ៍ បន្ទាប់ពីគាត់ត្រូវអង្គការអនុញ្ញាតឲ្យចេញពីជួរទ័ពនៅឆ្នាំ១៩៧៥ ។ ផន បាននិយាយពីប្រវត្តិរបស់គាត់ថា នៅចុងឆ្នាំ១៩៧៦ គាត់បានផ្លាស់មកធ្វើការខាងកងដឹកជញ្ជូន ហើយនៅឆ្នាំ១៩៧៧ គាត់បានរត់ភៀសខ្លួនទៅរស់នៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។ ក្រោយឆ្នាំ១៩៧៩ ទើបគាត់វិលត្រឡប់ទៅរស់នៅស្រុកកំណើតវិញ ។ ផន បានបដិសេធពីតួនាទីធ្វើការនៅមន្ទីរសន្តិសុខឫស្សីសាញ់ និងការ

កាន់កាប់សៀវភៅបញ្ជីឈ្មោះអ្នកទោសថា «ខ្ញុំអត់មានសៀវភៅអ្នកទោសទេ ព្រោះក្រោយពេលបែកខ្ញុំរត់យករួចតែខ្លួនប៉ុណ្ណោះ គ្មានបានយកអ្វីមកជាមួយឡើយ» ។

ម៉ី សាម៉ុល ជាអតីតអ្នកទោសនិងជាអ្នកបានឃើញសកម្មភាពច្បាស់របស់ មាស ជន កាលពីដើមឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨ដែរ បាននិយាយថា ជន មានតួនាទីពីរ ១) បែងចែកអ្នកទោសតាមកម្រិតធ្ងន់និងស្រាល ២) គ្រប់គ្រងនារីខាងបង្កបង្កើនផលឬគ្រប់គ្រងអ្នកទោសកម្រិតស្រាល ។ ជន ធ្វើការឲ្យមន្ទីរសន្តិសុខសំប៉ូងផង និងជាសេនាធិការឲ្យមន្ទីរសន្តិសុខឫស្សីសាញ់ផង ។ «គាជនជាមនុស្សមិនល្អទេ» គាត់មានសៀវភៅមួយក្បាលសម្រាប់កត់ឈ្មោះអ្នកទោសធ្ងន់និងស្រាល ។ សាម៉ុល បានរៀបរាប់ពីកិនភាគសៀវភៅនោះថា មានក្របរឹង ពណ៌ខ្មៅ និងមានកត់ឈ្មោះអ្នកទោសរាប់រយនាក់ ។ មុំ ពីន ជាប្រជាជនដែលរស់នៅក្បែរផ្ទះរបស់ សាម៉ុល បាននិយាយថា «ទោសធ្ងន់និងស្រាលគឺអាស្រ័យនៅលើមាត់របស់ គាជន តែម្នាក់គត់» ។ សាម៉ុល បញ្ជាក់ថា នៅពេលទទួលលិខិតពី ពេជ្រ សារឿន ប្រធានមន្ទីរសន្តិសុខស្រុកកំពង់រោទ៍ភ្លាម គាជន បានអនុវត្តតាមអត្ថន័យក្នុងលិខិតនោះភ្លាមដែរ ។

នៅចុងឆ្នាំ១៩៧៧ បន្ទាប់ពីខ្មែរក្រហមខាងភូមិភាគនិរតីចូលមកកាន់កាប់ភូមិភាគបូព៌ាទាំងស្រុង ថ្នាក់ដឹកនាំធំៗនៅក្នុងមន្ទីរសន្តិសុខឫស្សីសាញ់បានរត់គេចខ្លួនអស់ ។ មាស ជន ត្រូវប្រជាជនដឹងថា គាត់បានរត់គេចខ្លួនឆ្ពោះមកទិសខាងលិច(អ្នកលឿង)ជាមួយនឹងកាបូបខ្មៅធំមួយដែលទំនងជាមានដាក់ឯកសារពេញ ។ ម៉ី សាម៉ុល អះអាងថា ក្នុងកាបូបខ្មៅនោះពិតជាមានបញ្ជីអ្នកទោស ។ មួយរយៈក្រោយមកមន្ទីរសន្តិសុខឫស្សីសាញ់ត្រូវបាត់បង់អត្ថិភាពព្រោះកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានវាយរុញច្រានមកដល់ ។

## ៤) មន្ទីរសន្តិសុខភូមិត្រពាំងគ្រាច

ភូមិត្រពាំងគ្រាចនាពេលបច្ចុប្បន្ននេះ គឺជាភូមិព្រៃប្រើសកាលពីសម័យខ្មែរក្រហម ។ ភូមិនេះស្ថិតនៅក្នុងឃុំ ស្វាយតាយាន ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ។ ផ្ទះប្រជាជនមួយចំនួននៅក្នុងភូមិនេះត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោសជាប្រជាជនជម្លៀសប្រជាជនមូលដ្ឋាននិងអ្នកទោសផ្សេងទៀតដែលប្រព្រឹត្តខុសនឹងអង្គការវិន័យ ។ អ៊ុក សំ អាយុ៨៧ឆ្នាំ រស់នៅភូមិត្រពាំងគ្រាច ឃុំស្វាយតាយាន ស្រុកកំពង់រោទ៍ មានប្រសាសន៍ថា ផ្ទះរបស់គាត់ត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោសដែលជម្លៀសមកពីទីក្រុងភ្នំពេញ ។ មេភូមិត្រពាំងគ្រាចឈ្មោះ កោក នៅ អាយុ៦២ឆ្នាំ បាននិយាយថាផ្ទះចំនួន៤ខ្នងផ្សេងទៀតក៏ត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងដែរគឺផ្ទះរបស់តា សំ, កោក កុយ, ប្រាជ្ញ ដាន់ និង គង់ ។ តាសំ បានប្រាប់ថាផ្ទះរបស់គាត់មានផ្ទុកអ្នកទោសចំនួនពី៥០ទៅ៦០នាក់ដែលអ្នកទាំងនោះច្រើនតែជាទាហាន ។ នៅពេលថ្ងៃអ្នកទោសទាំងអស់ត្រូវខ្មែរក្រហមចាត់តាំងឲ្យជួយដកស្ទូងប្រជាជនមូលដ្ឋាននិងកាប់ឫស្សី ។ នៅពេលយប់ត្រូវជាប់ខ្នោះនៅតែក្នុងផ្ទះ ។

ពេជ្រ សារឿន ថ្វីដ្បិតតែពុំសូវបាននៅជាប្រចាំនៅក្នុងមន្ទីរសន្តិសុខនេះក៏ដោយ ក៏គាត់ជាអ្នកមើលការខុសត្រូវរួមលើមន្ទីរសន្តិសុខនេះដែរ ។ ប្រធានភូមិបានរៀបរាប់ថា យូរៗទើបឃើញ សារឿន មកមើលមន្ទីរឃុំឃាំងម្តង ហើយពេលគាត់មកដល់គ្មាននរណាម្នាក់ហ៊ានទៅជិតគាត់ឡើយ ។ អ៊ុក សំ ចង្អុលបង្ហាញប្រហោងពីរ-បីនៅជញ្ជាំងផ្ទះរបស់គាត់ ហើយប្រាប់ថានេះជាប្រហោងសម្រាប់ដាក់ខ្នោះ ។

## ស្រុករំដួល

## ៥) មន្ទីរសន្តិសុខទួលពពកវិល



ទួលពពកវិលស្ថិតក្នុងភូមិរោងដំរី ឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង និងមានចម្ងាយ៧គីឡូម៉ែត្រពី សាលាស្រុករំដួល ប៉ែកខាងលិច ។ នៅមុនរបបខ្មែរក្រហមគ្មានប្រជាជនណាម្នាក់ហ៊ានទៅរស់នៅទួលពពកវិលនេះទេ ។ ទីទួលនេះសម្បូរទៅដោយដើមឈើ និងដើមឫស្សីដុះស៊ុបទ្រុប និងមានបឹងយ៉ាងធំមួយផង ។ នៅពេលខ្មែរក្រហមឡើងកាន់អំណាច មន្ទីរសន្តិសុខមួយត្រូវបានកសាងឡើងនៅដីទួលនេះដោយឲ្យឈ្មោះថា មន្ទីរសន្តិសុខទួល ពពកវិល ដែល

ជាមន្ទីរសន្តិសុខធំជាងគេនៅស្រុករំដួល ។ អ្នកទោសជាច្រើននាក់ត្រូវកងសន្តិសុខចាប់យកមកពីគ្រប់ឃុំក្នុងស្រុកនិងពីបណ្តាស្រុកខ្លះក្នុងខេត្តស្វាយរៀងមកដាក់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ ។

ឃឹម វ៉ែន ភេទប្រុស អាយុ៥៨ឆ្នាំ រស់នៅក្នុងឃុំស្វាយចេក ស្រុករំដួល ខេត្តស្វាយរៀង បានប្រាប់ថា អ្នកទោសខ្លះត្រូវខ្មែរក្រហមចាប់មកពីត្រពាំងវែង ភូមិទួលប្រេស ឃុំកំពង់អំពិល និងអ្នកទោសខ្លះទៀតជាប្រជាជនជម្លៀស ។ អ្នកទោសទាំងនេះត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅទីតាំងពិឃាតមួយស្ថិតនៅចម្ងាយប្រហែល៤០០ម៉ែត្រពីមន្ទីរសន្តិសុខ ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានចុះធ្វើប្រវត្តិរូបប្រជាជនទាំងអស់ ។ ក្រោយពីបំពេញប្រវត្តិរូបរួចរាល់ ប្រជាជនមួយចំនួនត្រូវកងឈ្លបចាប់ខ្លួននាំមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខទួលពពកវិល ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ចោល ។ នៅក្នុងឆ្នាំដដែល អ្នកទោសដែលជាប្រជាជនរស់នៅឃុំបុសមន ថ្នាធ្នង់ ជ្រុងពពេល និងកំពង់អំពិល ក៏ត្រូវកងសន្តិសុខបណ្តើរមកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខទួលពពកវិលដែរ ។ ចាប់ពីឆ្នាំ១៩៧៧ អ្នកទោសស្ទើរតែទាំងអស់នៅមន្ទីរសន្តិសុខទួលពពកវិល ត្រូវកងសន្តិសុខសម្លាប់ចោល ។

## ស្រុករមាសហែក




### ៦) មន្ទីរសន្តិសុខព្រៃរំដេង

អតីតមន្ទីរសន្តិសុខព្រៃរំដេងរបស់ខ្មែរក្រហមគឺជាដីចម្ការរបស់ប្រជាជននៅក្នុងភូមិព្រៃរំដេង ឃុំជ្រៃធំ នាពេលបច្ចុប្បន្ននេះ ។ កាលពីជំនាន់ខ្មែរក្រហម មន្ទីរសន្តិសុខព្រៃរំដេងសាងសង់ឡើងជារបៀបជាផ្ទះគៀមផ្ទាល់ដីប្រវែងប្រហែល២០ទៅ៣០ម៉ែត្រ ។ ជិន ដឹម អាយុ៤៨ឆ្នាំ ភេទប្រុស រស់នៅភូមិព្រៃរំដេង ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង បានឲ្យដឹងថា អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខព្រៃរំដេងមានចំនួនប្រហែល១០០នាក់ ហើយក្នុងនោះមានអ្នកទោសស្ត្រីប្រហែល១០នាក់ដែរ ។ អ្នកទោសទាំងអស់ត្រូវខ្មែរក្រហមចោទប្រកាន់ថា មានជាប់ពាក់ព័ន្ធនិន្នាការនយោបាយ សន្តិសម្ព័ន្ធ និងជាខ្មាំងស៊ីរូងផ្ទៃក្នុង ។ ការងាររបស់អ្នកទោសគឺដាំដំឡូង ជីកស្រះ ឃ្វាលក្របី និងធ្វើស្រែ ។ ខ្មែរក្រហមបានសម្លាប់អ្នកទោសនៅពេលដែលអ្នកទាំងនោះធ្វើការមិនបានសម្រេចតាមផែនការដែលបានប្រគល់ឲ្យ ។ ការសម្លាប់អ្នកទោសមួយលើកៗ គឺមានតែម្នាក់ទៅ៥នាក់ប៉ុណ្ណោះ ។ សមមិត្ត សុភា គឺជាប្រធានមន្ទីរសន្តិសុខព្រៃរំដេង ។ ក្រោយឆ្នាំ១៩៧៩ ឈ្មោះនេះបានបាត់មុខរហូតមិនដឹងទៅទីណា ។

### ៧) មន្ទីរសន្តិសុខវត្តស្វាយទន្ទឹម

មន្ទីរសន្តិសុខវត្តស្វាយទន្ទឹម ស្ថិតនៅភូមិស្វាយទន្ទឹម ឃុំត្រពាំងស្តៅ ស្រុករមាសហែក ខេត្តស្វាយរៀង ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខនេះឡើងដោយយកបរិវេណខាងក្នុងវត្តធ្វើជាមន្ទីរសួរចម្លើយ និងខាងក្រៅរបងវត្តប៉ែកខាងមុខធ្វើជាមន្ទីរឃុំឃាំង ។ រដ្ឋអំណាចបដិវត្តន៍បានហាមឃាត់ប្រជាជនមិនឲ្យដើរឆ្លងកាត់មន្ទីរសន្តិសុខឡើយ ។ គង់ ដឹម អាយុ៦៧ឆ្នាំ ដែលមានមុខរបរជាជាងឈើ រស់នៅភូមិស្វាយទន្ទឹម ឃុំត្រពាំងស្តៅ ស្រុករមាសហែក ខេត្តស្វាយរៀង បានឃើញកងសន្តិសុខបណ្តើរអ្នកទោសប្រមាណពី៥០ទៅ៦០នាក់ចូលមន្ទីរសន្តិសុខទាំងថ្ងៃ ។ អ្នកទោសម្នាក់ៗត្រូវកងសន្តិសុខចងភ្ជាប់គ្នាជាខ្សែៗ ព្រមទាំងយកក្រណាត់រុំមុខជិតជង ។ ឃី សាមុត អាយុ៦០ឆ្នាំ ឃុំត្រពាំងស្តៅបានដឹងយ៉ាងច្បាស់ថា អ្នកទោសដែលកងសន្តិសុខបណ្តើរមកនិងអ្នកទោសដែលជាប់នៅខាងក្នុងមន្ទីរសន្តិសុខសុទ្ធតែត្រូវខ្មែរក្រហមចាប់បញ្ជូនមកពីសហករណ៍តាមឃុំនានាក្នុង

ស្រុករមាសហែក ស្រុកស្វាយរៀងនិងស្រុករំដួល ។

ឆើត ដែលជាប្រធានមន្ទីរសន្តិសុខវត្តស្វាយទន្ទឹម បានចាត់តាំងឲ្យកម្មាភិបាលរបស់ខ្លួននិងដែលធ្លាប់បម្រើការនៅខាងក្នុងមន្ទីរសួរចម្លើយទទួលភារកិច្ចតែម្យ៉ាងគត់ គឺសួរចម្លើយអ្នកទោសដែលទើបមកដល់ថ្មី ។ បន្ទាប់ពីសួរចម្លើយ អ្នកទោសត្រូវបញ្ជូនទៅឃុំឃាំង ហើយមួយចំនួនត្រូវនាំយកទៅសម្លាប់ចោល ។ អ្នកទោសដែលនៅជាប់ក្នុងមន្ទីរឃុំឃាំងត្រូវកងសន្តិសុខបណ្ដើរឲ្យទៅកាស់គល់ឈើ ជីកប្រឡាយ និងធ្វើកិច្ចការផ្សេងៗទៀត ។

ចាប់ពីចុងឆ្នាំ១៩៧៧ អ្នកទោសទាំងអស់ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ចោល ហើយចាប់អ្នកទោសថ្មីៗមកដាក់ឃុំឃាំងបន្តទៀត ។ នៅឆ្នាំ១៩៧៨ ការសម្លាប់បានកើនឡើងលើសពីឆ្នាំមុនៗ ។ សាមុត និយាយដូច្នេះថា «[ការសម្លាប់] បានជាកើនឡើងច្រើនជាងលើកមុន ព្រោះជាការសម្លាប់ផ្ដាច់ព្រ័ត្រ» ។

ក្រោយឆ្នាំ១៩៧៩ គង់ ជឹម បានឃើញខ្មោះយ៉ាងច្រើននៅក្នុងបរិវេណមន្ទីរសន្តិសុខវត្តស្វាយទន្ទឹមនេះ ក៏ប៉ុន្តែបច្ចុប្បន្នសម្ភារៈទាំងនេះត្រូវប្រជាជនបំផ្លាញចោល ហើយសំណង់មន្ទីរឃុំឃាំងត្រូវរុះរើបន្សល់ទុកនូវដីល្ហល្ហេវដែលប្រជាជនអាចធ្វើស្រែបាននៅរដូវវស្សា ។

### ៨) មន្ទីរសន្តិសុខវាលស្វាយ

មន្ទីរសន្តិសុខវាលស្វាយ ស្ថិតនៅក្នុងភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក ខេត្តស្វាយរៀង ។ មន្ទីរនេះបង្កើតឡើងនៅឆ្នាំ១៩៧៥ សម្រាប់ឃុំឃាំងអ្នកទោសដែលកងសន្តិសុខចាប់មកពីកន្លែងផ្សេងៗក្នុងខេត្តស្វាយរៀង ។ អ្នកទោសដែលមកជាប់មុនគេគឺជាប្រជាជនជម្លៀស ។ ប្រជាជនទាំងនេះត្រូវកងសន្តិសុខសម្លាប់ទាំងអស់ ហើយយកអ្នកទោសថ្មីមកដាក់ជំនួសវិញ ។ ចាន់ ដូ អាយុ៣៨ឆ្នាំ និង មោង អ៊ិត រស់នៅក្នុងភូមិស្រះ ឃុំជ្រៃធំ ស្រុករមាសហែក ធ្លាប់បានឃើញសន្តិសុខខ្មែរក្រហមក្មេងៗបណ្ដើរអ្នកទោសមកកាន់មន្ទីរសន្តិសុខវាលស្វាយ ដោយម្នាក់ស្ពាយកាំភ្លើងដើរខាងមុខនិងម្នាក់ទៀតដើរខាងក្រោយ ។

ចាប់ពីឆ្នាំ១៩៧៦ដល់ឆ្នាំ១៩៧៨ អ្នកទោសដែលនាំដាក់នៅមន្ទីរនេះជាប្រជាជនដែលមានជាប់ខ្សែស្រឡាយចិននិងវៀតណាម និងយុទ្ធជនខ្មែរក្រហមដែលខ្មែរក្រហមគ្នាឯងចាប់មក ។ នៅក្នុងឆ្នាំ១៩៧៨ កម្មាភិបាលខ្មែរក្រហមភូមិភាគបូព៌ាត្រូវកម្មាភិបាលខាងភូមិភាគនិរតីចាប់ខ្លួនជាបន្តបន្ទាប់ដោយចោទថាក្បត់អង្គការបដិវត្តនិងចូលដៃចូលជើងជាមួយយួន ។ កម្មាភិបាលខាងភូមិភាគបូព៌ាជាច្រើននាក់ត្រូវនាំយកទៅដាក់នៅមន្ទីរសន្តិសុខវាលស្វាយនិងមន្ទីរសន្តិសុខវត្តស្វាយទន្ទឹមនេះ ។ ភឹម សាក់ បានរៀបរាប់ប្រាប់ថា គាត់ជាយុទ្ធជនខ្មែរក្រហមម្នាក់ធ្វើការក្នុងកងពលលេខ៣ ខាងបក្ខពួក សោភឹម ដែលត្រូវកងសន្តិសុខចាប់ខ្លួនមកដាក់មន្ទីរសន្តិសុខវាលស្វាយនៅដើមឆ្នាំ១៩៧៨ ដែលមានសមមិត្ត ភ័ណ ជាប្រធានមន្ទីរសន្តិសុខ និង សំអេន ជាអនុប្រធាន ។ អ្នកទោសទាំងអស់ត្រូវនាំយកទៅសម្លាប់នៅទួលមួយចម្ងាយប្រហែល៣០០ម៉ែត្រពីមន្ទីរសន្តិសុខវាលស្វាយ ។


មន្ទីរសន្តិសុខវត្តស្វាយទន្ទឹម

សាក់ បានកត់សម្គាល់ថានៅពេលកងសន្តិសុខផ្ដល់អាហារឲ្យអ្នកទោសណាម្នាក់ហូបគ្រប់គ្រាន់ អ្នកទោសរូបនោះប្រាកដ ជាត្រូវនាំយកទៅសម្លាប់ក្រោយពេលបរិភោគរួចមិនខាន ។ តាមធម្មតាអ្នកទោសមិនដែលបានទទួលរបបអាហារហូបគ្រប់គ្រាន់ឡើយ ។ «អ្នកទោសគ្រប់គ្នា

*ភិតភ័យពេលដែលខ្មែរក្រហមដាក់បាយឲ្យហូបនៅផ្ទាល់ដី ព្រោះថាសកម្មភាពនេះជាសញ្ញាមួយបញ្ជាក់យ៉ាងច្បាស់ថា ពិតជាមានការសម្លាប់មនុស្ស ក្រោយពេលហូបបាយរួចមិនខាន» ។*

## ស្រុកស្វាយរៀង

### ៩) មន្ទីរសន្តិសុខធ្លក

*មន្ទីរសន្តិសុខវត្តធ្លកស្ថិតនៅភូមិធ្លក ឃុំធ្លក ស្រុកស្វាយរៀង ខេត្តស្វាយរៀង និងមន្ទីរធំជាងគេមួយក្នុងស្រុកស្វាយរៀង ។*

*សង្ឃមួយអង្គដែលគង់នៅវត្តធ្លកបានមានសង្ឃដីកាថា នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានកសាងមន្ទីរសន្តិសុខធ្លកនេះឡើងសម្រាប់ឃុំឃាំងអ្នកទោសបន្ទាប់ពីព្រះសង្ឃទាំងអស់ត្រូវអង្គការបង្ខំឲ្យផ្សឹកដើម្បីធ្វើការងារផ្សេងៗដូចប្រជាជនធម្មតា ។ អ្នកទោសជាច្រើនដែលខ្មែរក្រហមចោទប្រកាន់ពីបទក្បត់អង្គការត្រូវបានសម្លាប់ចោលនៅទីនេះ រួចបោះចូលទៅក្នុងរណ្តៅ ។ មន្ទីរសន្តិសុខធ្លកនេះមានឃុំឃាំងអ្នកទោសជាច្រើនដែលកងឈ្លបចាប់មកពីឃុំទាំងប៉ែតសិបក្នុងខេត្តស្វាយរៀង ។ ប្រធានមន្ទីរសន្តិសុខធ្លកមានឈ្មោះ សុខ សារ៉េត ក្រោយមក សារ៉េត បានត្រូវស្លាប់នៅក្នុងគុកទួលស្លែង ។*

*បច្ចុប្បន្នមន្ទីរឃុំឃាំងពុំមានបន្សល់ទុកអ្វីឡើយ ប៉ុន្តែនៅក្បែរបរិវេណមន្ទីរសន្តិសុខនិងជិតវត្តធ្លក មានស្លាកស្នាមរណ្តៅកប់សាកសពរួមចំនួន៤១រណ្តៅ ហើយក្នុងចំណោមនោះមានតែរណ្តៅបីប៉ុណ្ណោះ ដែលប្រជាជនគាស់យកឆ្អឹងសាកសពបានចំនួន៩៣២នាក់ដាក់តម្កល់ទុកក្នុងសារមន្ទីរធ្លក ។*

### ១០) មន្ទីរសន្តិសុខវត្តបឹងវ៉ែ

*មន្ទីរសន្តិសុខវត្តបឹងវ៉ែ ស្ថិតនៅក្នុងភូមិបឹងវ៉ែ ឃុំក្រោលគោ ស្រុកស្វាយរៀង ជាមន្ទីរឃុំឃាំងលំដាប់ទី២នៅក្នុងខេត្តស្វាយរៀង ។ ព្រះសង្ឃទាំងអស់ត្រូវបង្ខំឲ្យផ្សឹកនិងសម្លាប់ចោលមួយចំនួនចំពោះសង្ឃដែលប្រឆាំងនឹងបទបញ្ជា ។ បច្ចុប្បន្នព្រះចៅអធិការវត្តបានប្រើប្រាស់កុដិដែលខ្មែរក្រហមយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោសធ្វើជាកន្លែងគង់នៅ និង មន្ទីររដ្ឋបាលរបស់វត្តទាំងមូល ។ កុដិមួយនេះត្រូវពុទ្ធបរិស័ទជួសជុលឡើងវិញនៅឆ្នាំ១៩៨០ ។ សារមន្ទីរនៅក្នុងបរិវេណវត្តនេះមានតម្កល់អដ្ឋិធាតុជនរងគ្រោះ៣៣០នាក់ដែលគាស់ចេញពីរណ្តៅកប់សាកសពរួមមួយចំនួនក្នុងចំណោមរណ្តៅសាកសពទាំងអស់២៨ដែលស្ថិតនៅក្បែរៗនោះកាលពីឆ្នាំ១៩៨២ ។*

*ជនរងគ្រោះដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរឃុំឃាំងបឹងវ៉ែភាគច្រើនជាប្រជាជនថ្មីដែលកងឈ្លបនាំមកពីខេត្តនិងក្រុងនានា ។ ទិត ណាង អាយុ៦១ឆ្នាំ បាននិយាយប្រាប់ពីការចាប់ជនរងគ្រោះមកឃុំឃាំងថា «ដំបូងខ្មែរក្រហមចាប់ប្រជាជនថ្មីមកពីភ្នំពេញ ប៉ុន្តែក្រោយមកបានចាប់មនុស្សភាគច្រើនដែលជាយុទ្ធជនស្ថិតក្រោមការដឹកនាំរបស់ សោ ភឹម ប្រធានភូមិភាគបូព៌ាដែលបះបោរប្រឆាំងបដិវត្តន៍» ។*

*អ្នកទោសត្រូវឆ្នាំគុកសួរចម្លើយនិងធ្វើទណ្ឌកម្ម ។ ណាង និយាយថា គាត់បានឃើញខ្មែរក្រហមបណ្តើរអ្នកទោសចេញពីមន្ទីរឃុំឃាំងឆ្ពោះទៅទីតាំងសម្លាប់នៅក្រោយអគារមួយក្នុងបរិវេណវត្តនេះ ។ «ខ្ញុំមើលឃើញសកម្មភាពនេះច្បាស់ណាស់ ពីព្រោះយប់នោះខែរះភ្លឺច្បាស់ ហើយផ្ទះរបស់ខ្ញុំនៅក្បែរនេះដែរ» ។ សុខ ចេង ធ្វើការនៅនាយកដ្ឋានវប្បធម៌ និងវិចិត្រសិល្បៈស្រុកធ្លាប់បានមកកាន់បរិវេណវត្តបឹងវ៉ែមួយភ្លែតដែរបន្ទាប់ពីថ្ងៃរំដោះភ្លាម ហើយបានសង្កេតឃើញថានៅលើជញ្ជាំងទាំងអស់នៅមានស្នាមប្រឡាក់ឈាម ខួរ និងសក់មនុស្សនៅឡើយ ។*

## ស្រុកស្វាយទាប

### ១១) មន្ទីរសន្តិសុខវត្តក្តីរំដួល

*វត្តក្តីរំដួលស្ថិតនៅក្នុងភូមិអកនាគ ឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ វត្តនេះត្រូវខ្មែរក្រហមប្រើប្រាស់ជាមន្ទីរសន្តិសុខ ។ មាន បានប្រាប់ថា ពីលើចុងត្នោតគាត់មើលឃើញខ្មែរក្រហមបណ្តើរអ្នកទោសជាជួរៗឆ្ពោះទៅកាន់វាលស្រែមួយស្ថិតនៅប៉ែកខាងក្រោយវត្តក្តីរំដួល ប៉ុន្តែគាត់ពុំដែលឃើញអ្នកទាំងនោះត្រឡប់មកវិញឡើយ ។ មាន បានពោលពាក្យចចាមអារ៉ាមថា អ្នកទោសទាំងនោះត្រូវកងឈ្លបសម្លាប់អស់ទៅហើយ ។ នៅក្នុងមន្ទីរសន្តិសុខ អ្នកទោសត្រូវឆ្នាំគុកដាក់ខ្នោះជើងភ្ជាប់នឹងរនុកដែកមួយ ។ អ្នកទាំងនេះភាគច្រើនជាមន្ត្រីរដ្ឋការខេត្ត ។ ចំពោះអ្នកទោសស្ត្រីវិញ ខ្មែរក្រហមចាប់សម្រាតសម្លៀកបំពាក់ចេញអស់មុននឹងសម្លាប់ ។*

**ផេង ពង្សរ៉ាស៊ី**

# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ជំពូកទី៨
## ប្រព័ន្ធសន្តិសុខ

### ១) មន្ទីរសន្តិសុខ

ទោះបីជាវិសុទ្ធកម្មនៅភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨ ជាព្រឹត្តិការណ៍ព្រៃផ្សៃបំផុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ប្រជាជនរាប់សែននាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន ហើយក្នុងករណីជាច្រើនត្រូវបានសម្លាប់ចោលនៅតាមតំបន់ផ្សេងៗទៀតក្នុងទូទាំងប្រទេស ។ ប្រព័ន្ធសន្តិសុខរបស់ខ្មែរក្រហមដែលរួមមានជិតពីររយគុកត្រូវបានបង្កើតឡើងស្ទើរគ្រប់កន្លែងទាំងអស់លើផ្ទៃប្រទេស ។ ខ្មែរក្រហមបានហៅគុកទាំងនេះថា "មន្ទីរសន្តិសុខ" ជាជាងការប្រើពាក្យ"គុក" ។

មន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានរៀបចំឡើងជាប្រាំថ្នាក់ ។ មន្ទីរសន្តិសុខទាំងនេះត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំង កន្លែងសួរចម្លើយ និងកន្លែងសម្លាប់ ។ អ្នកទោសដែលជាប់ឃុំក្នុងគុកបីថ្នាក់ដំបូង (ថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ) ភាគច្រើនជាអតីតទាហាននិងមន្ត្រីរដ្ឋការស៊ីវិលរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ហើយអ្នកទោសផ្សេងទៀតគឺជាប្រជាជនសាមញ្ញដែលត្រូវបានចោទប្រកាន់ពីបទលួចរបស់របរឬចំណីអាហារ រត់ចោលកន្លែង ឬនិយាយអាក្រក់ពីអង្គការ ។ មន្ទីរសន្តិសុខថ្នាក់ភូមិភាគធ្វើការឃុំឃាំងអ្នកទោសរាប់ពាន់នាក់ ។ មន្ទីរសន្តិសុខទាំងនេះប្រើសម្រាប់ ឃុំឃាំង យុទ្ធជនខ្មែរក្រហមនិងក្រុមគ្រួសារ ហើយនិងអ្នកដែលជាប់ចោទពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុង


ក្រុមកុមារ

ភូមិភាគ ។ មន្ទីរសន្តិសុខថ្នាក់ខ្ពស់បំផុតគឺជាមន្ទីរសន្តិសុខមជ្ឈិមនៅភ្នំពេញដែលមានឈ្មោះសម្ងាត់ថា "មន្ទីរស-២១" ។ អ្នកទោសនៅក្នុងមន្ទីរស-២១ស្ទើរតែទាំងអស់គឺជាកម្មាភិបាល និងកងទ័ពខ្មែរក្រហមដែលជាប់ចោទពីបទក្បត់បដិវត្តន៍ ។

នៅមន្ទីរសន្តិសុខថ្នាក់ក្រោម ការធ្វើទណ្ឌកម្មមិនសូវជាធ្ងន់ធ្ងរប៉ុន្មានទេ ដោយសារតែជាទូទៅអ្នកទោសត្រូវបានបញ្ជូនពីមន្ទីរសន្តិសុខទៅជំរំពលកម្មដែលនៅទីនោះអ្នកទោសត្រូវបានចាត់តាំងឲ្យសាងសង់ផ្ទះ ដាំបន្លែបង្ការ និងចម្អិន ម្ហូបអាហារ ។ អ្នកទោសជាច្រើនដែលជាប់ឃុំក្នុងមន្ទីរសន្តិសុខទាំងនេះត្រូវបានដោះលែងវិញនៅមុនឆ្នាំ១៩៧៦ ។ ប៉ុន្តែ ចាប់តាំងពីឆ្នាំនោះមក នៅថ្នាក់តំបន់និងថ្នាក់ស្រុកស្ទើរតែគ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងឡើយ ហើយស្ទើរតែគ្មានអ្នកទោសណាម្នាក់អាចរួចរស់ជីវិតពីមន្ទីរស-២១ដែរ ។

## ៧) ខ្មាំងរបស់អង្គការ

ខ្មែរក្រហមចង់ឲ្យបដិវត្តន៍របស់ខ្លួននិងប្រជាជនកម្ពុជាទាំងអស់មានភាពស្អាតស្អំ ។ ប្រជាជនទាំងអស់ត្រូវតែស្អាតស្អំទាំងសតិអារម្មណ៍និងប្រវត្តិរូប ។ កសិករក្រីក្រត្រូវខ្មែរក្រហមចាត់ទុកថាជាអ្នកបដិវត្តន៍ដែលស្អាតស្អំបំផុត ។ ខ្មែរក្រហមមិនទុកចិត្តអ្នកផ្សេងក្រៅពីកសិករក្រទាំងនេះឡើយ ។ ប្រជាជនដែលបានប្រព្រឹត្តកំហុសតូចតាច ដូចជាការរអ៊ូរទាំអំពីការធ្វើការលំបាកឬក៏ការលួចម្ហូបអាហារ ត្រូវបានចាត់ទុកថាជាខ្មាំងរបស់រដ្ឋ និងជាញីកញាយបានក្លាយទៅជាមុខសញ្ញាដែលត្រូវយកទៅសម្លាប់ចោល ។ មេដឹកនាំខ្មែរក្រហមបាន បែងចែកសត្រូវរបស់ខ្លួនជាពីរប្រភេទ គឺ "សត្រូវខាងក្នុង" និង "សត្រូវខាងក្រៅ" ។

***សត្រូវខាងក្នុង*** គឺជា"ប្រជាជនថ្មី" ឬ "ប្រជាជន១៧មេសា" និងអ្នកដែលធ្លាប់ធ្វើការក្នុងរបបចាស់ ។ អ្នកទាំងនេះត្រូវខ្មែរក្រហមចាត់បញ្ចូលជាពួកមូលធននិយម និងពួកសក្តិភូមិនិយម ។ ជំពូកប្រជាជនទាំងនេះក៏រួមបញ្ចូលទាំងអ្នកដែលមិនមានដើមកំណើតជាជនជាតិខ្មែរផងដែរ ។ សត្រូវខាងក្នុងទាំងនេះធ្វើឲ្យមជ្ឈិមបក្សមានការខ្វល់ខ្វាយជាងអ្វីៗទាំងអស់ ។ ក្រុមដែលខ្មែរក្រហមចាត់



យោធាខ្មែរក្រហមនៅវិមានឯករាជ្យ

ទុកថាជាសត្រូវខាងក្នុងរួមមានៈ

***អ្នករដ្ឋការរបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ*** ៖ ក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានធ្វើការសម្លាប់រង្គាលអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរជាច្រើនពាន់នាក់ ។ ខ្មែរក្រហមធ្វើការសម្លាប់ចាប់ពីថ្នាក់ដឹកនាំជាន់ខ្ពស់រហូតដល់កូនទាហាន ។ អ្នកដែលធ្លាប់បម្រើឲ្យរដ្ឋាភិបាលសាធារណរដ្ឋខ្មែរទាំងប៉ុន្មានសុទ្ធតែជាមុខសញ្ញាដែលត្រូវសម្លាប់ ។ ជាទូទៅ សូម្បីតែសមាជិកគ្រួសារនិងសាច់ញាតិរបស់អ្នករដ្ឋការទាំងនេះក៏ត្រូវសម្លាប់ដែរ ។ ទោះជាយ៉ាងនេះក្តី ជាសំណាងល្អអតីតទាហាននិងអ្នករដ្ឋការរាប់ពាន់នាក់បានខិតខំលាក់អត្តសញ្ញាណរបស់ខ្លួន ហើយបានរួចរស់ជីវិតមួយគ្រា ឬរួចរស់ជីវិតរហូតដល់ថ្ងៃដួលរលំរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

***ក្រុមជនជាតិភាគតិច*** ៖ ខ្មែរក្រហមចង់បានជនជាតិខ្មែរដែលមិនមានជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាលចាស់ក្នុងការអនុវត្តផែនការបដិវត្តន៍របស់ខ្លួន ។ ជនជាតិភាគតិចផ្សេងទៀតដែលមិនទទួលបានការទុកចិត្ត ឬមានការសង្ស័យពី បក្សត្រូវបានធ្វើទុក្ខបុកម្នេញ ។

**ជនជាតិភាគតិចតំបន់ភ្នំ** ៖ មុនពេលឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ មេដឹកនាំខ្មែរក្រហមភាគច្រើនធ្លាប់បានរស់នៅក្នុងចំណោមជនជាតិភាគតិចតំបន់ភ្នំក្នុងភូមិភាគឦសាន ។ មេដឹកនាំខ្មែរក្រហមទាំងនេះមានការជឿទុកចិត្តលើជនជាតិភាគតិចតំបន់ភ្នំទាំងនេះណាស់ ដោយយល់ឃើញថា ជនជាតិទាំងនេះមានចិត្តស្មោះត្រង់ ។ ជនជាតិភាគតិចមួយចំនួនបានក្លាយជាកងការពាររបស់ ប៉ុល ពត ទៀតផង ។ ប៉ុន្តែទោះបីជារបបនេះបានអះអាងថាស្រឡាញ់ស្មោះស្ម័គ្រនិងជឿទុកចិត្តលើជនជាតិភាគតិចតំបន់ភ្នំយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមបានចាប់ផ្តើមធ្វើការផ្លាស់ទីលំនៅជនជាតិភាគតិចក្នុងខេត្តមណ្ឌលគិរីឲ្យទៅរស់នៅផ្តុំគ្នាក្នុងស្រុកកោះញែក នៅដើមឆ្នាំ១៩៧២ ដែលបណ្តាលឲ្យប្រជាជនស្លាប់ជាច្រើន ។ អ្នកដែលជំទាស់មិនព្រមទៅ ត្រូវបានសម្លាប់ចោល ។

ផ្សុស ប្រែ ជនជាតិព្នងរស់នៅក្នុងខេត្តមណ្ឌលគិរី រៀបរាប់ពីស្ថានភាពគ្រួសាររបស់គាត់បន្ទាប់ពីត្រូវបង្ខំឲ្យផ្លាស់ប្តូរទីលំនៅក្នុងរបបខ្មែរក្រហមថា ៖

*ក្មួយស្រីរបស់ខ្ញុំអាយុ១៥ឆ្នាំត្រូវខ្មែរក្រហមបាញ់សម្លាប់ដោយសារតែវាស្រែកថាវាមិនចង់ទៅរស់នៅកន្លែងផ្សេង ។ ខ្ញុំត្រូវបានបំបែកចេញពីគ្រួសារឲ្យទៅធ្វើស្រែចម្ការនៅកន្លែងជាច្រើន ។ នៅក្នុងស្រុកកោះញែក ប្រជាជនធ្វើការទាំងថ្ងៃទាំងយប់ដោយទទួលបានរបបអាហារតិចតួចនិងមានការហត់ហេវអស់កម្លាំងជាខ្លាំង ។ កូនស្រីរបស់ខ្ញុំដែលទើបតែឆ្លងទន្លេហើយមិនមានអ្វីហូប ក្រៅតែពីក្តួចនោះទេ ដូច្នេះហើយប្តីរបស់វាទៅរកអង្ករបានប្រាំបីកំប៉ុងនិងមាន់មួយពីភូមិផ្សេង ។ ប្រធានឃុំបានចោទកូនប្រសាខ្ញុំថាហូបឯកជន ។ សមាជិកគ្រួសារកូនស្រីខ្ញុំទាំងអស់ត្រូវអង្គការចាប់ខ្លួន ។ ក្នុងភូមិឡាំទឹក ប្រជាជនពីរនាក់ត្រូវបានចាប់យកទៅសម្លាប់ចោល ព្រោះពួកគេបានហូបផ្ទិតឃ្មុំដោយមិនចែកអ្នកភូមិ ។*

**ជនជាតិភាគតិចចាម** ៖ ខ្មែរក្រហមបានបង្ខំឲ្យជនជាតិចាមចាកចេញពីលំនៅឋានរបស់ខ្លួន ហើយទៅរស់នៅលាយឡំគ្នាជាមួយសហគមន៍ជនជាតិខ្មែរ ។ ជនជាតិចាមត្រូវបានហាមប្រាមមិនឲ្យនិយាយភាសាចាមឬគោរពបូជាសាសនាអ៊ិស្លាម ។ ខ្មែរក្រហមបានសម្លាប់មេដឹកនាំសាសនាអ៊ិស្លាម(ហាគីម) និងជនជាតិចាមទាំងឡាយណាដែលត្រូវបានសង្ស័យថាធ្វើការប្រឆាំងនឹងគោលនយោបាយរបស់រដ្ឋា-



ការហូបចុកនៅក្នុងផ្ទះបាយរួម

ភិបាលអស់ជាច្រើន ។ ដាងនេះទៅទៀត ខ្មែរក្រហមបានបង្ខំឲ្យជនជាតិចាមហូបសាច់ជ្រូកដែលផ្ទុយទៅនឹងការហាមប្រាមរបស់សាសនាអ៊ីស្លាម ។ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ជនជាតិចាមរាប់ម៉ឺននាក់បានស្លាប់ដោយការសម្លាប់ ជំងឺ ការអត់ឃ្លាននិងការធ្វើការហួសកម្លាំង ។

**ជនជាតិភាគតិចវៀតណាម** ៖ ជនជាតិវៀតណាមទាំងអស់ត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥ ។ ជនជាតិវៀតណាមមួយចំនួនដែលបានរៀបការជាមួយជនជាតិខ្មែរបានរស់នៅក្នុងប្រទេសកម្ពុជាបន្តទៅទៀត ។ ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាប់ផ្តើមសម្លាប់ជនជាតិវៀតណាមដែលសេសសល់ទាំងនេះយ៉ាងរង្គាល ហើយមានតែមួយចំនួនតូចប៉ុណ្ណោះដែលបានរួចរស់ជីវិត ។ ជនជាតិភាគតិចវៀតណាមត្រូវបានសម្រាំងយកទៅសម្លាប់ដោយសារតែខ្លួនជាជនជាតិវៀតណាម ។

**ជនជាតិភាគតិចចិន** ៖ សមាជិកនៃសហគមន៍នេះដែលជាអ្នកជំនួញនិងជាសហគ្រិនក្រុមហ៊ុនក៏ត្រូវបានបង្ខំឲ្យធ្វើដំណើរទៅជនបទទៅធ្វើការងារកសិកម្មដែរ ។ ជនជាតិចិនត្រូវខ្មែរក្រហមប្រព្រឹត្តមកលើយ៉ាងឃោរឃៅ នៅពេលដែលអ្នកទាំងនេះមិនអាចទ្រាំទ្រនឹងការងារលំបាកបាន ។ ប៉ុន្តែជនជាតិចិន មិនត្រូវបានសម្រាំងជ្រើសរើសដើម្បីយកទៅសម្លាប់ចោលទេ ។

**បញ្ញវន្ត** ៖ មេដឹកនាំខ្មែរក្រហមដែលមួយចំនួនជាបញ្ញវន្តបានចាត់ទុកបញ្ញវន្តដទៃទៀតថាជាសត្រូវចម្បងរបស់ប្រទេស និងជាជំពូកជនពុករលួយដែលមេដឹកនាំទាំងនេះយល់ថាជាអ្នកដែលធ្វើឲ្យប្រទេសជាតិក្លាយទៅជាអាយ៉ងរបស់បរទេស ។ បញ្ញវន្តជាច្រើនបានក្លាយជាមុខសញ្ញាសម្រាប់ការសម្លាប់ ។ អ្នកដែលអាចត្រូវចាត់បញ្ចូលក្នុងជំពូកអ្នកចេះដឹងត្រូវតែធ្វើពុតជាមនុស្សល្ងង់ខ្លៅ ។ បញ្ញវន្តអាចរួចរស់ជីវិតបាន លុះត្រាណាតែអ្នកទាំងនោះអាចលាក់បាំងចំណេះវិជ្ជានិងអាជីពការងាររបស់ខ្លួន ។ សាស្ត្រាចារ្យ និងនិស្សិតមហាវិទ្យាល័យរាប់ពាន់នាក់ត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងសៀវភៅ "ជីវិតកូនថ្ងៃ កូនត្រូវតែរស់" វិស្វករ ពិន យ៉ាថៃ បានរៀបរាប់ពីបទពិសោធន៍ដែលលោកបានជួបប្រទះក្នុងរបបខ្មែរក្រហម ។ ក្នុងអំឡុងពេលជម្លៀសឆ្នាំ១៩៧៥ គ្រួសាររបស់លោកដែលមានសមាជិកដប់ប្រាំបីនាក់ ត្រូវបានបង្ខំឲ្យផ្លាស់ទីតាំងជាច្រើនលើក ដែលនៅចុងក្រោយត្រូវបានបញ្ជូនទៅខេត្តពោធិសាត់ ។ លោក ពិន យ៉ាថៃ ជាមនុស្សតែម្នាក់គត់ក្នុងគ្រួសារដែលនៅរស់រានមានជីវិត ហើយបានរត់គេចទៅប្រទេសថៃនាដើមឆ្នាំ១៩៧៧ ។ មូលហេតុមួយដែលធ្វើឲ្យ ពិន យ៉ាថៃ រួចរស់ជីវិតបាននោះគឺដោយសារលោកអាចលាក់បាំងវិជ្ជាជីវៈរបស់លោក ។ លោកបានរៀបរាប់ដូច្នេះថា ៖

*ថ្ងៃមួយនៅភូមិវាលវង់ក្នុងខេត្តពោធិសាត់ប្រធានភូមិបានរៀបចំប្រជុំនយោបាយដ៏គួរឲ្យធុញទ្រាន់ម្តងទៀត ។ គាត់បានប្រកាសថា សម្តេចព្រះនរោត្តម សីហនុ បានយាងនិវត្តចូលប្រទេសវិញហើយ ហើយកំពុងតែរៀបចំរដ្ឋាភិបាលថ្មីមួយ ដូច្នេះអង្គការសូមស្នើឲ្យអ្នកឯកទេស បញ្ញវន្ត អតីតនាយ ទាហាន វេជ្ជបណ្ឌិត វិស្វករ និងនិស្សិត អញ្ជើញមកចុះឈ្មោះក្នុងបញ្ជីពិសេសមួយ ។ មនុស្សប្រហែលសែសិបនាក់បានលើកដៃ ដោយរួមទាំងអតីត*



កម្មាភិបាលខ្មែរក្រហមវិលត្រឡប់មកពីធ្វើការនៅវាលស្រែ

ទាហានដែលបានខិតខំលាក់អត្តសញ្ញាណរបស់ខ្លួនតាំងពីយូរមកហើយ ។ ខ្ញុំមានការរារែកក្នុងចិត្ត ប៉ុន្តែខ្ញុំអាចទប់អារម្មណ៍ខ្លួនឯងបានហើយមិនបានលើកដៃទឹងគេទេ ។ ចាប់តាំងពីពេលនោះមក យើងមិនដែលបានទទួលដំណឹងអ្វីពីអ្នកទាំងនោះទេ ។ អ្នកភូមិបានខ្សឹបខ្សៀវប្រាប់គ្នាថា "អតីតមន្ត្រីជាន់ខ្ពស់និងអ្នកឯកទេសទាំងនោះត្រូវខ្មែរក្រហមសម្លាប់អស់ទៅហើយ" ។

***អ្នកដែលខ្មែរក្រហមចោទថាជាជនក្បត់ជាតិ*** : កម្មាភិបាលខ្មែរក្រហមជាច្រើននាក់ត្រូវបានចោទថាក្បត់បដិវត្តន៍និងចូលដៃជាមួយវៀតណាម ។ ប្រជាជនសាមញ្ញដែលធ្វើខុសបន្តិចបន្តួចក៏ត្រូវចោទថាជាជនក្បត់បដិវត្តន៍ដែរ ។ ជាទូទៅ បទឧក្រិដ្ឋដែលកម្មាភិបាលនិងប្រជាជនទាំងនេះបានសារភាពរួមមានលួចមកលេងផ្ទះដោយមិនបានប្រាប់ប្រធានក្រុម ធ្វើឲ្យបែកបាក់ឧបករណ៍ផ្ទះបាយ លួចចំណីអាហារ និយាយរិះគន់អង្គការ មកធ្វើការយឺតយ៉ាវមិនទាន់ពេលវេលា ធ្វើការមិនបានល្អ ត្អូញត្អែរពីលក្ខខណ្ឌរស់នៅ ពាក់គ្រឿងអលង្ការ មានទំនាក់ទំនងស្នេហាខុសវិន័យបក្ស យំទួញសោកស្តាយស្រណោះ បងប្អូនឬមិត្តភក្តិដែលបានស្លាប់ ឬបង្ហាញទឹកចិត្តក្នុងការគោរពជំនឿសាសនាជាដើម ។ ប្រជាជនមួយចំនួនដែលធ្លាក់ខ្លួនឈឺ ដោយសារធ្វើការធ្ងន់ធ្ងរ ឬហូបមិនគ្រប់គ្រាន់ ត្រូវបានចោទថាធ្វើពុតជាឈឺនិងត្រូវបានចាត់ទុកថាជាមនុស្សខ្ជិលច្រអូស ឬឈឺសតិអារម្មណ៍ ។ អ្នកទាំងនេះជាញឹកញាប់ត្រូវបាត់ខ្លួនដោយមិនមានដានអ្វីទាំងអស់ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ធ្វើច្រើនជាង ឬតិចជាងការកំណត់របស់អង្គការមានន័យស្មើសេចក្តីស្លាប់ ដូចពាក្យស្លោកខ្មែរក្រហមនិយាយថា "អង្គការថាម៉េច ត្រូវធ្វើយ៉ាងហ្នឹង! អង្គការដាក់ទិស ត្រូវអនុវត្តឲ្យបានសម្រេច! មិត្តមិនបាច់តថ្លៃទេ!" ។

***សត្រូវខាងក្រៅ*** សំដៅទៅលើសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តដូចជាប្រទេសថៃនិងប្រទេសសង្គមនិយមមួយចំនួន ជាពិសេសប្រទេសវៀតណាមនិងអតីតសហភាពសូវៀត ។ ខ្មែរក្រហមយល់ថាប្រទេសទាំងអស់នេះមានគោលបំណងឈ្លានពាន និងប៉ុនប៉ងចង់យកកម្ពុជាដាក់ក្រោមអាណានិគម ។ ខ្មែរក្រហមបានចោទប្រកាន់មនុស្សជាច្រើនរួមទាំងកម្មាភិបាលនិងកងទ័ពរបស់ខ្លួនផងថាបានបម្រើឲ្យមនោគមវិជ្ជារបស់ប្រទេសទាំងនេះ ។ ខ្មែរក្រហមបានហៅអ្នកទាំងនេះថាជា "ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង" ។ អ្នកទាំងនោះរួមមានអ្នកដែលមកពីប្រទេសដែលប្រឆាំងនឹងរបបសង្គមនិយមដឹកនាំដោយសហរដ្ឋអាមេរិក និងប្រទេសសេរីនិយមឬប្រទេសអនុត្តរភាពនិយម ដូចជាអតីតសហភាពសូវៀត វៀតណាមនិងសម្ព័ន្ធមិត្តដទៃទៀត ។ មនុស្សភាគច្រើនដែលត្រូវបានចាត់ទុកថាជាសត្រូវបង្កប់ស៊ីរូងផ្ទៃក្នុងត្រូវបានចោទប្រកាន់ដោយច្រឡំថាបានធ្វើការឲ្យភ្នាក់ងារសម្ងាត់សេ.អ៊ី.អារបស់សហរដ្ឋអាមេរិក ភ្នាក់ងារសម្ងាត់កា-ហ្គេ-បេរបស់អតីតសហភាពសូវៀតនិងជាភ្នាក់ងារសម្ងាត់របស់វៀតណាម ។ ខ្មែរក្រហមក៏បានចាត់ទុកអ្នកដែលអាចនិយាយភាសាបរទេសថាជាភ្នាក់ងារសម្ងាត់ផងដែរ ។ ការចោទប្រកាន់នេះបានក្លាយទៅជាវិធីមួយដ៏មានប្រសិទ្ធភាពសម្រាប់កម្មាភិបាលមូលដ្ឋានយកធ្វើជាលេសសម្លាប់ប្រជាជនណាម្នាក់ដែលខ្លួនស្អប់ខ្ពើម ។


កម្មាភិបាលខ្មែរក្រហមនៅក្នុងផ្ទះបាយរួម

## ៣) ការចាប់ខ្លួននិងការឃុំឃាំង

នៅចុងឆ្នាំ១៩៧៦និងដើមឆ្នាំ១៩៧៧ ការស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុងបានក្លាយជាកិច្ចការចម្បងរបស់

ខ្មែរក្រហម ។ ខ្មែរក្រហមបានធ្វើឲ្យអ្នកភូមិស៊ើបការណ៍ពីគ្នាទៅវិញទៅមកដោយប្រើប្រាស់ពាក្យស្លោកមួយ "ត្រូវបេះតាមដានគ្នាទៅវិញ ទៅមក ។ ត្រូវរាយការណ៍ជូនអង្គការ" ។ មធ្យោបាយផ្សេងៗទៀតដែលខ្មែរក្រហមប្រើក្នុងការស្វែងរកចាប់ខ្លួនខ្មាំងបង្កប់ រួមមានការឈ្លបយកការណ៍ របាយការណ៍ពីអ្នកយកការណ៍ ការធ្វើប្រវត្តិរូបផ្ទាល់ខ្លួនញឹកញាប់ និងចម្លើយសារភាព ។

នៅពេលដែលខ្មាំងត្រូវបានរកឃើញឈ្មោះរបស់អ្នកទាំងនេះនឹងត្រូវរាយការណ៍ទៅគណៈកម្មាធិការឃុំ ឬគណៈកម្មាធិការស្រុក ហើយបន្ទាប់មកអ្នកទាំងនេះនឹងត្រូវចាប់ខ្លួន ។ អង្គការកម្រចាប់ខ្លួនអ្នកណាម្នាក់ជាសាធារណៈណាស់ ។ ប្រសិនបើមានសមាជិកណាម្នាក់នៅក្នុងសហករណ៍មួយត្រូវបានសង្ស័យ កម្មាភិបាលសហករណ៍នោះនឹងប្រាប់អ្នកនោះថា "អង្គការអញ្ជើញអ្នកទៅរៀនសូត្រ" ។ ក្រោមលេសអញ្ជើញនេះជនរងគ្រោះជាច្រើនត្រូវបានចាប់បញ្ជូនទៅមន្ទីរឃុំឃាំងនិងសម្លាប់ចោលជាញឹកញាប់ ដោយមិនមានការកាត់សេចក្តីឬស្រាវជ្រាវឲ្យបានហ្មត់ចត់ថាតើអ្នកទាំងនោះពិតជាបានប្រព្រឹត្តបទឧក្រិដ្ឋបែបនោះមែនឬក៏មិនមែនទេ ។ ខ្មែរក្រហមនិយាយថា "សុខចិត្តចាប់ខុស ១០ មិនឲ្យលែងខុស១" ។

## ៤) ការសួរចម្លើយនិងការធ្វើទារុណកម្ម

អ្នកដែលជាប់ចោទពីបទល្មើសស្រាលៗ ឬជាប់ឃុំនៅមន្ទីរសន្តិសុខថ្នាក់ទាប ជាទូទៅច្រើនទទួលរងនូវការទទួលទានអាហារមិនគ្រប់គ្រាន់ ជំងឺគ្មានការព្យាបាល និងការប្រព្រឹត្តអំពើឃោរឃៅផ្សេងៗទៀត ។ ទោះជាមានមនុស្សជាច្រើនស្លាប់ ក្នុងស្ថានភាពបែបនេះក៏ដោយ ក៏មានមួយចំនួនទៀតបានរួចផុតពីទារុណកម្មនិងការសម្លាប់ដែរ ។ ប៉ុន្តែនៅមន្ទីរសន្តិសុខថ្នាក់ខ្ពស់របស់ខ្មែរក្រហមដូចជាមន្ទីរស-២១ ការសួរចម្លើយនិងការធ្វើទារុណកម្មគឺជាសកម្មភាពធម្មតាប្រចាំថ្ងៃ ។

ជូ សូភា រស់នៅក្នុងខេត្តកំពង់ចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ សូភា ត្រូវបានចាប់ខ្លួននៅខែឧសភា ឆ្នាំ១៩៧៧ ដោយមិនដឹងមូលហេតុអ្វីទាំងអស់ ។ សូភា បានរៀបរាប់ពីការចាប់ខ្លួននិងស្ថានភាពរបស់គាត់កាលនៅក្នុងគុក ស្រុកត្បូងឃ្មុំយ៉ាងដូច្នេះថាៈ

ថ្ងៃមួយកងសន្តិសុខបួននាក់បានមកដល់កងរបស់ខ្ញុំ ហើយបានស្នើខ្ញុំក្នុងសម្តីសុភាពរាបសាថាឲ្យទៅជួយតខ្សែភ្លើង ។ នៅពេលខ្ញុំចេញមកដល់ក្រៅសន្តិសុខស្ទុះមកភ្ជង់កាំភ្លើងតម្រង់រកខ្ញុំ ហើយចងដៃខ្ញុំ ។ ខ្មែរក្រហមបានចាប់ខ្ញុំយកទៅដាក់គុក ។ បន្ទាប់ពីស្នាក់នៅក្នុងគុកអស់រយៈពេលសែសិបថ្ងៃ ខ្មែរក្រហមបញ្ជូនខ្ញុំមកសួរចម្លើយដែលមានសភាពឃោរឃៅជាងមុនទៅទៀត ។ កងសន្តិសុខបានយកខ្សែភ្លើងមកឆក់ខ្ញុំដើម្បីសួរចម្លើយ ។ ជួនកាលគេវាយខ្ញុំយ៉ាងខ្លាំង ធ្វើឲ្យខ្ញុំសន្លប់ជាច្រើនសា ។ ទោះជាធ្វើទណ្ឌកម្មខ្ញុំខ្លាំងយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែឆ្លើយថាមិនដឹង ។ បន្ទាប់មកខ្មែរក្រហមបញ្ជូនខ្ញុំទៅមន្ទីរសួរចម្លើយថ្មីមួយទៀត ។ ខ្ញុំនៅទីនោះរយៈពេលដប់ពីរថ្ងៃ ។ ចាប់ពីពេលនោះមក ខ្មែរក្រហមលែងសួរចម្លើយឬធ្វើទារុណកម្មខ្ញុំទៀតហើយ ។ ខ្លួនប្រាណខ្ញុំចុះស្គមយ៉ាងខ្លាំង ។ បីថ្ងៃក្រោយមក ខ្មែរក្រហមដោះលែងខ្ញុំ ដោយនិយាយថាអង្គការមានការភ័ន្តច្រឡំ ។ ប៉ុន្តែខ្ញុំត្រូវសន្យាថានឹងមិនប្រាប់អ្នកណាទាំងអស់អំពីស្ថានភាពនៅក្នុងគុក ។ ប្រសិនបើមានអ្នកណាម្នាក់សួរខ្ញុំ ចម្លើយរបស់ខ្ញុំគឺ "មិនដឹង មិនឮ មិនឃើញ" ។

## ៥) ការសម្លាប់

ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនប្រហែលប្រាំសែននាក់ត្រូវបានសម្លាប់ក្រោមបទប្រព្រឹត្តអំពើឧក្រិដ្ឋប្រឆាំងបដិវត្តន៍និងរដ្ឋ ។ ប្រជាជនថ្មីរាប់ពាន់នាក់ដែលមិនមានបទពិសោធន៍ឬជំនាញក្នុងការធ្វើស្រែចម្ការបានបាត់ខ្លួន ។ ប្រជាជនត្រូវបាននាំយកទៅព្រៃជ្រៅឬទីវាលឆ្ងាយពីភូមិស្រុកដើម្បីសម្លាប់ បន្ទាប់ពីប្រជាជនទាំងនោះបានប្រព្រឹត្តនូវអំពើដែលខ្មែរក្រហមចាត់ទុកថាជាកំហុសឬបានបញ្ចេញកាយវិការខឹងសម្បានឹងថ្នាក់ដឹកនាំរបស់ខ្លួន ។ ជនរងគ្រោះខ្លះត្រូវបានកប់ទាំងរស់ ហើយស្លាប់ដោយថប់ដង្ហើម ។

មនុស្សស្ទើរគ្រប់រូបដែលត្រូវបានរកឃើញថា ជាអ្នកធ្លាប់មានការរៀនសូត្រជ្រៅជ្រះត្រូវបានយកទៅសម្លាប់ចោល ។ ជាទូទៅគ្មានអ្នកណាម្នាក់ហ៊ានពាក់វ៉ែនតាឬនិយាយភាសាបរទេសឡើយ ព្រោះវាជាសញ្ញាបង្ហាញថាជននោះជាអ្នកចេះដឹង ។ ជាពិសេសអ្នកដែលមកពីទីក្រុងត្រូវតែលាក់ប្រវត្តិនិងចំណេះវិជ្ជារបស់ខ្លួនហើយធ្វើពុតជាមនុស្សល្ងង់ខ្លៅ ។

ការសម្លាប់ត្រូវបានធ្វើឡើងច្រើនបែបច្រើនសណ្ឋាន ។ អ្នកខ្លះត្រូវខ្មែរក្រហមចោទថាក្បត់បដិវត្តន៍ ឬជាខ្មាំង ហើយត្រូវបានបញ្ជូនទៅមន្ទីរសួរចម្លើយ ។ បន្ទាប់ពីនៅទីនោះបានរយៈពេលពីរ-បីខែ អ្នកទោសនឹងត្រូវយកទៅវាលពិឃាត ដែលអ្នកទាំងនោះត្រូវបានបង្ខំឲ្យលុតជង្គង់នៅមាត់រណ្តៅ ។ បន្ទាប់មក អ្នកទោសទាំងនេះនឹងត្រូវសម្លាប់ដោយវាយចំផ្នែកខាងក្រោយនៃក្បាលជាមួយនឹងប៉ែល ចបកាប់ ឬដំបង ។ ជួនកាលមនុស្សរហូតដល់ទៅមួយរយនាក់ត្រូវបានបាញ់សម្លាប់ក្នុងពេលតែមួយ ហើយកប់ក្នុងរណ្តៅតែមួយ ។ អ្នកខ្លះទៀតត្រូវបានធ្វើឲ្យថប់ដង្ហើមស្លាប់ដោយយកថង់ផ្លាស្ទិកប្រកក្បាល ។ នៅជនបទដែលមានអណ្តូងជាច្រើននៅក្នុងព្រៃ អ្នកទោសត្រូវបានដឹកតាមឡានធំទៅដល់មាត់អណ្តូង ហើយបន្ទាប់មកកងឈ្លបក៏រុញឬវាយទម្លាក់ទៅក្នុងនោះតែម្តង ។

ពេលខ្លះសមាជិកគ្រួសារទាំងអស់ត្រូវបានយកទៅសម្លាប់ចោល ដោយសារតែកំហុសដែលបានប្រព្រឹត្តដោយសមាជិកម្នាក់ ។ ខ្មែរក្រហមបានស្វែងរកចាប់ខ្លួនសមាជិកទាំងអស់យកទៅសម្លាប់ក្រោមទ្រឹស្តីថា «ជីកស្មៅត្រូវជីកទាំងឫស» ។

ម៉ម ដៃប៊ុន ប្រជាពលរដ្ឋរស់នៅខេត្តកោះកុង បានរៀបរាប់អំពីសមាជិកគ្រួសាររបស់គាត់ដែលត្រូវបានយកទៅសម្លាប់ចោលថា ៖

ប្អូនស្រីរបស់ខ្ញុំម្នាក់អាយុប្រាំពីរឆ្នាំត្រូវបានអង្គការសម្លាប់ចោល ព្រោះវាលួចពោតខ្លីមួយផ្លែហូប ។ អង្គការវាយនឹងត្បូងចបហើយកប់ក្បែរចម្ការពោត ។ រសៀលមួយ ពេលខ្ញុំកំពុងដេញគោកាត់ព្រៃ ខ្ញុំធុំក្លិនស្អុយសាកសពរលួយ ។ ខ្ញុំដើររកមើលក្រែងប្រទះជាអ្នកធ្លាប់ស្គាល់គ្នា ។ មិននឹកស្មានថានោះជាសាកសពឪពុកខ្ញុំសោះ ។ គាត់ត្រូវកាប់នឹងកាំបិតដិតដាច់កចេញពីស្មា ។ នៅក្បែរសពឪពុកខ្ញុំ មានសាកសពពីរនាក់ទៀតដែលត្រូវសម្លាប់ដោយកាត់ផ្តាច់កដូចគ្នា ។ រំលងពីនោះបានប្រហែលជាងពីរខែ ជីដូនខ្ញុំអាយុជាងចិតសិបឆ្នាំបានស្លាប់ ។ គាត់ត្រូវបានចោទថាលួចបបរក្មេងហូប ហើយត្រូវមេកងវាយពីរដំបង ។ សពរបស់គាត់ត្រូវបានរុំនឹងបាវយកទៅកប់ចោល ។ ក្រោយពីមរណភាពរបស់ជីដូនខ្ញុំតែប៉ុន្មានថ្ងៃ ម្តាយខ្ញុំក៏ស្លាប់ទៀត ។ គាត់ស្លាប់ដោយសារការងាររលំបាកនិងគ្មានអាហារហូបគ្រប់គ្រាន់ ។ ខ្ញុំឪបគាត់ជាមួយសម្រែកយំសោកស្តាយ ។ **(នៅមានត)**

**ឌី ខាំបូលី**



កងកុមារ

# តម្លៃនៃការនិយាយពីជម្លោះអតីតកាល

តើយើងអាចរៀនពីប្រវត្តិសាស្ត្របានទេ? មានការព្យាយាមឆ្លើយថា «ទេ» ចំពោះសំណួរនេះ ។ នៅពេលយើងសិក្សាជម្លោះកំពុងកើតមាននៅជុំវិញពិភពលោកតាមរយៈគំនិតមួយមិនមានការរិះគិតនោះចម្លើយទៅនឹងសំណួរខាងលើគឺទេ ។ វាហាក់ដូចជាកំហុសចំពោះរឿងនេះដែលកើតឡើងម្តងហើយម្តងទៀត ។ តែប្រសិនបើយើងដូរសំណួរនេះហើយសួរ តើយើងអាចរៀនសូត្រពីរឿងអតីតកាលបានទេ? ខ្ញុំមិនស្ទាក់ស្ទើរនឹងឆ្លើយថា «បាន» នោះទេ ។ នៅក្នុងជំពូកទី១ ខ្ញុំព្យាយាមផ្តោតទៅលើជម្លោះកើតមាននៅប្រទេសន័រវេសនិងប្រទេសកម្ពុជាដែលមានទំនាក់ទំនងនឹងគ្នានាពេលបច្ចុប្បន្ន ។ រឿងរ៉ាវត្រូវបាននិយាយប្រាប់ដែលជាផ្នែកមួយនៃការនិទានពីប្រវត្តិជីវិតនៅអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ហើយរឿងរ៉ាវទាំងនេះត្រូវបាននិយាយតៗគ្នាដើម្បីបម្រើគោលបំណងប្រកបដោយផលប្រយោជន៍ជាក់លាក់មួយ ។ តាមរយៈការបង្ហាញករណីពីរផ្សេងគ្នា ខ្ញុំនឹងធ្វើការអះអាងថាពេលយើងនិយាយពីតម្លៃពិសេសរបស់ការនិទានរឿងរ៉ាវ យើងត្រូវសិក្សាវាដោយភ្ជាប់ជាមួយនឹងសង្គមផ្លាស់ប្តូរវប្បធម៌ប្រុនយោបាយរបស់សង្គមដែលរឿងរ៉ាវនេះកើតឡើង ។

បន្ទាប់ពីលើកឡើងពីតួនាទីខុសៗគ្នារបស់ការនិទានរឿងជម្លោះអតីតកាលដែលអាចមានឡើងនៅក្នុងបរិបទខុសគ្នា ខ្ញុំនឹងធ្វើការបង្ហាញយ៉ាងខ្លីពីប្រវត្តិខ្លះរបស់ទ្រឹស្តីគំនិតក្នុងការចូលរួមពីការយល់ដឹងពីវិធីដែលរឿងរ៉ាវពីអតីតកាលអាចមានតួនាទីទូលំទូលាយមួយចំពោះជម្រើសដ៏មានសក្តានុពលសម្រាប់សកម្មភាពអនាគតកាលដែលអាចនៅក្រោមគោលបំណងទាយធម្មនិយាមបានរបស់ការនិទានរឿង ។

យើងចាប់ផ្តើមពីប្រទេសន័រវេសនិងការព្យាយាមជាពិសេសមួយចំពោះរឿងរ៉ាវដែលទាក់ទងពីអំឡុងពេលត្រួតត្រារបស់អាល្លឺម៉ង់នៅក្នុងសង្គ្រាមលោកលើកទីពីររហូតមកដល់ពេលបច្ចុប្បន្ន ។

### ពី«ផ្ទះភ័យរន្ធត់» ទៅ«ផ្ទះសន្តិភាព»

ស៊ីវតេសិន អាគីវើត ជាស្ថាប័នមួយធ្វើការលើវិស័យព័ត៌មាន ឯកសារ ការអប់រំ ការស្រាវជ្រាវ និងវប្បធម៌ដែលមានទំនាក់ទំនងជាមួយនឹងបំណងធម្មតាក្នុងការធានានូវមូលដ្ឋានគ្រឹះសម្រាប់សន្តិភាពយូរអង្វែងនិងលទ្ធិប្រជាធិបតេយ្យ ។ ស្ថាប័ននេះមានទីតាំងនៅក្នុងអគារមួយដែលដើរតួនាទីជាការិយាល័យកណ្តាលប៉ូលិសសម្ងាត់របស់អាល្លឺម៉ង់ ក្រុមហ្គេសស្តាប៉ូនៅភាគខាងជើងប្រទេសន័រវេសនៅអំឡុងសង្គ្រាមលោកលើកទីពីរ ។ ជាន់ខាងក្រោមរបស់អគារនេះត្រូវបានប្រើជាមជ្ឈមណ្ឌលឃុំឃាំងនិងសួរចម្លើយ ។

នៅមុនពេលហ្គេសស្តាប៉ូចូលកាន់កាប់ អគារនេះជាបណ្ណ-សារដ្ឋានតំបន់មួយ ។ អគារនេះត្រូវបានស្គាល់ថា «អាគីវើត» ។ ក្រោយសង្គ្រាមផុតរលត់ទៅ អគារនេះនៅតែដើរតួនាទីជាបណ្ណ-សារដ្ឋានតំបន់មួយដដែល រហូតដល់មានមនុស្សមួយក្រុមមានគំនិតប្រែក្លាយទីកន្លែងនេះឲ្យទៅជា«ផ្ទះសន្តិភាព»នៅឆ្នាំ១៩៩៩ ។

បន្ទប់ឃុំឃាំងនិងបន្ទប់សួរចម្លើយពីឆ្នាំ១៩៨២ដល់ឆ្នាំ១៩៨៥ ត្រូវបានជួសជុលឡើងវិញ ហើយព្រឹត្តិការណ៍ដែលកើតឡើងនៅជាន់ខាងក្រោមត្រូវបានបង្ហាញតាមរយៈការរៀបចំនិងរូបសំណាកទំហំប៉ុនមនុស្ស ។ ជារៀងរាល់ឆ្នាំមានសិស្សសាលាប្រហែល៧០០០នាក់ ទៅទស្សនកិច្ចបន្ទប់ឃុំខ្លួននិងកន្លែងសួរចម្លើយនេះ ។ រឿងរ៉ាវនេះត្រូវបាននិយាយប្រាប់សម្រាប់គោលបំណងមួយ ។ ដំណើរទស្សនកិច្ចនេះដើរតួនាទីជាគោលបំណងសំខាន់មួយបង្ហាញពីអាកប្បកិរិយា តម្លៃការឆ្លុះបញ្ចាំងនិងការយល់ដឹងអំពីរឿងរ៉ាវដែលបានកើតមានឡើងនៅ «អាគីវើត» ។

ស៊ីវតេសិន អាគីវើត មានកម្មវិធីផ្លាស់ប្តូរការសិក្សាជាមួយសារមន្ទីរកោះរ៉ូបេនរបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ អ្នកនិយាយរឿងរ៉ាវប្រាប់ម្នាក់របស់ ស៊ីវតេសិន អាគីវើត ធ្វើការមួយឆ្នាំនៅសារមន្ទីរនេះ និងអ្នកនិយាយរឿងរ៉ាវម្នាក់ទៀតមកពីសារមន្ទីរ

*កោះរ៉ូបេន ក៏ធ្វើការមួយឆ្នាំនៅ ស៊ីវតេសិន អាគីវើត ដែរ ។ នៅឆ្នាំ២០០៦ និង២០០៧ វុយស៊ុមស៊ី ម៉ាកខុងហ្គោ មកពីសារមន្ទីរកោះរ៉ូបេនកំពុងធ្វើការនៅ ស៊ីវតេសិន អាគីវើត ។*

*ម៉ាកខុងហ្គោ ត្រូវបានចាប់ឃុំខ្លួនអស់រយៈពេល១២ឆ្នាំ នៅកោះរ៉ូបេន នៅអំឡុងពេលរបបអាប៉ាថេត ។ បន្ទាប់ពីរបបអាប៉ាថេតចប់ គាត់វិលត្រឡប់ទៅកន្លែងឃុំឃាំងនោះវិញ ហើយធ្វើការជាមគ្គុទេសក៍នៅសារមន្ទីរនេះ ។ ប្រការនេះធ្វើឲ្យមានការជឿជាក់យ៉ាងខ្លាំងអំពីសារសំខាន់ក្នុងកានិយាយរឿងឧក្រិដ្ឋកម្ម និងការឈឺចាប់ដែលគាត់ទទួលរងក្នុងរយៈពេលនោះ ។ ម៉ាកខុងហ្គោជឿថា យើងអាចរៀនពីប្រវត្តិសាស្ត្រ ហើយគាត់ចង់ចូលរួមក្នុងការទប់ស្កាត់រឿងរ៉ាវបែបនេះកុំឲ្យកើតមានម្តងទៀត ។*

*នៅពេលគាត់និយាយប្រាប់ក្មេងសិស្សសាលានិងនិស្សិតដែលទៅទស្សនកិច្ចនៅអគារជាន់ក្រោម ស៊ីវតេសិន អាគីវើត និយាយប្រាប់រឿងរ៉ាវស្រដៀងគ្នានៅពេលគាត់ជាប់ឃុំនៅកោះរ៉ូបេន និងអំពីអ្វីដែលដែលអ្នកទោសនៅអាគីវើតបានជួបប្រទះ ។*

*នៅពេលគាត់និយាយអំពីការតស៊ូរបស់គាត់ក្រោមការគ្រប់គ្រងរបស់អាប៉ាថេតនៅប្រទេសអាហ្វ្រិកខាងត្បូង និងការប្រយុទ្ធប្រឆាំងដើម្បីសិទ្ធិសេរីភាពនិងភាពថ្លៃថ្នូររបស់មនុស្ស គាត់បាននិយាយភ្ជាប់ជាមួយនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់សិស្សសាលាប្រទេសន័រវេស អំពីន័យនិងតម្លៃសេរីភាព និងការទទួលខុសត្រូវដែលមានជាមួយនឹងសិទ្ធិសេរីភាពនេះ ។ គាត់និយាយថា «នេះមិនមែនជារឿងដែលអ្នកទាញយកផលប្រយោជន៍ទេ» ។ «លទ្ធិប្រជាធិបតេយ្យអាចដំណើរការទៅបានប្រសិនបើអ្នកទទួលខុសត្រូវចំពោះសុខុមាលភាព អត់ឱនចំពោះគ្នាទៅវិញទៅមក ស្រឡាញ់រាប់អានជនជាតិផ្សេងៗគ្នា និងប្រសិនបើអ្នកការពារនឹងប្រើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់អ្នករងការឈឺចាប់ដើម្បីរួចផុតភ័យ» ។ គាត់និយាយបែបនេះក្នុងពេលដែលគាត់កំពុងឈរនៅកណ្តាលបន្ទប់ឃុំឃាំងនៅ ស៊ីវតេសិន អាគីវើត ។ នៅក្រោមពន្លឺភ្លើងចាំងពីបង្អួចតូចមួយនៅក្រោមដំបូល អ្នកឃើញសំណាកប៉ុនមនុស្សហួរឈាម និងត្រូវបានវាយធ្វើបាប ។ វាមានក្លិនដូចបន្ទប់ជាន់ក្រោម ត្រជាក់ និងនៅថ្មីៗ ហើយនៅពេលដែលសិស្សសាលាឈរស្ទាកៀកស្ទាគ្នាក្នុងបន្ទប់តូចមួយ អ្នកអាចមានអារម្មណ៍ពីបរិយាកាសតូចនិងគួរឲ្យខ្លាច ។ រាល់ការដឹងដោយអារម្មណ៍ទាំងនេះគឺជាផ្នែកមួយរបស់ការនិទានរឿងដូចជាសំឡេងទ្វារដែកខ្លាំងៗ និងសំឡេងអ្នកនិយាយរឿងប្រាប់ ។*

*អ្នកនិយាយរឿងប្រាប់ជាច្រើននៅ ស៊ីវតេសិន អាគីវើត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរឿងដែលគេប្រាប់ ។ អ្នកខ្លះធ្លាប់បានត្រូវចាប់ខ្លួននិងធ្វើទារុណកម្មដោយផ្ទាល់នៅ «អាគីវើត» ។ ដូចជា ម៉ាកខុងហ្គោ ដែរ អ្នកទាំងអស់នេះមិនអាចបំភ្លេចនូវការឈឺចាប់ពីអតីតកាលនេះទេ ។ តែផ្ទុយទៅវិញអ្នកទាំងនេះបានត្រឡប់ទៅកន្លែងដែលស្គាល់ថា «ផ្ទះភ័យរន្ធត់» ដើម្បីចងក្រងនូវព្រឹត្តិការណ៍និងជារៀងរាល់ថ្ងៃប្រាប់ពីរឿងរ៉ាវដែលបានកើតឡើងនៅ «អាគីវើត» និងពីរបៀបដែលយើងចាំបាច់រៀនពីរឿងរ៉ាវទាំងនេះ ដើម្បីការពារកុំឲ្យកើតមានតទៅទៀត ។ សព្វថ្ងៃកន្លែងនេះត្រូវបានទទួលស្គាល់ថា «ស៊ីវតេសិន អាគីវើត មជ្ឈមណ្ឌលសម្រាប់ផ្ទះបញ្ចាំងប្រវត្តិសាស្ត្រនិងការកសាងសន្តិភាព» ។ ដោយការខិតខំប្រឹងប្រែងពីសំណាក់អ្នកនិយាយប្រាប់រឿងរ៉ាវនេះផ្ទះត្រូវបានប្តូរពីអ្វីដែលស្គាល់ថាជា «ផ្ទះភ័យរន្ធត់» ទៅជា «ផ្ទះសន្តិភាព»វិញ ។*

## តម្លៃសំខាន់នៃការនិទានរឿង

*ហេតុអ្វីបានត្រូវធ្វើរឿងនេះ? នៅពេលខ្ញុំសួរគាត់ ខ្ញុំទទួលបានចម្លើយដូចគ្នា គឺប្រាប់រឿងរ៉ាវដើម្បីការពារកុំឲ្យកើតមានឡើងវិញ ។ គាត់ជឿជាក់លើឥទ្ធិពលផ្ទះបញ្ចាំងពីប្រវត្តិសាស្ត្រ និងជឿលើមុខងារប្រកបដោយផលប្រយោជន៍របស់ការនិទានរឿង ។ «យើងអាចលើកលែងទោស ប៉ុន្តែមិនអាចបំភ្លេច» ជាពាក្យនិយាយជាទូទៅដែលចេញពីមាត់អ្នកនិយាយរឿងនៅ ស៊ីវតេសិន អាគីវើត ។ គាត់ចង់រក្សាការចងចាំទុកជាប់រហូត ប៉ុន្តែគាត់មិនបិតនៅក្នុងអតីតកាលទេ នេះជារឿងអស្ចារ្យអំពីការនិយាយរឿងប្រាប់ដែលគាត់ចូលរួម ។ គាត់និយាយថា «នៅពេលយើងនិយាយរឿងមួយពីអតីតកាល យើងត្រូវតែនិយាយរឿងពីរគឺ អំពីបច្ចុប្បន្នកាលនិងអនាគតកាល» ។*

*នៅក្នុងទម្រង់យ៉ាងសាមញ្ញបំផុត នេះគឺជាអត្ថន័យនៃគំនិតខាងមនសិការប្រវត្តិសាស្ត្រ ។ មនសិការប្រវត្តិសាស្ត្រលើសពីអ្វីដែលគ្រាន់តែជាការយល់ដឹងខាងប្រវត្តិសាស្ត្រ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ចំណេះដឹងពីការពិតប្រវត្តិសាស្ត្រនិងការជឿថា*

រឿងអ្វីមួយពិតជាកើតមានឡើង ដូចដែលអ្វីដែលគាត់បានលើកឡើងនោះ ប្រហែលជាផ្នែកសំខាន់ចំពោះការបង្កើតមនសិការ ប៉ុន្តែមនសិការប្រវត្តិសាស្ត្រវាជារឿងមួយផ្សេងទៀត ។ ដូចដែលបានដឹងនៅក្នុងការបង្កើតឡើងរឿងនិទាន និងការនិទានរឿងប្រាប់នៅស៊ីវ៉ែតេសិន អាគីវ៉េត មនសិការប្រវត្តិសាស្ត្រ គឺជាស្មារតីដែលរបៀបដែលអតីតកាលទាក់ទងនឹងពេលបច្ចុប្បន្ននិងរបៀបដែលមនសិការបង្កើតនូវមុខងារធំទូលាយសម្រាប់អនាគតកាល ។ និយាយបែបម្យ៉ាងទៀត មនសិការប្រវត្តិសាស្ត្រគឺជាទំនាក់ទំនងរវាងពេលវេលាបី គឺអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល ។

អ្នកនិយាយរឿងប្រាប់នៅ ស៊ីវ៉ែតេសិន អាគីវ៉េត ជាញឹកញាប់តែងតែភ្ជាប់រឿងដែលខ្លួននិយាយជាមួយនឹងរឿងរ៉ាវក្នុងពេលបច្ចុប្បន្នដែលក្មេងសិស្សសាលាជួបជារៀងរាល់ថ្ងៃ ។ អ្នកទាំងនោះមិនប្រាប់រឿងមួយនោះទេ ប៉ុន្តែបើកឲ្យមានការឆ្លុះបញ្ចាំង ។ អ្នកទាំងនោះសួរថា «ហេតុអ្វីបានជា អូលី វីហ៊ុសបានក្លាយសមាជិកណាហ្ស៊ី?» ។ វីហ៊ុស ជាជនជាតិន័រវេសនៅសហគមន៍ក្នុងស្រុកមួយ ។ អ្នកនិយាយរឿងជាច្រើនស្គាល់ វីហ៊ុស ពេលគាត់ធំពេញរូបពេញរាង ។ អ្នកទាំងនោះប្រាប់ពីរបៀបដែល វីហ៊ុស ត្រូវបានគេសម្លុតនៅសាលានិងពីរបៀបដែលគាត់ត្រូវបានដេញចេញពីសង្គមសហគមន៍ ។ អ្នកនិយាយរឿងដែលគាត់ប្រាប់មនុស្សដែលគាត់ធ្វើទារុណកម្មថា «ពេលនេះសងសឹកវិញ» «តើអ្នកណាជាអ្នកខ្សោយក្នុងពេលនេះ» ។ វីហ៊ុស ជាអ្នកធ្វើទារុណ-កម្មយ៉ាងសាហាវនៅអាគីវ៉េត ។ នៅចំពោះមុខការកាត់ទោសរូបគាត់ក្រោយពេលសង្គ្រាមបានបញ្ចប់ គាត់បានពន្យល់ពីការដែលគាត់មានអារម្មណ៍ខ្លាំងនិងមានអំណាចក្នុងពេលឋិតនៅជាមួយក្រុមហ្គេសតាប៉ូ ។ ជាសមាជិកណាហ្ស៊ីម្នាក់ គាត់មានអារម្មណ៍ភ័យខ្លាចចំពោះសហគមន៍ក្នុងស្រុក ហើយការចូលរួមជាមួយណាហ្ស៊ី គាត់ត្រូវបានទទួលជាសមាជិកក្រុម ។ ការប្រាប់រឿងនេះទៅអ្នកនិទានរឿងប្រាប់ឲ្យធ្វើការប្រដូចរឿងរបស់ វីហ៊ុស ទៅនឹងរឿងរ៉ាវក្នុងពេលបច្ចុប្បន្នដែលសិស្សសាលាជួបប្រទះជាមួយនឹងក្រុមអ្នកជិះជាន់និងពីសារប្រយោជន៍ដែលមនុស្សទាំងអស់ចាំបាច់ចេះយោគយល់ចំពោះគ្នាទៅវិញទៅមក ។

ជាផ្នែកមួយនៃការតាំងពិព័ណ៌បង្ហាញការតស៊ូ ធ្វើឡើងដោយចលនាតស៊ូដើម្បីផ្សាយព័ត៌មាន ។ ពេលដែលអ្នកនិយាយរឿងប្រាប់ពីរឿងដែលមនុស្សត្រូវបាននាំយកមកអាគីវ៉េតដើម្បីសួរចម្លើយនិងធ្វើទារុណកម្ម ដោយសារតែបានចូលរួមបង្កើតវិទ្យុខុសច្បាប់មួយ អ្នកនិយាយប្រាប់បានទាញរឿងនេះឲ្យទាក់ទងនឹងសារសំខាន់របស់សេរីភាពក្នុងការបញ្ចេញមតិនិងពីរបៀបដែលខ្លួនប្រឈមមុខនឹងសេចក្តីស្លាប់ ប្រសិនបើខ្លួនព្យាយាមទាមទារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ដោយសេរី ។

នេះជាទម្រង់ពិសេសនៃការនិទានរឿងប្រាប់ ។ ស៊ីវ៉ែតេសិន អាគីវ៉េត ប្រើពាក្យការនិទានរឿង មិនប្រើពាក្យប្រវត្តិសាស្ត្រ ឬការចងចាំនោះទេ ។ វាមិនមែនជាប្រវត្តិសាស្ត្រមួយ ឬក៏ការចងចាំមួយដែលទាក់ទងគ្នានោះទេ ។ ភាពពិតប្រវត្តិសាស្ត្រដែលកើតមានឡើងនៅ «អាគីវ៉េត» គឺទាក់ទងនឹងរឿងមានទំនាក់ទំនងទៅនឹងអតីតកាល បច្ចុប្បន្នកាលនិងអនាគតកាល ។ រឿងរ៉ាវត្រូវបានបង្កើតឡើងនិងធ្វើឲ្យមានទំនាក់ទំនងគ្នាបែបនេះដើម្បីស្វែងយល់ពីគោលបំណងសំខាន់នៃការនិទានរឿងប្រាប់ ។

ខ្ញុំនឹងធ្វើការអះអាងថា ពេលយើងនិយាយពីតម្លៃសំខាន់នៃការនិទានរឿងប្រាប់របស់អតីតកាល គឺយើងចាំបាច់ត្រូវតែសិក្សារឿងនេះជាមួយនឹងសង្គមវប្បធម៌ និងការប្រែប្រួលនយោ-បាយទាក់ទងនឹងសង្គមដែលការនិទានរឿងប្រាប់នេះកើតមានឡើង ។

ដើម្បីធ្វើការអះអាងដូចនេះខ្ញុំចង់បង្វែរការចាប់អារម្មណ៍ទៅលើប្រទេសកម្ពុជាដើម្បីចាប់យកនូវសក្តានុពលភាពរបស់តម្លៃសំខាន់នៃការនិទានរឿងប្រាប់ពីអំពើឃោរឃៅនៅអតីតកាលដោយធ្វើការភ្ជាប់ជាមួយនឹងតុលាការក្នុងពេលខាងមុខនេះ ។

**ការដោះស្រាយជម្លោះអតីតកាល**

សង្គមដែលជួបប្រទះអំពើហិង្សា និងសង្គ្រាមប្រឈមមុខនឹងបញ្ហាយ៉ាងច្រើនក្នុងការដោះស្រាយរឿងឃោរឃៅពីអតីតដើម្បីឈានទៅរកអនាគតមួយប្រកបដោយសន្តិភាពនិងលទ្ធិប្រជាធិបតេយ្យ ។

សន្តិភាពមានន័យច្រើនជាងការអត់មានសង្គ្រាម ។ របៀបដែលសង្គមក្រោយជម្លោះដោះស្រាយរឿងរ៉ាវនិងការចងចាំដ៏សាហាវឃោរឃៅ គឺជាការកំណត់គ្រាដ៏សំខាន់សម្រាប់ដោគជ័យ

ក្នុងការធ្វើដំណើរចេញពីជម្លោះហិង្សាឬការកៀបសង្កត់ឆ្ពោះទៅរកសន្តិភាព លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិរបស់បុគ្គលនិងសមូហភាព ។ តុលាការ គណៈកម្មាធិការស្វែងរកការពិត វិមានចងចាំនិងថ្ងៃចងចាំ គឺជាឧទាហរណ៍ដែលសង្គមក្រោយពីជម្លោះតែងតែដោះស្រាយពីរឿងរ៉ាវកើតឡើងពីអតីតកាល ។

អ្វីដែលដំណើរការទាំងនេះមានជាទូទៅនោះ គឺការប្រើរឿងនិទាន និងការនិយាយរឿងប្រាប់ពីជម្លោះក្នុងអតីតកាលធ្វើជាឧបករណ៍មួយដើម្បីលើកតម្កើងការឆ្លុះបញ្ចាំងនិងមនសិការប្រវត្តិសាស្ត្រ ។

ការប្រឈមមុខនឹងរឿងរ៉ាវអតីតកាលអាចត្រូវបានសិក្សានៅក្នុងផ្នែកនៃដំណើរការក្នុងការធានានូវយុត្តិធម៌អន្តរកាលមួយនៅក្នុងសង្គមក្រោយជម្លោះ ។ ការយល់ដឹងបណ្តោះអាសន្នពីយុត្តិធម៌អន្តរកាល គឺមានន័យទូលំទូលាយដោយត្រូវបានរាប់បញ្ចូលមិនត្រឹមតែជាការដាក់ទោសតាមផ្លូវច្បាប់ ការប៉ះប៉ូវ ការការពារមិនឲ្យមាននិទ្ទណ្ឌភាព និងការកសាងនីតិរដ្ឋមួយ ។ ការប្រឈមមុខនឹងសោកនាដកម្មឈឺចាប់អតីតកាល ត្រូវបានចាត់ទុកថាជាជំហានសំខាន់មួយដើម្បីទទួលបាននូវន័យរួមមួយដើម្បីយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីបង្កើតការជឿជាក់ពីសង្គមស៊ីវិល ដើម្បីធ្វើការផ្សះផ្សាប្រជាជននិងសហគមន៍ និងដើម្បីការពារមិនឲ្យមានការរំលោភបំពាននៅពេលខាងមុខទៀត ។

ប្រទេសកម្ពុជាសព្វថ្ងៃកំពុងតែជួបប្រទះរឿងនេះ ។ នៅឆ្នាំ២០០១ សភាជាតិបានចុះហត្ថលេខាលើច្បាប់មួយដើម្បីគាំទ្រឲ្យមានការបង្កើតឡើងនូវតុលាការមួយដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមនៅរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ តុលាការនេះត្រូវបានប្រកាសចាប់ផ្តើមការងារនៅចុងឆ្នាំ២០០៧ ហើយដែលមានឈ្មោះថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ។ តុលាការនេះត្រូវបានស្គាល់ដោយប្រជាជនក្នុងស្រុកថា «តុលាការខ្មែរក្រហម» ។

ដើម្បីយល់ពីមុខងារបង្កើតឡើងប្រកបដោយសក្តានុពលភាពក្នុងការឆ្លុះបញ្ចាំងប្រវត្តិសាស្ត្ររបស់តុលាការនេះ យើងចាំបាច់ត្រូវតែមើលពីកត្តាសំខាន់ៗមួយចំនួនស្តីពីអំពើឃោរឃៅកើតមាននៅប្រទេសកម្ពុជានិងរបៀបដែលរឿងនេះទាក់ទងជាមួយរឿងរ៉ាវក្នុងពេលបច្ចុប្បន្ននេះ ដោយភ្ជាប់រឿងរ៉ាវជម្លោះនៅអតីតកាលទៅនឹងរឿងរ៉ាវដើម្បីបង្កើតសង្គមអនាគតមួយប្រកបដោយសន្តិភាពនិងប្រជាធិបតេយ្យ ។ វាមានសារសំខាន់ក្នុងការយល់រឿងនេះថា ជាផ្នែកមួយសម្រាប់អះអាងលើហេតុផលដែលថាវាមានសារសំខាន់ដើម្បីធ្វើឲ្យជម្លោះអតីតកាលទៅនឹងគោលគំនិតក្នុងការកសាងសង្គមអនាគតប្រកបដោយសន្តិភាពនៅក្នុងប្រទេសកម្ពុជាដែលមានទំនាក់ទំនងជាមួយតុលាការនេះ ។

## ជម្លោះពីអតីតកាលនៅប្រទេសកម្ពុជា

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជាដែលលោកខាងក្រៅស្គាល់ថា ជាខ្មែរក្រហម បានទទួលជ័យជម្នះបន្ទាប់ពីប្រយុទ្ធក្នុងសង្គ្រាមស៊ីវិលអស់រយៈពេល៥ឆ្នាំ ។ ស្ទើរតែភ្លាមៗនោះ ដោយពុំមានការពន្យល់ពីការគិតគូររបស់ខ្លួន ខ្មែរក្រហមបានកាច់ផ្តាច់រាល់ទំនាក់ទំនងបានមកដោយជោគជ័យជាមួយប្រទេសខាងក្រៅ ហើយបានបង្ខំប្រជាជនឲ្យចេញពីទីក្រុងនិងទីប្រជុំជន បំផ្លាញប្រាក់ចាយ លុបបំបាត់សាលារៀន ទ្រព្យសម្បត្តិឯកជន ច្បាប់ តុលាការ និងផ្សារ ហាមឃាត់ចំពោះការប្រតិបត្តិសាសនា និងឲ្យប្រជាជនទាំងអស់ទៅធ្វើការនៅទីជនបទបង្កបង្កើនផល ។ ការសម្រេចចិត្តនេះធ្វើឡើងដោយសម្ងាត់ដោយអ្នកមានអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងផ្នែកមួយនៃផែនការរបស់ខ្លួនដើម្បីគ្រប់គ្រងលើបដិវត្តន៍ផ្តាច់ការរបស់ម៉ាក្សលេនីន ។ កម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយអតីតគ្រូបង្រៀនម្នាក់ឈ្មោះ ប៉ុល ពត ត្រូវបណ្តេញចេញពីអំណាចដោយកងកម្លាំងវៀតណាមនៅខែមករា ឆ្នាំ១៩៧៩ ។ នៅក្នុងរបបខ្មែរក្រហមមានមនុស្សស្លាប់ ១,៧លាននាក់ ។ តាមការសន្និដ្ឋានមានប្រជាជនប្រហែលមួយនាក់ក្នុងចំណោម៥នាក់ត្រូវបាត់បង់ជីវិត ។ រឿងរ៉ាវរបស់របបខ្មៅងងឹតនេះត្រូវបាននិយាយប្រាប់និងរៀបចំឡើងតាមវិធីផ្សេងៗ បន្ទាប់ពីការរំដោះនៅឆ្នាំ១៩៧៩ ។

ភ្លាមៗបន្ទាប់ពីការឈ្លានពានប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ អ្នកថតរូបវៀតណាមពីរនាក់បានរកឃើញអគារមួយដែលព័ទ្ធជុំវិញដោយរបងស័ង្កសីមានភ្ជាប់ចរន្តអគ្គិសនី មានលួស

បន្ទាជុំវិញ ។ នៅក្នុងអគារនោះអ្នកទាំងពីរឃើញមានសាកសពខ្លះដែលទើបនឹងសម្លាប់ ។ ទីកន្លែងនោះគឺជាកន្លែងសួរចម្លើយ និងឃុំឃាំងដែលប្រើប្រាស់ដោយកម្លាំងសន្តិបាលសម្ងាត់របស់ខ្មែរក្រហម ជាកន្លែងដែលស្គាល់ថាជាមន្ទីរស-២១ ។ រហូតមកដល់ពេលនេះ យើងដឹងថាមានមនុស្សច្រើនជាង ១៤០០០នាក់ ត្រូវបានឃុំឃាំងនិងសួរចម្លើយនៅទីនោះ ។ បន្ទាប់ពីសួរចម្លើយនិងធ្វើទារុណកម្ម អ្នកទោសទាំងអស់ត្រូវបានសម្លាប់ ហើយមានតែមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិត ។

អាចនិយាយបានថា ប្រទេសវៀតណាមបានដឹងភ្លាមៗចំពោះតម្លៃជាប្រវត្តិសាស្ត្ររបស់កន្លែងនេះ ។ ទីកន្លែងនេះត្រូវបានដាក់បង្ហាញជូនដល់ភ្ញៀវបរទេសទស្សនានៅពីរ-បីថ្ងៃក្រោយពីកន្លែងនេះត្រូវបានរកឃើញ ។ ពីរ-បីខែក្រោយមក កន្លែងនេះត្រូវបានប្តូរទៅជាសារមន្ទីរវិញ ។ សព្វថ្ងៃនេះសារមន្ទីរនេះត្រូវបានហៅថា «សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង» ។

ទួលស្លែងជាកន្លែងចាប់អារម្មណ៍មួយរបស់ភ្ញៀវទេសចរណ៍នៅកម្ពុជា ។ នៅក្នុងសារមន្ទីរនេះ អ្នកនឹងដើរនៅក្នុងបន្ទប់ដែលអ្នកទោសត្រូវបានធ្វើទារុណកម្មនិងសម្លាប់ ។

មានរឿងដូចគ្នាជាច្រើនរវាងការពិពណ៌នានៅ ស៊ីវតេសិន អាគីវីត សារមន្ទីរកោះរ៉ូបេន និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ និទានកថានិងរឿងរ៉ាវត្រូវធ្វើឡើងនៅកន្លែងដែលហេតុការណ៍បានកើតឡើង ។ វត្ថុតាងជារូបរាង និងអារម្មណ៍ទាក់ទងនឹងរឿងរ៉ាវ គឺជាផ្នែកសំខាន់មួយនៃការនិយាយរឿងប្រាប់ ។ នេះអាចនិយាយបានថា ជាបទពិសោធន៍ចេញពីការបរិយាយប្រាប់ ។

ការដឹងជារូបរាង រូបភាព ក្លិន និងសំឡេងគឺជាផ្នែករបស់និទានកថា ។ ជាផ្នែករបស់ដំណើរការដែលអ្នកចូលរួមភ្ជាប់រឿងរ៉ាវដែលខ្លួនបាននិយាយប្រាប់ទៅនឹងរឿងរ៉ាវឬក៏អត្តសញ្ញាណបទពិសោធន៍ជីវិតផ្ទាល់ខ្លួន ។ ដូចដែលបានលើកឡើងក្នុងពេលបន្តិចទៀតនេះ ដោយយោលទៅលើស្ថាបនិកសង្គម និងរឿងរបស់ស្ថាបនិកនៃមុខងារបង្កើតនិទានកថារបស់ភាពពិតនៃសង្គម រឿងនេះត្រូវចាត់ទុកថាជាផ្នែកសំខាន់នៃមូលដ្ឋានគ្រឹះក្នុងការសម្រេចបានមនសិការប្រវត្តិសាស្ត្រ ។

រឿងនេះគឺជាលក្ខណៈសាមញ្ញរវាងការនិយាយរឿងប្រាប់នៅ ស៊ីវតេសិន អាគីវីត និងនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ អ្វីដែលខុសប្លែកគ្នានោះគឺនិទានកថា ។ ឬនិយាយម្យ៉ាងទៀតថា អ្វីដែលខុសប្លែកគ្នានោះគឺការឲ្យអត្ថន័យរឿងធំជាងគ្នា តម្លៃ និងការបង្ហាញរឿងរ៉ាវដែលត្រូវនិយាយប្រាប់ ។ គោលបំណងសំខាន់នៃការទាក់ទងនិទានកថាមានការខុសប្លែកគ្នា ។ ស្ថានភាពនៅប្រទេសកម្ពុជាគឺជាឧទាហរណ៍សំខាន់មួយដើម្បីបង្ហាញពីចំណុចនេះ ។ ដើម្បីបង្ហាញពីរឿងនេះ យើងចាំបាច់ត្រូវមើលបន្ថែមទៅលើធាតុសំខាន់ៗរបស់ស្ថានភាពនយោបាយ រឿងរ៉ាវបានកើតឡើងពីអតីតកាលផ្តល់នូវគោលបំណងសំខាន់ច្បាស់លាស់មួយនិងពីហេតុផលការនិទានប្រាប់ទាក់ទងនឹងតុលាការអាចជាតម្លៃសំខាន់ជាមូលដ្ឋាននៃដំណើរការកសាងគ្រឹះសម្រាប់សន្តិភាពនិងលទ្ធិប្រជាធិបតេយ្យយូរអង្វែងក្នុងប្រទេសកម្ពុជា ។

**តម្លៃសំខាន់នៃការបរិយាយជម្លោះអតីតនៅក្រោយការរំដោះឆ្នាំ ១៩៧៩**

ពីរ-បីខែបន្ទាប់ពីការឈ្លានពាននៅខែមករាឆ្នាំ១៩៧៩ របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលគាំទ្រដោយប្រទេសវៀតណាមត្រូវបានបង្កើតឡើង ។ ឥស្សរជនសំខាន់ៗរបស់រដ្ឋាភិបាលថ្មីគឺជាអតីតមន្ត្រីខ្មែរក្រហមដែលបានចូលរួមក្នុងពេលខុសៗគ្នា ជាមួយនឹងកងកម្លាំងវៀតណាមប្រឆាំងនឹងខ្មែរក្រហម ។ នាយករដ្ឋមន្ត្រីកម្ពុជា គឺលោក ហ៊ុន សែន ជាអតីតកម្មាភិបាលខ្មែរក្រហមម្នាក់ដែលបានចូលរួមជាមួយកងកម្លាំងវៀតណាមនៅឆ្នាំ១៩៧៧ ។ ហ៊ុន សែន បានក្លាយជារដ្ឋមន្ត្រីក្រសួងការបរទេសរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាបន្ទាប់ពីការឈ្លានពាននេះ ។

របបសាធារណរដ្ឋចាំបាច់ត្រូវនិយាយពីប្រវត្តិចលនាកុម្មុយនីស្តកម្ពុជាដែលទទួលបានការគាំទ្រថា ជាបដិវត្តន៍សមស្របមួយរហូតមកដល់ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមគ្រប់គ្រងអំណាចនៅប្រទេសកម្ពុជា ។ ដូចគ្នានេះដែរ ចាំបាច់ត្រូវនិយាយផងដែរអំពីរឿងដែលកែសម្រួលឲ្យសមស្របការឈ្លានពានរបស់ខ្លួនមកលើប្រទេសកម្ពុជា នៅខែមករា ឆ្នាំ១៩៧៩ និងការប្រយុទ្ធប្រឆាំងនឹងរបបមួយដែលខ្លួនធ្លាប់បានចូលរួម

កសាង ។ លោក ឆេនល័រ បានសរសេរថា «ពេលដែលរដ្ឋាភិបាលថ្មីផ្តោតការធ្វើឲ្យស្របច្បាប់របស់ខ្លួនលើភាពពិតដែលការកាន់អំណាចនេះបានមកពីការផ្តួលរលំរបបខ្មែរក្រហម ដូចនេះវាគ្មានរឿងអ្វីដែលត្រូវចោទប្រកាន់ចលនាទាំងអស់នោះទេ ដោយសារតែឥស្សរជនជាន់ខ្ពស់ជាច្រើនរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្លាប់ជាខ្មែរក្រហមរហូតដល់បានផ្តាច់ខ្លួនទៅប្រទេសវៀតណាមនៅឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨» ។

នៅពេលសង្គ្រាមត្រជាក់ចប់នៅឆ្នាំ១៩៨៩ ប្រទេសវៀតណាមលែងមានការគាំទ្រពីសហភាពសូវៀត ហើយវៀតណាមក៏បានដកខ្លួនចេញពីកម្ពុជានៅឆ្នាំនោះ ។ ខ្មែរក្រហមនៅតែបន្តសង្គ្រាមជាមួយរដ្ឋាភិបាលថ្មីរហូតដល់ឆ្នាំ១៩៩៩ ។

នៅខែកក្កដា ឆ្នាំ១៩៩៤ រដ្ឋាភិបានបានអនុវត្តយុទ្ធសាស្ត្រដែលប្រើដោយវៀតណាមនៅមុនពេល និងក្រោយការឈ្លានពានដោយលួងលោមខ្មែរក្រហមឲ្យចុះចូលតាមរយៈផ្តល់ការលើកលែងទោស ។ មន្ត្រីជាន់ខ្ពស់ខ្មែរក្រហមបានចូលរួមជាមួយរដ្ឋាភិបាលទទួលបានការលើកលែងទោស ការការពារ ទ្រព្យសម្បត្តិ និងមុខតំណែងខ្ពស់ក្នុងកងកម្លាំងកម្ពុជា ។

លោក ឆាំង យុ សរសេរអត្ថបទមួយនៅក្នុងព្រឹត្តិបត្រអន្តរជាតិរបស់យុត្តិធម៌អន្តរកាលថា «ជនទីមួយបានទទួលការលើកលែងទោស គឺអតីតឧបនាយករដ្ឋមន្ត្រី ឈ្មោះ អៀង សារី ដែលបានផ្តាច់ខ្លួនជាមួយកូនទាហានរបស់គាត់ពីរ-បីពាន់នាក់នៅខែសីហា ឆ្នាំ១៩៩៦ ។ ដើម្បីជាថ្នូរនឹងរឿងនេះ រដ្ឋាភិបាលបានផ្តល់ការលើកលែងទោស ហើយការកាត់ទោសដោយពុំមានវត្តមានគាត់នៅឆ្នាំ១៩៧៩ត្រូវបានលុបចោល ។ នៅពេលមានការផ្តាច់ខ្លួនរបស់ អៀង សារី បានធ្វើឲ្យចលនាខ្មែរក្រហមបែកខ្ញែកនិងចុះខ្សោយ វាក៏មានការទាមទារយ៉ាងច្រើនពីប្រជាជនរស់រានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ និងបង្ខំឲ្យមានគិតគូរពីរឿងយុត្តិធម៌ចំពោះឧក្រិដ្ឋកម្ម ។ ការបន្តរបៀបវារៈនយោបាយនៅពេលនោះធ្វើឡើងដុយពីការការចង់បានយុត្តិធម៌ ។ ទាំងគណបក្សប្រជាជននិងគណបក្សហ៊្វុនស៊ិនប៉ិច ប្រកួតប្រជែងគ្នាដើម្បីទាក់ទាញអ្នកផ្តាច់ខ្លួនពីខ្មែរក្រហមដើម្បីចូលរួមក្នុងបក្សរបស់ខ្លួនដើម្បីបង្កើនកម្លាំង» ។

ការផ្តល់ការលើកលែងទោស អំណាច និងទ្រព្យសម្បត្តិដល់ខ្មែរក្រហមចាត់ទុកថាជាការផ្សះផ្សាជាតិមួយ ។ តែនៅពេលជាមួយគ្នានោះមានមនុស្សជាច្រើនចង់ដឹងពីរឿងរ៉ាវដែលបានកើតឡើង ។ ហេតុអ្វីបានជាអ្នកទាំងនោះរស់នៅក្នុងភាពអត់ឃ្លាន ហើយមនុស្សដែលបង្កការអត់ឃ្លាន ធ្វើទារុណកម្ម និងសម្លាប់អ្នកជាទីស្រឡាញ់របស់គាត់ ត្រូវបានការពារនិងផ្តល់នូវទ្រព្យសម្បត្តិនិងអំណាច?

កង្វះខាតក្នុងការចែករំលែក និងការចូលរួមជាសាធារណៈនៅក្នុងវិធីដើម្បីដោះស្រាយរឿងរ៉ាវពីអតីតកាលត្រូវចាត់ទុកថាជាប្រការមិនផ្តល់អំណាចដល់ប្រជាជនកម្ពុជា ។ ប្រការនេះអាចជាឧបសគ្គក្នុងការដើរចេញពីអំពើឃោរឃៅពីអតីតកាលដើម្បីបង្កើតសង្គមអនាគតមួយប្រកបដោយសន្តិភាពយូរអង្វែង លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍ ។

**(នៅមានត)**

**ថ្មីធីល ក្រូឌឹម**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុFM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជារៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា និង គាត លក្ខិណា**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្ដើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្ដល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្ដី ស្ដាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្ដល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង លី សុខឃាង តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។


ក្រុមហាគិម-ទួន កំពុងបំពេញពាក្យបណ្ដឹង


ក្រុមហាគិម-ទួន កំពុងបំពេញពាក្យបណ្ដឹង

# អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## នៅក្នុងបញ្ហានៃការធ្វើបណ្តឹងឧទ្ធរណ៍ដោយ កាំង ហ្គេកអ៊ាវ (ឌុច) ទៅនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់សហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ សំណុំរឿងលេខ ០០២,១៨-០៨-២០០៦

## សារណារបស់ អែន ហែនដែល ទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងនាមការបញ្ចេញយោបល់ផ្ទាល់ខ្លួន ៨ តុលា ២០០៧


### សេចក្តីសង្ខេប

សារណានេះត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងជាសាធារណៈរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះវិសាមញ្ញ) ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០០៧ ដែលអនុញ្ញាតឲ្យមានការផ្តល់សារណាដោយអ្នកមិនមែនជាភាគីនៃរឿងក្តីដោយអនុលោមទៅតាមមាត្រា៣៣ នៃវិធានផ្ទៃក្នុង ។ សារណានេះនឹងដោះស្រាយការរកឃើញដោយសហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញដែលថា «ខ្លួនមិនមានយុត្តាធិការដើម្បីសម្រេចភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ឌុច» ដោយតុលាការយោធាកម្ពុជាទេ ។ ដូច្នេះ សារណានេះមិនពិភាក្សាអំពីច្បាប់ដែលមានអានុភាពចំពោះការសម្រេចថាតើសិទ្ធិទទួលបានដំណើការជំនុំជម្រះត្រឹមត្រូវរបស់ ឌុច ត្រូវបានរំលោភបំពានដែរឬអត់នោះទេ ហើយសារណានេះក៏មិនបញ្ចេញយោបល់ទាក់ទងនឹងថាតើឌុចមានសិទ្ធិទទួលបាននូវការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នឬទទួលបានដំណោះស្រាយផ្សេងពីនេះនោះទេ ។

ឌុច បានធ្វើបណ្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកាចេញដោយសហចៅក្រមស៊ើបអង្កេតដែលអនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្នក្រោមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ហើយ ឌុច ក៏កំពុងស្វែងរក «ការដោះលែងភ្លាមៗ» ដោយគ្មានលក្ខខណ្ឌឬដោយបង់ប្រាក់ធានា ។ ដីកាឃុំខ្លួនបណ្តោះអាសន្នបានពិចារណាដល់ទ្រឹស្តីចំនួនពីរ ដែលតាមរយៈនេះការឃុំខ្លួនកាលពីមុនរបស់ ឌុច អាចទំនងជាបណ្តាលមកពីអង្គជំនុំជម្រះវិសាមញ្ញ ហើយតាមរយៈទ្រឹស្តីទាំងពីរនេះអាចបណ្តាលឲ្យអង្គជំនុំជម្រះវិសាមញ្ញបាត់បង់នូវយុត្តាធិការរបស់ខ្លួន ។ ដោយរកឃើញថា ទ្រឹស្តីទាំងពីរនេះមិនមានអានុភាពអនុវត្តនៅក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចថា ខ្លួនមិនមានយុត្តាធិការដើម្បីសម្រេចអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ឌុចនៅក្នុងដំណាក់កាលជំនុំជម្រះពេលនេះទេ ប៉ុន្តែមិនបានច្រានចោលនូវលទ្ធភាពដែលថា ឌុច អាចមានសិទ្ធិទទួលបាននូវដំណោះស្រាយ នៅក្នុងសាលក្រមចុងបញ្ចប់នោះដែរ ។ សហចៅក្រមស៊ើបអង្កេតមិនបានដោះស្រាយនូវទ្រឹស្តីផ្សេងទៀត ដូចជាថាតើ ឌុច ត្រូវបានដាក់ឲ្យនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នដែល «មានប្រយោជន៍» របស់អង្គជំនុំជម្រះវិសាមញ្ញ ។ ជាងនេះទៅទៀត ដោយសារខ្លួនមិនបានពិនិត្យមើលអំពីចរិតគតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញដែលជាស្ថាប័ន *sui generis* និងមិនបានគិតដល់ថាតើវាមានកាតព្វកិច្ចដូចគ្នាឬស្រដៀងគ្នាទៅនឹងតុលាការកម្ពុជាដើម្បីដោះស្រាយបញ្ហារំលោភដំណើរជំនុំជម្រះនោះទេ ។ នៅចុងបញ្ចប់យុត្តិសាស្ត្រទាំងតុលាការសិទ្ធិមនុស្សនិងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិបានបង្ហាញថាសូម្បីតែការរំលោភសិទ្ធិរបស់ឌុចមិនបណ្តាលមកពីអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ នៅក្នុងការពិចារណាថាការឃុំឃាំងបណ្តោះអាសន្នត្រឹមត្រូវឬអត់ អង្គជំនុំជម្រះវិសាមញ្ញមានទាំង

អំណាចនិងកាតព្វកិច្ចនៅក្នុងការពិចារណាអំពីភាពស្របច្បាប់និងរយៈពេលនៃការឃុំខ្លួនរបស់ឌុច កាលពីមុន ។

## អ្នកផ្តល់សារណា

បច្ចុប្បន្ន អែន ហែនដែល ជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ។ អែន ហែនដែល ធ្លាប់ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិអស់រយៈពេលជាង១០ឆ្នាំ និងជាសមាជិកនៃគណៈមេធាវីរបស់រដ្ឋកាលីហ្វញ៉ា នៅសហរដ្ឋអាមេរិក ។ យោបល់ដែលបញ្ចេញនៅក្នុងសារណានេះគឺជាយោបល់ផ្ទាល់ខ្លួន ហើយការយល់ឃើញទាំងនេះគឺមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលនយោបាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។

## I. ការទទួលខុសត្រូវរបស់អង្គជំនុំជម្រះវិសាមញ្ញចំពោះការរំលោភការឃុំខ្លួនបណ្តោះអាសន្នដោយតុលាការកម្ពុជាអាចអាស្រ័យលើលក្ខណៈគតិយុត្តរបស់ខ្លួន

### ក) អង្គជំនុំជម្រះវិសាមញ្ញជាតុលាការជាតិដែលមានលក្ខណៈអន្តរជាតិ

១) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដោយយោងទៅតាមកិច្ចព្រមព្រៀងអន្តរជាតិរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាដែលបានបង្កើតជា "មូលដ្ឋានគតិយុត្ត និងគោលការណ៍ និងបែបបទសម្រាប់...សហប្រតិបត្តិការ[របស់ពួកគេ]" ។ កិច្ចព្រមព្រៀងនេះត្រូវបានអនុម័តដោយច្បាប់កម្ពុជា និងត្រូវបានអនុវត្តតាមរយៈការអនុម័តច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ដោយយោងទៅតាមកិច្ចព្រមព្រៀងនិងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញអង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងជាផ្នែកមួយនៃ "រចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់" ដោយ "មានជំនួយពីអន្តរជាតិ" ។

២) ដូច្នេះអង្គជំនុំជម្រះវិសាមញ្ញជាតុលាការកម្ពុជាបង្កើតឡើងដោយយោងទៅតាមច្បាប់កម្ពុជា ។ ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញនេះមានលក្ខណៈខ្លះៗដូចទៅនឹងតុលាការអន្តរជាតិ ។ ដោយសារមូលហេតុនេះ ឧបនាយករដ្ឋមន្ត្រីកម្ពុជាលោក សុខ អាន បានហៅអង្គជំនុំជម្រះវិសាមញ្ញថាជា "តុលាការជាតិដែលមានលក្ខណៈអន្តរជាតិ" ។ លោកឧបនាយករដ្ឋមន្ត្រីបានធ្វើការកត់សម្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញជា "តុលាការចម្រុះឬតុលាការកូនកាត់ដែលស្ថិតនៅក្នុងតុលាការជាតិ ប៉ុន្តែមានប្រើប្រាស់ទាំងច្បាប់ជាតិនិងអន្តរជាតិ មានចៅក្រម ព្រះរាជអាជ្ញានិងបុគ្គលិកទាំងជាតិនិងអន្តរជាតិ និងប្រើប្រាស់ហិរញ្ញវត្ថុជាតិនិងអន្តរជាតិ" ។

៣) លក្ខណៈគតិយុត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ ទោះជាតុលាការជាតិឬតុលាការអន្តរជាតិ ឬជាអ្វីមួយនៅចន្លោះកណ្តាលនេះ គឺមានសារសំខាន់ណាស់ព្រោះវាអាចមានឥទ្ធិពលទៅលើបញ្ហាមួយចំនួនដែលអាចកើតឡើងនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញនេះ ដែលរួមទាំងការទទួលខុសត្រូវរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការដោះស្រាយចំពោះការរំលោភបំពានលើសិទ្ធិរបស់លោក កាំង ហ្កេកអ៊ាវ (ឌុច) នៅខណៈពេលដែលបុគ្គលនេះត្រូវឃុំខ្លួនដោយតុលាការយោធាអស់រយៈពេល៨ឆ្នាំដោយមិនបានធ្វើការជំនុំជម្រះ ។ តាមការពិត នៅពេលចេញដីកាឃុំខ្លួនបណ្តោះអាសន្នឌុចដោយអង្គជំនុំជម្រះវិសាមញ្ញ សហចៅក្រមស៊ើបអង្កេតបានសង្កត់ធ្ងន់ថា បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញ "ត្រូវបានបង្កើតឡើងនៅក្នុងអង្គការតុលាការកម្ពុជា...[អង្គជំនុំជម្រះវិសាមញ្ញ] ជាស្ថាប័នឯករាជ្យមានរចនាសម្ព័ន្ធដាច់ដោយឡែកពីយុត្តាធិការជាតិដទៃទៀត" ។ ជាលទ្ធផល នៅក្នុងការសម្រេចអំពីសមត្ថកិច្ចនៅក្នុងការជំនុំជម្រះអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ឌុច សហចៅក្រមស៊ើបអង្កេតមិនបានគិតដល់កាតព្វកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញជាតុលាការកម្ពុជាក្នុងស្រុកទេ ។

៤) នៅក្នុងការវាយតម្លៃអំពីលក្ខណៈគតិយុត្តរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលសាធារណជនគិតថាជាតុលាការកូនកាត់ដូចគ្នាដែរ អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការនេះបានគិតគូរដល់ទិដ្ឋភាពមួយចំនួននៃទំនាក់ទំនងរបស់តុលាការពិសេសនេះទៅនឹងសហគមន៍អន្តរជាតិមុនពេលដែលចេញសេចក្តីសម្រេចថា តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូននេះជាតុលាការអន្តរជាតិ ។ អង្គជំនុំជម្រះឧទ្ធរណ៍របស់តុលាការពិសេសនេះបានកត់សម្គាល់ថា តុលាការពិសេសនេះជា "យុត្តាធិការថ្មីមួយមានដំណើរការនៅក្នុងមជ្ឈដ្ឋានច្បាប់អន្តរជាតិ" ដែល "មានសមត្ថកិច្ចជំនុំជម្រះ" តាមរយៈសន្ធិសញ្ញារវាងអង្គការសហប្រជាជាតិនិងសេរ៉ាឡេអូន ។ ដូច្នេះអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ

ពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូននេះបានចេញសេចក្តីសម្រេចថា តុលាការនេះជា «ស្ថាប័នស្វយ័តនិងឯករាជ្យ» និងមិនមែនជាផ្នែកមួយនៃប្រព័ន្ធយុត្តិធម៌ក្នុងស្រុករបស់សៀរ៉ាឡេអូនទេ ។ បើយើងធ្វើការប្រៀបធៀបដូចដែលបានពិភាក្សាពីខាងលើអង្គជំនុំជម្រះវិសាមញ្ញគឺជាយុត្តាធិការថ្មីដែលបង្កើតឡើងដោយយោងទៅតាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាផង និងជាតុលាការកម្ពុជាដែលបង្កើតឡើងដោយយោងទៅតាមច្បាប់កម្ពុជាផង ។ ថ្វីបើអង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការពិសេសរបនាសម្ព័ន្ធឯករាជ្យ និងមានបុគ្គលិកអង្គការសហប្រជាជាតិក៏ដោយក៏ស្វយ័តភាពរបស់អង្គជំនុំជម្រះវិសាមញ្ញពីប្រព័ន្ធយុត្តិធម៌កម្ពុជាគឺមិនច្បាស់លាស់ទេ ។ ជាក់ស្តែងនៅខណៈពេលដែលច្បាប់បង្កើតតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនយ៉ាងច្បាស់លាស់បានផ្តល់ឲ្យតុលាការពិសេសនូវឧត្តមភាពយុត្តាធិការខ្ពស់ជាងតុលាការជាតិរបស់សៀរ៉ាឡេអូន ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញមិនបានចែងអំពីទំនាក់ទំនងឋានានុក្រមរវាងអង្គជំនុំជម្រះវិសាមញ្ញ និងតុលាការកម្ពុជាផ្សេងទៀតទេ ។ នៅពេលដែលតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនអាចប្រើប្រាស់វិធានជាធរមានរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងអាចធ្វើវិសោធនកម្មវិធានទាំងនោះ ឬអាចអនុម័តវិធានថ្មីតាមការចាំបាច់នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវតែ «ស្របទៅនឹងច្បាប់កម្ពុជា» ដោយមានការណែនាំពីវិធាននីតិវិធីអន្តរជាតិ តែនៅពេលដែលមានការខ្វះចន្លោះ [នៅក្នុងនីតិវិធីជាតិ] មិនច្បាស់លាស់នៅក្នុងការបកស្រាយ ឬនៅពេលមានបញ្ហាទាក់ទងទៅនឹងភាពសមស្របជាមួយបទដ្ឋាននីតិវិធីអន្តរជាតិ ។

៥) ចំណុចខុសគ្នាផ្សេងទៀតរវាងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន និងអង្គជំនុំជម្រះវិសាមញ្ញបានបង្ហាញអំពីកម្រិតនៃឯករាជ្យភាពរបស់អង្គជំនុំជម្រះវិសាមញ្ញពីកម្ពុជា ។ ខណៈពេលដែលតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនមាន «លទ្ធភាពអាចចុះកិច្ចព្រមព្រៀងជាមួយនីតិបុគ្គលអន្តរជាតិផ្សេងៗដែលគ្រប់គ្រងដោយច្បាប់អន្តរជាតិ» អង្គជំនុំជម្រះវិសាមញ្ញហាក់ដូចជាមិនមានអំណាចបែបនេះទេ ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ផងដែរនោះគឺការណ៍ដែលថា លក្ខន្តិកៈរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានហាមឃាត់មិនឲ្យមានការផ្តល់ការលើកលែងទោសចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិទៅឲ្យអ្នកដែលធ្លាក់មកក្នុងយុត្តាធិការរបស់តុលាការពិសេសនេះទេ ចំណែកឯអង្គជំនុំជម្រះវិសាមញ្ញវិញបានចែងត្រឹមតែថា «វិសាលភាពនៃការលើកលែងទោស...ដែលត្រូវបានផ្តល់ឲ្យមុនពេលអនុម័តច្បាប់នេះគឺនឹងត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ» ។ នេះអាចបង្ហាញអំពីភាពមិនច្បាស់លាស់ដោយអង្គការសហប្រជាជាតិទាក់ទងទៅនឹងលក្ខណៈគតិយុត្តរបស់អង្គជំនុំជម្រះដោយឡែកនៅក្នុងពេលថ្មីៗកន្លងមកនេះ អង្គការសហប្រជាជាតិបានប្រកាន់យកនូវគោលជំហររឹងមាំប្រឆាំងនឹងការផ្តល់ការលើកលែងទោសចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ។ ចុងក្រោយបំផុត ខុសប្លែកពីតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនដែរ ប្រសិនបើបុគ្គលិកអង្គការសហប្រជាជាតិ «ខកខានមិនបានឬបដិសេធមិនចូលរួមនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬប្រសិនបើអង្គការសហប្រជាជាតិត្រូវដកការគាំទ្ររបស់ខ្លួនចេញពីអង្គជំនុំជម្រះវិសាមញ្ញ ហើយមិនមានបេក្ខជនបទេសដើម្បីបំពេញតួនាទីទំនេរទាំងនោះ រដ្ឋាភិបាលកម្ពុជាប្រហែលជាអាចរើសបេក្ខជនកម្ពុជាមកបំពេញជំនួស» ។ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញបានមើលឃើញជាមុនអំពីលទ្ធភាពដែលថានៅក្រោមលក្ខខណ្ឌខ្លះអង្គជំនុំជម្រះវិសាមញ្ញអាចបន្តដំណើរការរបស់ខ្លួនដោយគ្មានការគាំទ្រពីអន្តរជាតិ ឬដោយគ្មានបុគ្គលិកអន្តរជាតិ ។

៦) ម្យ៉ាងវិញទៀត អង្គជំនុំជម្រះវិសាមញ្ញដូចតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនដែរ ត្រូវគេគិតថាជាយន្តការយុត្តិធម៌អន្តរជាតិមួយ ។ ឧទាហរណ៍សាលាឧទ្ធរណ៍នៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនបានបង្ហាញអំពីការណ៍ដែលថាសន្ធិសញ្ញាបង្កើតតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូនគឺជាកិច្ចព្រមព្រៀងក្នុងនាម «សមាជិកទាំងអស់នៃអង្គការសហប្រជាជាតិជាមួយប្រទេសសៀរ៉ាឡេអូន» ដូច្នេះសន្ធិសញ្ញានេះជា «ឆន្ទៈរបស់សហគមន៍អន្តរជាតិ» ។ សាលាឧទ្ធរណ៍នៃតុលាការពិសេសនេះបានសម្រេចថា «អំណាចគតិយុត្តដែលអនុវត្តដោយតុលាការពិសេសគឺមិនមែនជារបស់ប្រទេសសៀរ៉ាឡេអូន

ទេ ប៉ុន្តែអំណាចគតិយុត្តរបស់តុលាការពិសេសនេះគឺផ្ទុះបញ្ចាំង អំពីផលប្រយោជន៍របស់សហគមន៍អន្តរជាតិ» ។ ស្រដៀងគ្នាដែរ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជាគឺជាលទ្ធផល នៃការចរចាអន្តរជាតិអស់រយៈពេលជាច្រើនឆ្នាំ ហើយអាច សម្រេចដោយសារតែមានការជំរុញពីមហាសន្និបាតសហប្រជាជាតិ ប៉ុណ្ណោះ ។

៧) ជាងនេះទៅទៀត ដូចតុលាការពិសេសសម្រាប់ប្រទេស សៀរ៉ាឡេអូនដែរ អង្គជំនុំជម្រះវិសាមញ្ញអាចនិយាយបានថា បង្កើតឡើងដើម្បី «បំពេញកិច្ចការអន្តរជាតិ» ។ កិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិនិងកម្ពុជារបស់អង្គជំនុំជម្រះវិសាមញ្ញ បានសង្កត់ធ្ងន់ថា ការណ៍ដែលថា «ការរំលោភធ្ងន់ធ្ងរលើច្បាប់ មនុស្សធម៌ជាតិ និងអន្តរជាតិនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិប តេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ នៅតែជាបញ្ហាព្រួយបារម្ភ យ៉ាងសំខាន់ចំពោះសហគមន៍អន្តរជាតិទាំងមូល» ។ លោកនាយក រដ្ឋមន្ត្រី ហ៊ុន សែន បានបន្ទរត្រង់ចំណុចនេះថា «ឧក្រិដ្ឋកម្ម [ដោយ ខ្មែរក្រហម] ត្រូវបានប្រព្រឹត្តឡើងមិនត្រឹមតែប្រឆាំងនឹងប្រជាជន កម្ពុជាទេ ថែមទាំងប្រឆាំងនឹងមនុស្សជាតិទាំងមូល» ។ ដោយសារ មូលហេតុនេះ លោកនាយករដ្ឋមន្ត្រីបានមើលឃើញថា វាជារឿង «សមរម្យដែលថា ចៅក្រម ព្រះរាជអាជ្ញា និង មេធាវីទាំងជាតិ និងអន្តរជាតិនឹងធ្វើការជាមួយគ្នានៅក្នុងកិច្ចការនាំយកអ្នកទទួល ខុសត្រូវខ្ពស់បំផុតនិងបានជួយបង្កើតនូវវប្បធម៌មួយដែលនឹងការ ពារការកើតឡើងម្តងទៀតនូវឧក្រិដ្ឋកម្មបែបនេះនៅកន្លែងផ្សេង ទៀតនៅក្នុងពិភពលោក» ។

៨) ដោយសារអង្គជំនុំជម្រះវិសាមញ្ញមិនមែនជាតុលាការ ជាតិទាំងស្រុង ឬតុលាការអន្តរជាតិទាំងស្រុង អង្គជំនុំជម្រះវិសាមញ្ញ នឹងទំនងជាត្រូវពិចារណាអំពីលក្ខណៈគតិយុត្តរបស់ខ្លួននិងច្បាប់ មួយណាដែលនឹងត្រូវអនុវត្តទៅតាមសំណុំរឿងនីមួយៗ ។

**១) ត្រឹមកម្រិតដែលថាអង្គជំនុំជម្រះវិសាមញ្ញជាផ្នែកមួយ នៃប្រព័ន្ធយុត្តិធម៌កម្ពុជា អង្គជំនុំជម្រះវិសាមញ្ញមានកាតព្វកិច្ចនៅ ក្រោមច្បាប់សិទ្ធិមនុស្សក្នុងការដោះស្រាយបញ្ហារំលោភបំពាន ផ្សេងៗ ដោយតុលាការកម្ពុជាក្នុងស្រុក ។**

៩) ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថាៈ

សាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការ របស់ខ្លួនឲ្យបានសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹម ត្រូវនឹងដំណើរការសមស្របនៃច្បាប់ដូចដែលមានចែងនៅក្នុង មាត្រា១៤ និងមាត្រា១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ស្តី អំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

ជាងនេះទៅទៀតក្នុងនាមជាភាគីសមាជិកមួយរបស់អនុ សញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋាភិបាលកម្ពុជារួម ទាំងផ្នែកផ្សេងៗរបស់រដ្ឋាភិបាលមានកាតព្វកិច្ច «គោរពនិងធានា ដល់បុគ្គលដែលស្ថិតនៅក្នុងទឹកដីនិងស្ថិតក្រោមយុត្តាធិការរបស់ ខ្លួននូវសិទ្ធិដែលមានទទួលស្គាល់នៅក្នុង......អនុសញ្ញា» ដែលរួម ទាំងសិទ្ធិទទួលបាននូវការជំនុំជម្រះ «ដោយគ្មានការពន្យារពេល» ។ ដូច្នេះរដ្ឋាភិបាលមិនអាចប្រើប្រាស់ច្បាប់ក្នុងស្រុកដែលរួមទាំង ការបែងចែកអំណាចរវាងតុលាការយោធា និងអង្គជំនុំជម្រះ វិសាមញ្ញដើម្បីធ្វើការដោះសារចំពោះការខកខានមិនបានបំពេញ កាតព្វកិច្ចនេះទេ ។ ដូច្នេះនៅក្នុងកម្រិតដែលថា អង្គជំនុំជម្រះ វិសាមញ្ញជាតុលាការជាតិរបស់កម្ពុជា ត្រូវតែ «ផ្តល់ប្រសិទ្ធភាព ទៅឲ្យសិទ្ធិដែលទទួលស្គាល់នៅក្នុង....អនុសញ្ញា» ដែលរួមទាំង «ធានា ថាបុគ្គលដែលទាមទាររកដំណោះស្រាយ[ដែលមានប្រសិទ្ធភាព] នឹងទទួលបាននូវការសម្រេចដោយអំណាច...តុលាកាមានសមត្ថ-កិច្ច» ។ តាមការពិតគណៈកម្មាការសិទ្ធិមនុស្សបានថ្លែងថា តម្រូវការ នេះ «គឺមានភាពចាំបាច់និងមានប្រសិទ្ធភាពភ្លាមៗ» ។ ដោយសារ មូលហេតុនេះៈ

សិទ្ធិទទួលបានដំណោះស្រាយយ៉ាងមានប្រសិទ្ធភាពនៅក្នុង ករណីខ្លះអាចតម្រូវឲ្យរដ្ឋសមាជិកចែង ឬចាត់វិធានការបណ្តោះ អាសន្នដើម្បីចៀសវាងបន្តការរំលោភបំពាន និងដើម្បីព្យាយាម ឲ្យអស់សមត្ថភាពដើម្បីជួសជុលឲ្យបានឆាប់បំផុតនូវការខូចខាត ដែលអាចកើតចេញពីការរំលោភបំពាននោះ ។

ដំណោះស្រាយចំពោះការរំលោភបំពានលើសិទ្ធិមនុស្ស អាចរួមមានការសងជំងឺចិត្ត ការកាត់បន្ថយទោស និងការដោះលែង «ដោយពិចារណាទៅលើកម្មវត្ថុ ក៏ដូចជាលក្ខណៈនៃសិទ្ធិដែលត្រូវ ចោទប្រកាន់ថាបានរំលោភបំពាននោះ» ។ ឧទាហរណ៍ នៅពេល ដែលជនជាប់ចោទម្នាក់ត្រូវជាប់នៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន

*អស់រយៈពេល៥ឆ្នាំដែលផ្ទុយគ្នាទៅនឹងនីតិវិធីក្នុងស្រុក គណៈ-កម្មការសិទ្ធិមនុស្សបានថ្លែងថា បន្ថែមទៅលើទទួលបានសំណងជំងឺចិត្ត ជនជាប់ចោទគួរតែត្រូវដោះលែងសិន រង់ចាំសាលក្រមចុងក្រោយ ។ នៅពេលដែលជនជាប់ចោទត្រូវបានឃុំឃាំងរយៈពេល៩ឆ្នាំដោយមិនទទួលបាននូវការជំនុំជម្រះគណៈកម្មការសិទ្ធិមនុស្សបានថ្លែងថាៈ*

*រដ្ឋសមាជិក[របស់អនុសញ្ញាសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ] មានកាតព្វកិច្ចផ្តល់ឲ្យម្ចាស់ពាក្យបណ្តឹង[ទៅគណៈកម្មាធិការសិទ្ធិមនុស្ស] នូវដំណោះស្រាយដែលមានប្រសិទ្ធភាពដែលត្រូវមានសំណងជំងឺចិត្តគ្រប់គ្រាន់សម្រាប់រយៈពេលចំណាយនៅក្នុងការឃុំឃាំងមិនស្របច្បាប់ ។ រដ្ឋសមាជិកក៏មានកាតព្វកិច្ចផងដែរក្នុងការធានាថា ម្ចាស់ពាក្យបណ្តឹងទទួលបាននូវការជំនុំជម្រះទាន់ពេលវេលាដោយមាននូវការធានាទាំងឡាយចែងនៅក្នុងមាត្រា១៤ ឬប្រសិនបើមិនអាចទេត្រូវដោះលែង ។*

**ក) ត្រឹមកម្រិតដែលថាអង្គជំនុំជម្រះវិសាមញ្ញជាតុលាការអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញត្រូវទទួលខុសត្រូវចំពោះការរំលោភបំពានសិទ្ធិរបស់ ឌុច នៅពេលដែល ឌុច ស្ថិតក្រោម «ការឃុំឃាំងមានប្រយោជន៍» របស់ខ្លួន ។**

*១១) សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថា នៅពេលដែលសាលាជំនុំជម្រះក្តីនេះរួមចំណែក «ការឃុំខ្លួនមានប្រយោជន៍» លើជនជាប់ចោទឃុំឃាំងដោយយុត្តាធិការជាតិ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាត្រូវពិចារណាថាតើការឃុំខ្លួនកាលពីមុនបានរំលោភលើបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិដែរឬទេ? ហើយប្រសិនបើមានការរំលោភមែន សាលាជំនុំជម្រះក្តីត្រូវផ្តល់ដំណោះស្រាយសមរម្យ ។ នៅក្នុងសំណុំរឿងបារ៉ាយ៉ាវីហ្សា បានប្តឹងនៅក្នុងចំណោមបញ្ហាផ្សេងទៀតអំពីរយៈពេលឃុំខ្លួនបណ្តោះអាសន្នរបស់គាត់នៅក្នុងប្រទេសកាមេរូន មុនពេលត្រូវបញ្ជូនទៅដាក់ក្រោមការឃុំខ្លួនរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ មុនដំបូង ជនជាប់ចោទត្រូវឃុំខ្លួនក្រោមសំណើបត្យាប័នរបស់រដ្ឋ ប៉ុន្តែបន្ទាប់ពីសំណើទាំងនេះត្រូវទាត់ចោល ប្រទេសកាមេរូនបានឃុំខ្លួនជនជាប់ចោទអស់រយៈពេលជិត៩ខែតាមរយៈការស្នើសុំដោយព្រះរាជអាជ្ញារបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា មុនពេលដែលជនជាប់ចោទត្រូវបានចោទប្រកាន់និងបញ្ជូនទៅកាន់សាលាជំនុំជម្រះក្តី ។ សាលាឧទ្ធរណ៍នៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថា ខ្លួនត្រូវតែពិចារណា «ទំនាក់ទំនងរវាងកាមេរូននិងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាទាក់ទងនឹងការឃុំខ្លួនរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍» ដើម្បីសម្រេចថាតើសាលាជំនុំជម្រះក្តីសម្រាប់ប្រទេសរ៉្វាន់ដានេះមានការឃុំខ្លួនមានប្រយោជន៍នេះទៅលើជនជាប់ចោទនៅក្នុងរយៈពេលនេះ ។*

*១២) ដោយយោងទៅតាមសាលាឧទ្ធរណ៍នៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា «បើទោះបីជាជនជាប់ចោទមិនមានរូបរាងនៅក្នុងមន្ទីរឃុំឃាំងរបស់សាលាជំនុំជម្រះក្តីក៏ដោយ ម្ចាស់បណ្តឹងឧទ្ធរណ៍នេះគឺស្ថិតនៅក្នុងការឃុំខ្លួនរបស់សាលាជំនុំជម្រះក្តី ប្រសិនបើគាត់ត្រូវបានឃុំខ្លួនដោយយោងទៅតាម «ដំណើរការឬអំណាចស្របច្បាប់» របស់សាលាជំនុំជម្រះក្តីនេះ ។ នៅក្នុងករណីនេះ សាលាឧទ្ធរណ៍នេះបានថ្លែងថា «ប្រសិនបើមិនមាន» សំណើរបស់ព្រះរាជអាជ្ញាឲ្យមានការឃុំខ្លួនបណ្តោះអាសន្នទេ បារ៉ាយ៉ាវីហ្សានឹងត្រូវដោះលែងនៅពេលសំណើបត្យាប័នរបស់រដ្ឋត្រូវបានបដិសេធ ។ សាលាឧទ្ធរណ៍នេះបានមើលឃើញស្ថានភាពនោះស្រដៀងទៅនឹងៈ*

*ដំណើរការ«ឃាត់ទុក» ដែលតាមរយៈនេះ ដីកាប្រភេទពិសេសមួយ...ត្រូវបានធ្វើឡើងប្រឆាំងទៅនឹងបុគ្គលម្នាក់ដែលជាប់ឃុំឃាំងរួចហើយដើម្បីធានាថា បុគ្គលនោះនឹងមានមុខសម្រាប់អាជ្ញាបន្ទាប់ពីបញ្ចប់រយៈពេលឃុំខ្លួនបច្ចុប្បន្ន ។ «ការឃាត់ទុក» គឺជារបស់ម្យ៉ាង ដែលតាមរយៈនេះរដ្ឋស្នើសុំអាចទទួលបានការឃុំខ្លួនរបស់ជនជាប់ឃុំឃាំងនោះ បន្ទាប់ពីបុគ្គលនោះត្រូវបានដោះលែងដោយរដ្ឋដែលឃុំខ្លួន ។*

*នៅក្នុងករណីបែបនោះ តុលាការក្នុងស្រុកបានថ្លែងថា «ជនជាប់ចោទគឺស្ថិតនៅក្នុងការឃុំឃាំងដែលមានប្រយោជន៍របស់រដ្ឋស្នើសុំ ហើយ...រដ្ឋដែលឃុំខ្លួនជនជាប់ចោទដើរតួជាភ្នាក់ងារសម្រាប់រដ្ឋស្នើសុំដើម្បីគោលបំណង...ជំទាស់[ទៅនឹងភាពស្រប*

ច្បាប់នៃការឃុំខ្លួននោះ]» ។ តុលាការក្នុងស្រុកបានសង្កត់ធ្ងន់ថា នៅក្នុងសំណុំរឿងនេះដែលកំពុងពិនិត្យមើលឡើងវិញដោយតុលាការ «ទំនាក់ទំនងរវាងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងប្រទេសកាមេរូនគឺកាន់តែខ្លាំងជាងនេះទៅទៀតដោយសំអាងទៅលើមូលដ្ឋាននៃកាតព្វកិច្ចអន្តរជាតិផ្តល់ឲ្យរដ្ឋដោយក្រុមប្រឹក្សាសន្តិសុខសហប្រជាជាតិក្រោម....ច្បាប់លក្ខន្តិកៈ[បង្កើតសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា]» ។

១៣) ដូចគ្នាដែរ នៅក្នុងសំណុំរឿង ខាដេលីដេលី សាលាឧទ្ធរណ៍បានពិចារណាទំនាក់ទំនងរវាងរដ្ឋឃុំខ្លួននិងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានៅក្នុងការសម្រេចអំពីការទទួលខុសត្រូវរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាចំពោះការរំលោភបំពានសិទ្ធិរបស់ជនជាប់ចោទពេលនៅក្នុងការឃុំខ្លួនដោយរដ្ឋ ។ សាលាឧទ្ធរណ៍បានសម្រេចថា «បើទោះបីជាការរំលោភបំពាន[សិទ្ធិរបស់ជនជាប់ចោទ] មិនមែនបណ្តាលទាំងស្រុងមកពីសាលាជំនុំជម្រះក្តីនេះក៏ដោយ ក៏គេដឹងថា គឺអយ្យការដែលជាផ្នែកមួយរបស់សាលាជំនុំជម្រះក្តីជាស្ថាប័នស្នើសុំដែលទទួលខុសត្រូវសម្រាប់ការជំរុញឲ្យមានការចាប់ខ្លួន និងការឃុំខ្លួននៅក្នុងប្រទេសបេនីន» ។ ដោយសារអយ្យការបាន «ខកខានមិនបំពេញកាតព្វកិច្ចចោទប្រកាន់របស់ខ្លួនឲ្យបានប្រុងប្រយ័ត្ន» ការរំលោភសិទ្ធិឃុំខ្លួនរបស់ជនជាប់ចោទនៅក្នុងរដ្ឋឃុំខ្លួនគឺបណ្តាលមកពីសាលាជំនុំជម្រះព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។

១៤) ស្រដៀងគ្នាដែរ នៅក្នុងសំណុំរឿងសេមិនហ្សា សាលាឧទ្ធរណ៍នៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថា ការឃុំខ្លួនជនជាប់ចោទនៅក្នុងប្រទេសកាមេរូនអស់រយៈពេលជាង៧ខែតាមរយៈសំណើរបស់អយ្យការ គឺមិនមែនបណ្តាលមកពីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាទេ ។ សាលាឧទ្ធរណ៍នេះបានសម្រេចថា រយៈពេលខ្លីមុនពេលផ្ទេរជនជាប់ចោទទៅកាន់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាគឺដោយសារតែ «កង្វះនយោបាយនិងច្បាប់»ដែលរួមមានគំនាបសង្កត់ប្រទេសកាមេរូនឲ្យផ្ញើបត្យាប័នបុគ្គលនេះទៅកាន់រដ្ឋមួយទៀត និងរង់ចាំការបោះឆ្នោតជាតិ ។ ហើយនៅក្នុងសំណុំរឿង លូបាងហ្គា សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានថ្លែងថា «ការដឹងតែមួយមុខនៅខាងអយ្យការនូវការស៊ើបអង្កេតដោយអាជ្ញាធរ[ជាតិ] គឺមិនបានបង្ហាញភ័ស្តុតាងនៃការចូលរួមដោយអយ្យការនៅក្នុងរបៀបដែលខ្លួនធ្វើការស៊ើបអង្កេត ឬមធ្យោបាយផ្សេងៗដែលរួមទាំងការឃុំខ្លួនដែលប្រើប្រាស់ដើម្បីគោលបំណងនេះ» ។ សាលាឧទ្ធរណ៍នេះក៏បានសង្កត់ធ្ងន់ដែរថា ការឃុំខ្លួនរបស់ជនជាប់ចោទនៅក្នុងរដ្ឋឃុំឃាំងគឺសម្រាប់ឧក្រិដ្ឋកម្មដែល «ខុសគ្នានិងដោយឡែក» ពីបទឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

១៥) ដូចដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ឌុច «ចាប់ពីខែកុម្ភៈ ឆ្នាំ២០០២មក ការចោទប្រកាន់និងដីកាសម្រេចឃុំខ្លួន និងបន្តឃុំខ្លួន កាំង ហ្គេកអ៊ាវ បានធ្វើឡើងដោយផ្អែកទៅលើ [ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ]» និងផ្អែកទៅលើឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការ ។ តើអង្គហេតុទាំងនេះបន្ថែមនូវកត្តាផ្សេងៗទៀតដូចជាលក្ខណៈរបស់អង្គជំនុំជម្រះវិសាមញ្ញជាតុលាការជាតិគ្រប់គ្រាន់ដើម្បីបង្កើតជា «ការឃុំខ្លួនមានប្រយោជន៍» របស់ឌុច ដោយអង្គជំនុំជម្រះឬទេ នេះជាសំណួរដែលគួរតែពិនិត្យមើល ។

១៦) ប្រសិនបើតុលាការអន្តរជាតិយល់ថាការឃុំខ្លួនមានប្រយោជន៍របស់ជនជាប់ចោទនោះ វារួមចំណែកទទួលខុសត្រូវជាមួយរដ្ឋាភិបាលក្នុងស្រុកចំពោះការរំលោភបំពានលើសិទ្ធិរបស់ចុងចោទ ។ ជាក់ស្តែងនៅក្នុងសំណុំរឿង ខាដេលី ដេលី ជនជាប់ចោទត្រូវចាប់ខ្លួនដោយអាជ្ញាធរក្នុងស្រុកតាមរយៈការស្នើសុំដោយអយ្យការសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា នឹងត្រូវឃុំខ្លួនអស់រយៈពេលជិត៣ខែ ទម្រាំតែមានដីកាចាប់ខ្លួនចេញដោយសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ឬទម្រាំតែត្រូវចោទប្រកាន់ ។ សាលាឧទ្ធរណ៍នៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានសម្រេចថា ទាំងលក្ខន្តិកៈបង្កើតសាលាជំនុំជម្រះក្តីនេះ ឬច្បាប់នីតិវិធីរបស់ខ្លួនមិនបានបញ្ជាក់អំពី «របៀបនិងមធ្យោបាយ»

*នៃការចាប់ខ្លួនរបស់ជនជាប់ចោទឡើយ ។ ផ្ទុយទៅវិញ «វាស្ថិតនៅលើរដ្ឋដែលត្រូវបានគេស្នើសុំជាអ្នកសម្រេចអំពីរបៀបក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្រោមច្បាប់អន្តរជាតិ» ។ ទន្ទឹមនោះដែរ «មានបន្ទុករួមគ្នាទាក់ទងទៅនឹងការការពារសិទ្ធិជាសារវន្តរបស់ជនសង្ស័យនៅក្នុងសហប្រតិបត្តិការអន្តរជាតិទាក់ទងនឹងបញ្ហាឧក្រិដ្ឋកម្ម» ។ ដោយសារអយ្យការមាន «ការទទួលខុសត្រូវត្រួតស៊ីគ្នា» ជាមួយរដ្ឋសហការនៅពេលដែលអយ្យការចាប់ផ្តើមពិនិត្យសំណុំរឿងអយ្យការត្រូវតែធានាថា «សំណុំរឿងនេះបញ្ជូនទៅធ្វើការជំនុំជម្រះតាមរបៀបមួយដែលគោរពដល់សិទ្ធិរបស់ជនជាប់ចោទ» ។ ដូច្នេះ ៖*

*ប្រសិនបើជនជាប់ចោទ [ឬជនសង្ស័យ] ត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយរដ្ឋមួយនៅក្រោមសំណើ ឬក្រោមអំណាចរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សូម្បីតែជនជាប់ចោទមិនទាន់ស្ថិតនៅក្នុងការឃុំខ្លួនពិតប្រាកដរបស់សាលាជំនុំជម្រះក្តីក៏ដោយ សាលាជំនុំជម្រះក្តីមានការទទួលខុសត្រូវក្នុងការផ្តល់ការបន្ធូរបន្ថយដែលអាចធ្វើទៅបាន ដើម្បីព្យាយាមកាត់បន្ថយការរំលោភបំពានផ្សេងៗតាមដែលអាចធ្វើទៅបាន ។*

*១៧) ទាំងច្បាប់លក្ខន្តិកៈបង្កើតសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា និងសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីមិនបានចែងអំពីសិទ្ធិទទួលបានដំណោះស្រាយយ៉ាងមានប្រសិទ្ធភាពចំពោះការរំលោភបំពានដំណើរការជំនុំជម្រះទេ ប៉ុន្តែសាលាដំបូងនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាថ្មីៗនេះបានថ្លែងថា ខ្លួនមានអំណាច «ជាប់មកជាមួយ» ក្នុងការផ្តល់ដំណោះស្រាយដែលរួមមានទាំងការផ្តល់ជំងឺចិត្ត ។ នៅពេលដែលសិទ្ធិជនជាប់ចោទ «ត្រូវរំលោភបំពាន ប៉ុន្តែមិនធ្ងន់ធ្ងរពេកនោះ» សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានឹងកាត់បន្ថយទោសរបស់ជនជាប់ចោទ ប្រសិនបើជនជាប់ចោទនោះរកឃើញថាមានទោស ។ ដូចអង្គជំនុំជម្រះវិសាមញ្ញដែរសាលាជំនុំជម្រះក្តីអន្តរជាតិបានកំណត់រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន និងអនុញ្ញាត ឬក៏តម្រូវឲ្យមានការដោះលែងនៅពេលផុតរយៈពេលកំណត់នេះ ។*

***ឃ) ដោយមិនគិតពីលក្ខណៈគតិយុត្តរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើការរំលោភបំពានសិទ្ធិរបស់ ឌុច ធ្ងន់ធ្ងរគ្រប់គ្រាន់ អង្គជំនុំជម្រះវិសាមញ្ញមានឆន្ទានុសិទ្ធិក្នុងការបញ្ឈប់ដំណើរការជំនុំជម្រះ ។***

*១៨) ដូចដែលបានទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត នៅពេលមានការចោទប្រកាន់ធ្ងន់ធ្ងរអំពីការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ឃុំឃាំង តុលាការបានពិចារណាថាការរំលោភបំពាននោះធ្ងន់ធ្ងរពេករហូតដល់ធ្វើឲ្យការបន្តដំណើរការជំនុំជម្រះនឹង «កាត់បន្ថយសុចរិតភាពនៃដំណើការយុត្តិធម៌» និងអយុត្តិធម៌ចំពោះជនជាប់ចោទ ។ នៅក្រោមទ្រឹស្តីនៃ «ការរំលោភបំពានដំណើរការជម្រះ» សូម្បីតែនៅពេលដែលតុលាការមិនរួមចំណែកនៅក្នុងការរំលោភបំពានដំណើរការជំនុំជម្រះក៏ដោយ តុលាការមានឆន្ទានុសិទ្ធិក្នុងការបញ្ឈប់ដំណើរការជំនុំជម្រះព្រហ្មទណ្ឌ ។ ទ្រឹស្តីនេះមានទំនាក់ទំនងទៅនឹងគំនិតដែលថា «តុលាការមានអំណាចគ្រប់គ្រងដែលអាចយកមកប្រើប្រាស់ដើម្បីបុព្វហេតុយុត្តិធម៌ ដោយមិនគិតដល់ការរំលោភជាក់លាក់ណាមួយ» ។*

*១៩) ការលើកលែងការចោទប្រកាន់គឺជាមធ្យោបាយសមរម្យ តែនៅពេលដែលមានការរំលោភបំពានធ្ងន់ធ្ងរជាពិសេស ប៉ុន្តែទ្រឹស្តីនៃការរំលោភបំពានដំណើរការជំនុំជម្រះនេះមិនមែនប្រើប្រាស់នៅក្នុងសំណុំរឿង «ទារុណកម្ម ឬការធ្វើទុក្ខទោសធ្ងន់ធ្ងរ» នោះទេ ។ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានថ្លែងថា ការលើកលែងការចោទប្រកាន់និងការដោះលែងដោយគ្មានលក្ខខណ្ឌ អាចសមរម្យ នៅពេលដែលសិទ្ធិរបស់ជនជាប់ចោទត្រូវបានរំលោភបំពានធ្ងន់ធ្ងរតាមរយៈការពន្យារពេល ឬ «សកម្មភាពកុហក ឬមិនស្របច្បាប់ដោយអយ្យការ» ។ សាលាឧទ្ធរណ៍នៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថា «វាជាកត្តាជាច្រើន មិនមែនតែកត្តាតែមួយនោះទេ» ដែលនាំទៅដល់ការអនុវត្តដំណោះស្រាយបែបនេះ ។ នៅក្នុងសំណុំរឿងបារ៉ាយ៉ាវីហ្សា សាលាឧទ្ធរណ៍នៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថាការប្រើប្រាស់ទ្រឹស្តីនេះសមរម្យនៅពេលដែលមាន «ការពន្យារពេលជាបន្តទៀតដែលហាក់បីដូចជាកើតឡើងនៅស្ទើរតែគ្រប់ដំណាក់កាលទាំងអស់»*

នៃសំណុំរឿងនេះ ការរំលោភបំពានលើសិទ្ធិជនជាប់ចោទម្តងហើយម្តងទៀត និងការខកខានដោយអយ្យការក្នុងការចោទប្រកាន់ដែល«ស្មើទៅនឹងការធ្វេសប្រហែស» ។ សាលាឧទ្ធរណ៍នេះបានសង្កត់ធ្ងន់ថាៈ

វាមិនទាក់ទងទេដែលថា មានតែមួយផ្នែកតូចប៉ុណ្ណោះនៃរយៈពេលទាំងមូលនៃការឃុំខ្លួនបណ្តោះអាសន្ននោះដែលបណ្តាលមកពីសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ដោយសារតែវាជាសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងមិនមែនជាអង្គភាពផ្សេងទៀតដែលកំពុងតែជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ ។

២០) សំណុំរឿងដែលសមនឹងទទួលបានការលើកលែងការចោទប្រកាន់ «គឺវិសាមញ្ញ ហើយនៅក្នុងកាលៈទេសៈទូទៅ ដំណោះស្រាយដោយការលើកលែងចោទប្រកាន់នេះនឹង...គ្មានសមាមាត្រ» ។ ដោយមូលហេតុនេះ នៅក្នុងសេចក្តីសម្រេចក្រោយមកទៀតនៅក្នុងសំណុំរឿង បារ៉ាយ៉ាហ្គីហ្សា ដដែល សាលាឧទ្ធរណ៍បានថ្លែងថា អង្គហេតុថ្មី«បានកាត់បន្ថយការខកខានរបស់ព្រះរាជអាជ្ញា ក៏ដូចជាបានកាត់បន្ថយស្ថានភាពធ្ងន់ធ្ងរនៃការរំលោភសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍» ។ ដូច្នេះសាលាឧទ្ធរណ៍បានថ្លែងថា ការលើកលែងការចោទប្រកាន់គឺ«វិសមាមាត្រសម្រាប់ព្រឹត្តការណ៍ទាំងនោះ» និងបានចេញដីកាផ្តល់សំណងជំនឹចិត្តជំនួសវិញ ។ ប៉ុន្តែជាពិសេសសាលាឧទ្ធរណ៍នេះក៏បាន «បញ្ជាក់ផងដែរថា [សេចក្តីសម្រេចលើកមុន]...គឺសំអាងទៅលើអង្គហេតុដែលមាននៅពេលនោះ» ។

## II. បើទោះបីជាការឃុំខ្លួនដោយតុលាការយោធាបណ្តាលមកពីអង្គជំនុំជម្រះវិសាមញ្ញឬអត់ អង្គជំនុំជម្រះវិសាមញ្ញមានទាំងអំណាច និងកាតព្វកិច្ចពិនិត្យមើលឡើងវិញអំពីភាពស្របច្បាប់របស់ការឃុំខ្លួននោះ

### ក) ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញផ្តល់អំណាចដល់អង្គជំនុំជម្រះក្នុងការពិនិត្យមើល និងបកស្រាយនីតិវិធីព្រហ្មទណ្ឌកម្ពុជាក្នុងស្រុក

២១) អង្គជំនុំជម្រះវិសាមញ្ញមានអំណាចតាមច្បាប់អាចធ្វើការពិនិត្យមើលនិងបកស្រាយនីតិវិធីកម្ពុជា ហើយនៅពេលចាំបាច់ អាចសម្រេចថាតើនីតិវិធីទាំងនេះត្រូវបានអនុវត្តស្របតាមច្បាប់អន្តរជាតិដែរឬទេ ។ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា ការចោទប្រកាន់ ការស៊ើបអង្កេត និងការជំនុំជម្រះត្រូវធ្វើឡើងដោយស្របតាម «ច្បាប់នីតិវិធី[កម្ពុជា]ដែលមានស្រាប់» ។ ជាងនេះទៅទៀត «លក្ខខណ្ឌសម្រាប់ការចាប់ខ្លួននិងឃុំខ្លួនជនជាប់ចោទត្រូវស្របទៅនឹងច្បាប់ជាធរមានដែលមានស្រាប់» ។

ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីណាមួយ ឬប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របទៅនឹងនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំនៅក្នុងនីតិវិធីដែលបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ ។

២២) បន្ថែមទៅលើវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានអនុម័តកាលពីខែកក្កដា ឆ្នាំ២០០៧ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថ្មីមួយទៀតបានចូលជាធរមាននៅក្នុងខែសីហា ឆ្នាំ២០០៧ ។ នៅមុនពេលអនុម័តនីតិវិធីទាំងនេះមានក្រមព្រហ្មទណ្ឌកម្ពុជាពីរៈ ច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២ និងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ។ នៅក្នុងឆ្នាំ១៩៩៩ រដ្ឋាភិបាលកម្ពុជាបានប្រកាសឲ្យប្រើច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ដែលអនុញ្ញាតឲ្យបុគ្គលដែលជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឧក្រិដ្ឋកម្មសង្គ្រាម ឬបទប្រល័យពូជសាសន៍អាចត្រូវឃុំខ្លួនបណ្តោះអាសន្ន «រយៈពេលមួយឆ្នាំ» មិនឲ្យលើស «រយៈពេលសរុបពាឆ្នាំទេ» ។ ឌុច ត្រូវបានឃុំខ្លួនដោយច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ននេះអស់រយៈពេល៨ឆ្នាំរហូតដល់ពេលត្រូវផ្ទេរទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ ។

២៣) វិធានផ្ទៃក្នុងបានចង្អុលបង្ហាញថា វិធាននេះត្រូវបានបង្កើតក្នុងគោលបំណង«ពង្រឹង» នីតិវិធីកម្ពុជា មិនមែនដើម្បីជំនួសនីតិវិធីកម្ពុជាទេ ។ «នីតិវិធីធរមានដែលមានស្រាប់» ដែលនឹងត្រូវប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញអាចនិយាយបានថាមានមិនត្រឹមតែវិធានផ្ទៃក្នុងទេ ប៉ុន្តែមានទាំងច្បាប់នីតិវិធីកម្ពុជាទាំងអស់ដែលទាក់ទងទៅនឹងបញ្ហាដែលកើតឡើងនៅក្នុងការជំនុំជម្រះដោយអង្គជំនុំជម្រះវិសាមញ្ញ ជាពិសេសបញ្ហាទាក់ទងនឹងដំណើរការព្រហ្មទណ្ឌដែលកើតឡើងនៅមុនពេលអនុម័តវិធានផ្ទៃក្នុង ។

(២៤) ជាពិសេស ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញមិនត្រឹមតែអនុញ្ញាតឲ្យអង្គជំនុំជម្រះវិសាមញ្ញអនុវត្តច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជាទេ ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញបានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះវិសាមញ្ញរួមទាំងសហចៅក្រមស៊ើបអង្កេត ត្រូវបានរំពឹងថានឹងធ្វើការបកស្រាយនីតិវិធីទាំងនេះ និងសម្រេចអំពីភាពសមស្របរបស់នីតិវិធីទាំងនេះទៅនឹងបទដ្ឋានអន្តរជាតិអាចនិយាយបានថា រួមទាំងបទដ្ឋានទាំងឡាយដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិនិងបទដ្ឋានទាំងឡាយដែលសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិគោរពតាមផងដែរ ។ ការណ៍នេះបានផ្តល់ឲ្យសហចៅក្រមស៊ើបអង្កេតនូវអំណាចក្នុងការបកស្រាយច្បាប់ស្តីពីការឃុំខ្លួនបណ្តោះអាសន្នឆ្នាំ១៩៩៩ ក៏ដូចជាច្បាប់អ៊ិនតាក់ដែលតម្រូវឲ្យមានការដោះលែង«ជាបន្ទាន់» នៅពេលដែលមិនបានគោរពតាមនីតិវិធីឃុំខ្លួនបណ្តោះអាសន្ន ។

(២៥) កិច្ចការរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបអាចយកមកប្រដូចទៅនឹងអំណាចរបស់អង្គជំនុំជម្រះនៅក្នុងបរិបទនេះ ។ តុលាការទាំងពីរនេះមានអំណាចសម្រេចថាតើច្បាប់មួយសមស្របទៅនឹងបទដ្ឋានអន្តរជាតិឬអត់ ប៉ុន្តែមិនមែនពិនិត្យមើលឡើងវិញអំពីការបកស្រាយច្បាប់នោះដោយតុលាការក្នុងស្រុកទេ ។ ដូច្នេះវាសំខាន់ដែលតុលាការសិទ្ធិមនុស្សអឺរ៉ុបបានថ្លែងថាមាត្រា៥(១) នៃអនុសញ្ញាអឺរ៉ុបបានផ្តល់អំណាចឲ្យខ្លួន «អាចពិនិត្យមើលអំពីការគោរពច្បាប់ក្នុងស្រុកដោយអាជ្ញាធរជាតិទាំងឡាយ» ។ មាត្រានេះបានចែងខ្លះៗថា «គ្មាននរណាម្នាក់ត្រូវបានដកហូតសេរីភាពរបស់ខ្លួនលើកលែងតែក្នុងករណីខាងក្រោម និងលើកលែងតែការដកហូតសេរីភាពនោះស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់» ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានថ្លែងថា ភាសាសរសេរនេះសំដៅមិនត្រឹមតែទៅដល់ការណ៍ដែលថាច្បាប់ក្នុងស្រុកត្រូវតែស្របទៅនឹងអនុសញ្ញាអឺរ៉ុបទេ ប៉ុន្តែថែមទាំងសំដៅទៅដល់កាតព្វកិច្ចរបស់រដ្ឋសមាជិកក្នុងការគោរពច្បាប់ក្នុងស្រុកទៀតផង ។ ដោយសារមូលហេតុនេះ:

បើទោះបីជាធម្មតា វាជាកិច្ចការរបស់តុលាការក្នុងការពិនិត្យមើលអំពីការគោរពច្បាប់ក្នុងស្រុកដោយអាជ្ញាធរជាតិ... [ក៏ដោយ] ផ្ទុយទៅវិញ វាទាក់ទងទៅនឹងបញ្ហាដែលដូចជានៅពេលនេះ អនុសញ្ញាអ៊ឺរ៉ុបបានយោងដោយផ្ទាល់ត្រឡប់ទៅច្បាប់នោះវិញ ។ ដោយសារនៅក្នុងបញ្ហាទាំងនោះ ការមិនគោរពច្បាប់ក្នុងស្រុកបណ្តាលឲ្យមានការរំលោភលើអនុសញ្ញាអឺរ៉ុបដែលជាលទ្ធផលតុលាការអាច និងគួរតែអនុវត្តអំណាចត្រួតពិនិត្យខ្លះរបស់ខ្លួន ។

(២៦) ស្រដៀងគ្នាដែរ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានបកស្រាយភាសាសេរសេរនៅក្នុងលក្ខន្តិកៈក្រុងរ៉ូមដែលចែងថាបុគ្គលដែលត្រូវចាប់ខ្លួន «ត្រូវជំនុំជម្រះឲ្យបានទាន់ពេលវេលាដោយអាជ្ញាធរដែលមានសមត្ថកិច្ចជំនុំជម្រះនៅក្នុងរដ្ឋឃុំខ្លួនដែលត្រូវសម្រេចដោយយោងទៅតាមច្បាប់របស់រដ្ឋនោះថា ...បុគ្គលនោះត្រូវបានចាប់ខ្លួនស្របតាមដំណើរការត្រឹមត្រូវ... និង...សិទ្ធិ[របស់ពួកគេ]ត្រូវបានគោរព» ។ សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានច្រានចោលអំណះអំណាងរបស់ជនជាប់ចោទ ដែលថាមាត្រានេះបានផ្តល់អំណាចឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រេចអំពីភាពត្រឹមត្រូវនៃសេចក្តីសម្រេចរបស់អាជ្ញាធរក្នុងស្រុក ប៉ុន្តែបានថ្លែងថា «កិច្ចការរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិគឺត្រូវមើលថាតើដំណើរការដែលមានចែងដោយច្បាប់[ក្នុងស្រុក]ត្រូវបានគោរពត្រឹមត្រូវឬទេ និងថាតើសិទ្ធិរបស់បុគ្គលដែលត្រូវបានចាប់ខ្លួនត្រូវបានគោរពត្រឹមត្រូវដែរឬទេ» ។

(២៧) ដូចគ្នាដែរ ដោយសារច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ «បានយោងត្រឡប់ទៅ» ច្បាប់នីតិវិធីកម្ពុជាវិញទាក់ទងនឹងបញ្ហាចាប់ខ្លួននិងឃុំខ្លួន អង្គជំនុំជម្រះវិសាមញ្ញមានអំណាចដែលមានចែងនៅក្នុងច្បាប់ក្នុងការសម្រេចថា តើតុលាការកម្ពុជាក្នុងស្រុកបានគោរពតាមនីតិវិធីក្នុងស្រុកដែរឬទេ ។

### ១) អង្គជំនុំជម្រះវិសាមញ្ញមានអំណាចពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុន និងមានអំណាចក្នុងការផ្តល់ដំណោះស្រាយដែលមានប្រសិទ្ធភាព

(២៨) ដោយសារភាពជិតស្និទ្ធនៃសិទ្ធិទទួលបាននូវការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំឃាំង អង្គជំនុំជម្រះវិសាមញ្ញត្រូវតែមានយុត្តាធិការក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួន ។ តាមការពិត ក្រមព្រហ្មទណ្ឌកម្ពុជាបានចែងថា

"ចៅក្រមទាំងឡាយដែលទទួលបានពាក្យបណ្តឹងទាក់ទងនឹងការឃុំខ្លួនខុសច្បាប់ត្រូវតែធ្វើការពិនិត្យមើលជាបន្ទាន់" ។ នៅក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួននៅក្នុងសំណុំរឿងពីរនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា សាលាឧទ្ធរណ៍ជឿជាក់ថា ការឃុំខ្លួនជនជាប់ចោទដោយអាជ្ញាធរក្នុងស្រុកបណ្តាលមកពីព្រះរាជអាជ្ញារបស់សាលាជំនុំជម្រះក្តីនេះក្នុងសំណុំរឿងមួយ ប៉ុន្តែក្នុងសំណុំរឿងមួយទៀតមិនមានរឿងបែបនេះកើតឡើងទេ ។ ប៉ុន្តែនៅក្នុងសំណុំរឿងទាំងពីរ សាលាឧទ្ធរណ៍បានបញ្ជាក់អំពីសិទ្ធិជាសារវន្តរបស់ជនជាប់ចោទក្នុងការ "ស្វែងរកការត្រួតពិនិត្យមើលសកម្មភាពរបស់អាជ្ញាធរឃុំខ្លួនពីសំណាក់មន្ត្រីយុត្តិធម៌ឯករាជ្យ" ។ សាលាឧទ្ធរណ៍បានថ្លែងថាៈ

*សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាត្រូវតែជំនុំជម្រះ[ការជំទាស់ទៅនឹងភាពស្របច្បាប់នៃការឃុំខ្លួន] និងត្រូវតែចេញសេចក្តីសម្រេចដោយគ្មានការពន្យារពេល ដូចដែលមានចែងនៅក្នុងឧបករណ៍សំខាន់ៗនៃច្បាប់សិទ្ធិមនុស្ស ។ ប្រសិនបើមានបណ្តឹងជំទាស់ ប៉ុន្តែមិនត្រូវបានជំនុំជម្រះសាលាឧទ្ធរណ៍នឹងសម្រេចថាសិទ្ធិជាសារវន្តរបស់ជនជាប់ចោទត្រូវបានរំលោភបំពាន ។*

២៩) សាលាដំបូងនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌសម្រាប់ប្រទេសអតីតយូហ្គោស្លាវី បានថ្លែងស្រដៀងគ្នាថា "ប្រាកដណាស់ សាលាជំនុំជម្រះក្តីមានទាំងអំណាចនិងនីតិវិធីក្នុងការដោះស្រាយបណ្តឹងជំទាស់ទៅនឹងភាពស្របច្បាប់នៃការឃុំខ្លួនអ្នកជាប់ឃុំឃាំង" ។ សិទ្ធិនេះជារបស់ "បុគ្គលដែលត្រូវបានឃុំឃាំងដែលសំណុំរឿងរបស់ខ្លួនត្រូវបានបញ្ជូនទៅកាន់សាលាដំបូង" ។ "នៅពេលដែល... សំណើ[បឋម]ត្រូវបានដាក់ជូនសាលាដំបូង ព្រះរាជអាជ្ញាមានសិទ្ធិធ្វើការឆ្លើយតប ហើយបន្ទាប់មកសាលាដំបូងនឹងផ្តល់នូវសេចក្តីសម្រេចរបស់ខ្លួន" ។

៣០) ប្រសិនបើអំណាចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួន ឌុច កាលពីមុនមិនមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ អង្គជំនុំជម្រះវិសាមញ្ញគួរតែគិតថា ខ្លួនមានអំណាចនេះមកជាមួយ ។ នៅក្នុងសំណុំរឿង រ៉ាម៉ាគូបា សាលាឧទ្ធរណ៍របស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាបានថ្លែងថា "ទាំងច្បាប់លក្ខន្តិកៈ[ច្បាប់បង្កើតសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា] និងច្បាប់នីតិវិធីរបស់ខ្លួនមិនបានចែងអំពីសិទ្ធិផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាពចំពោះការរំលោភសិទ្ធិមនុស្សទេ" ។ ប៉ុន្តែសាលាជំនុំជម្រះក្តីនេះបានចែងថា អំណាចក្នុងការផ្តល់ដំណោះស្រាយមានប្រសិទ្ធភាពនេះ "កើតចេញពីឥទ្ធិពលរួមគ្នានៃអំណាចជាប់មកជាមួយសាលាជំនុំជម្រះក្តីនេះ និងកាតព្វកិច្ចរបស់ខ្លួនក្នុងការគោរពបទដ្ឋានសិទ្ធិមនុស្សដែលទទួលស្គាល់ជាទូទៅ" ។ អំណាចដែលមានមកជាមួយសាលាជំនុំជម្រះក្តីនេះ "គឺមានសម្រាប់សាលាជំនុំជម្រះក្តីនេះតែម្តងពីព្រោះវាមានសារសំខាន់ណាស់នៅក្នុងការបំពេញតួនាទីរបស់តុលាការដែលរួមទាំងការគ្រប់គ្រងត្រឹមត្រូវនិងសមរម្យនូវដំណើរការយុត្តិធម៌" ។ ប្រភពបន្ថែមមួយទៀតគឺលក្ខណៈនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាដែលជា "សរីរាង្គបន្ទាប់បន្សំប្រភេទពិសេសមួយរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ" ដែល "ត្រូវតែគោរពនិងធានាថាមានការគោរពបទដ្ឋានសិទ្ធិមនុស្សដែលមានការទទួលស្គាល់ជាទូទៅ" ។ ដូចដែលបានពិភាក្សាខាងលើអង្គជំនុំជម្រះវិសាមញ្ញមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអង្គការសហប្រជាជាតិនិងជាយន្តការមួយបង្កើតឡើងដើម្បីលើកកម្ពស់យុត្តិធម៌អន្តរជាតិ ។ ជាងនេះទៅទៀត ដោយសារទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រព័ន្ធយុត្តិធម៌កម្ពុជា អង្គជំនុំជម្រះវិសាមញ្ញប្រហែលជាមានកាតព្វកិច្ចកាន់តែសំខាន់ថែមទៀតក្នុងការធានាឲ្យមានការគោរពសិទ្ធិរបស់ជនជាប់ឃុំខ្លួនបណ្តោះអាសន្ននេះ ។ ដូចនេះអង្គបុរេជំនុំជម្រះគួរតែសម្រេចថាសហចៅក្រមស៊ើបអង្កេតមានអំណាចក្នុងការសម្រេចអំពីភាពស្របច្បាប់នៃការឃុំខ្លួនកាលពីមុនរបស់ ឌុច និងក្នុងការពិចារណាឥទ្ធិពលនៃការឃុំខ្លួននេះថាតើស័ក្តិសមនឹងធ្វើការដោះលែងបណ្តោះអាសន្នឬទេ ។

**ក) អង្គជំនុំជម្រះវិសាមញ្ញមានកាតព្វកិច្ចក្នុងការសម្រេចថាតើការឃុំខ្លួនកាលពីមុនរបស់ ឌុច ជាការស្របច្បាប់ និងមិនមែនដោយបំពានឬទេ ។**

៣១) ការវាយតម្លៃអំពីភាពស្របច្បាប់នៃការឃុំខ្លួន

*សំណួរដំបូងដែលត្រូវដោះស្រាយដោយតុលាការសិទ្ធិមនុស្សនិងតុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាករណីស្របច្បាប់ ។ ដើម្បីឲ្យការឃុំខ្លួនមួយស្របច្បាប់ ការឃុំខ្លួននោះត្រូវតែធ្វើឡើង «ដោយមូលហេតុស្របច្បាប់និងស្របទៅនឹងនីតិវិធីតាមច្បាប់» ។ ជាឧទាហរណ៍ គណៈកម្មាធិការសិទ្ធិមនុស្សអន្តរអាមេរិកាំងបានថ្លែងថាការឃុំខ្លួនទាំងឡាយណាដែលហួសពីរយៈពេលកំណត់ដោយច្បាប់ «គួរតែត្រូវចាត់ទុកថាមិនស្របច្បាប់» ព្រោះ «បទដ្ឋានមួយដែលអនុញ្ញាតឲ្យមានការដោះលែងអ្នកទោសម្នាក់ពីមន្ទីរឃុំឃាំងមិនអាចត្រូវគេយកមកបកស្រាយថាអាចអនុញ្ញាតឲ្យធ្វើការពន្យារពេលនៃការឃុំខ្លួនដោយសារមូលហេតុការពារផ្សេងៗឲ្យយូរជាងអ្វីដែលក្រមនីតិវិធីគិតថាសមរម្យនោះទេ» ។ ជាលទ្ធផលការពន្យាររយៈពេលឃុំខ្លួនត្រូវតែ «ត្រួតពិនិត្យមើលឲ្យបានតឹងតែង» ។ ការឃុំខ្លួនត្រូវតែស្របច្បាប់និង «មិនដោយបំពាន» ផងដែរ ។ ការឃុំខ្លួនត្រូវចាត់ទុកថាបំពាបំពាននៅពេលដែលការឃុំខ្លួននោះមិន «សមហេតុសមផល» និងមិន «ចាំបាច់» នៅក្រោមកាលៈទេសៈនោះ ។ ដូច្នេះការវាយតម្លៃអំពីភាពស្របច្បាប់នៃការឃុំខ្លួនតម្រូវឲ្យមានទាំងការសម្រេចថាតើនីតិវិធីត្រូវបានគោរពឬទេ និងទាំង «ភាពសមហេតុសមផលនៃ....ភាពស្របច្បាប់នៃគោលបំណងដែលសម្រេចឲ្យមានការចាប់ខ្លួននិងឃុំខ្លួននោះ» ។*

*៣២) នៅក្នុងសំណុំរឿងអាលម៉ាន់ និង ប្រទេសបារាំង គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា ប្រទេសបារាំងទទួលខុសត្រូវចំពោះនីតិវិធីបត្យាប័នដែលត្រូវចោទថាមិនស្របច្បាប់ ប្រើប្រាស់ដោយប្រទេសបូលីវា ដែលនាំឲ្យមានការឃុំខ្លួនម្ចាស់បណ្ដឹងនេះនៅក្នុងប្រទេសបារាំង ។ នៅក្នុងការសម្រេចថាមាន «ការសហការយ៉ាងជិតស្និទ្ធ» រវាងរដ្ឋទាំងពីរនេះដូចដែលបានលើកឡើងដោយម្ចាស់បណ្ដឹងគណៈកម្មការបានពិនិត្យមើលថាច្បាប់បារាំងដែលគ្រប់គ្រងការឃុំខ្លួននៅក្នុងប្រទេសបារាំងនោះត្រូវគេគោរពត្រឹមត្រូវនិងមិនបំពារបំពាន ។ ដោយសារលក្ខខណ្ឌនេះត្រូវបានបំពេញគណៈកម្មាធិការនេះបានសម្រេចថា មិនមានការរំលោភបំពានលើអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុបទេ ។*

*៣៣) នៅក្នុងសំណុំរឿងលូបាងហ្គា តុលាការព្រហ្មទណ្ឌអន្តរជាតិ បានពិចារណាអំពីភាពស្របច្បាប់នៃការចាប់ខ្លួននិងឃុំខ្លួនជនជាប់ចោទដោយសាធារណរដ្ឋកុងហ្គោ នៅក្នុងការឆ្លើយតបទៅនឹងការជំទាស់របស់ជនជាប់ចោទទៅនឹងយុត្តាធិការរបស់តុលាការ ។ អង្គបុរេជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានសម្រេចថា នៅពេលមិនមានការបំពានលើដំណើរការទេ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចពិនិត្យមើលអំពីការរំលោភសិទ្ធិជនជាប់ចោទកាលពីនៅក្រោមការឃុំខ្លួនក្រោមយុត្តាធិការជាតិ «ប៉ុន្តែនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងរកឃើញថាមានការសហការយ៉ាងជិតស្និទ្ធរវាងតុលាការព្រហ្មទណ្ឌអន្តរជាតិ និង...អាជ្ញាធរ[ក្នុងស្រុក]» ។ នៅពេលពិនិត្យមើលឡើងវិញអង្គជំនុំជម្រះនៃសាលាឧទ្ធរណ៍រកមិនឃើញមានការចូលរួមដោយអយ្យការនៅក្នុងការឃុំខ្លួនជនជាប់ចោទនៅក្នុងប្រទេសឃុំខ្លួនគាត់ទេ ។ ប៉ុន្តែអង្គជំនុំជម្រះនៃសាលាឧទ្ធរណ៍បានសម្រេចថា តាមច្បាប់លក្ខន្តិកៈបង្កើតតុលាការ តុលាការមានកាតព្វកិច្ច «មើលថាតើដំណើរការដែលចែងដោយច្បាប់[ជាតិ]ត្រូវបានគោរពត្រឹមត្រូវឬទេនិងថាតើសិទ្ធិបុគ្គលត្រូវចាប់ខ្លួនត្រូវបានគោរពត្រឹមត្រូវឬទេ» ។ អង្គជំនុំជម្រះនៃសាលាឧទ្ធរណ៍បានកត់សម្គាល់ថាអង្គបុរេជំនុំជម្រះតាមការពិត «បានសម្រេចថា ដំណើរការអនុវត្តសមស្របតាមច្បាប់របស់ប្រទេសកុងហ្គោ» ហើយអង្គជំនុំជម្រះនៃសាលាឧទ្ធរណ៍បានសម្រេចថា «មិនមានអ្វីផ្ទុយទៅនឹងការលើកឡើងនេះ....[ឬ]អាចបញ្ជាក់ថា ការចាប់ខ្លួនគាត់ ឬការបង្ហាញខ្លួនគាត់នៅចំពោះមុខអាជ្ញាធរកុងហ្គោ មានការរំលោភបំពានណាមួយលើសិទ្ធិរបស់គាត់ទេ» ។*

### ឃ) អង្គជំនុំជម្រះវិសាមញ្ញមានកាតព្វកិច្ចពិនិត្យមើលអំពីរយៈពេលនៃការឃុំខ្លួនកាលពីមុននៅក្នុងការសម្រេចពីភាពស្របច្បាប់នៃការឃុំខ្លួនជាបន្ត ។

*៣៤) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែលទើបតែអនុម័តថ្មីៗនេះបានចែងថា «គោលការណ៍ទូទៅ សេរីភាពរបស់ជនជាប់ចោទត្រូវតែផ្ដល់ឲ្យ» ប៉ុន្តែ «នៅក្នុងករណីពិសេសជនជាប់ចោទអាចត្រូវឃុំខ្លួនជាបណ្ដោះអាសន្ន» ។ ដូចគ្នាដែរ តុលាការសិទ្ធិមនុស្សបានសម្រេចថា ការឃុំខ្លួនបណ្ដោះអាសន្នគឺជាករណីលើកលែង និងមិនត្រូវឲ្យហួសពីរយៈពេលចាំបាច់ឡើយ ។ នៅក្នុងការវាយតម្លៃអំពីភាពសមរម្យនៃការបន្តឃុំខ្លួន តុលាការសិទ្ធិ*

មនុស្សទាំងនោះបានអនុវត្តនូវការសាកល្បងមួយដែលព្យាយាមធ្វើឲ្យមានតុល្យភាព ។ ជាក់ស្តែង តុលាការសិទ្ធិមនុស្សអឺរ៉ុបបានថ្លែងថា «ពីដំបូង វាស្ថិតនៅក្រោមអាជ្ញាធរតុលាការក្នុងស្រុកក្នុងការ...ពិនិត្យមើលគ្រប់លក្ខខណ្ឌទាំងអស់ដែលគាំទ្រ ឬប្រឆាំងទៅនឹងតម្រូវការចាំបាច់នៃផលប្រយោជន៍សាធារណៈដែលអាចដោះសាបាន....ចំពោះភាពមិនសមស្របទៅនឹងវិធាននៃការគោរពសេរីភាពបុគ្គល» ។

៣៥) តុលាការអន្តរជាតិ ជាទូទៅបានចាត់ទុកការដោះលែងថាជាករណីលើកលែង ប៉ុន្តែនៅប៉ុន្មានឆ្នាំថ្មីៗនេះ តុលាការក៏បានប្រើប្រាស់ការសាកល្បងមួយដែលព្យាយាមធ្វើឲ្យមានតុល្យភាពដែរ ។ សាលាដំបូងនៃសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី បានថ្លែងថា «ការផ្តោតអារម្មណ៍[នៃការវាយតម្លៃលើការឃុំខ្លួនបណ្តោះអាសន្ន] ត្រូវតែផ្តោតទៅលើលក្ខខណ្ឌពិសេសនៃសំណុំរឿងនីមួយៗ... កិច្ចការ[របស់សាលាជំនុំជម្រះក្តី] គឺសំខាន់ត្រូវថ្លឹងថ្លែងកត្តាទាំងឡាយដែលមាននៅក្នុងសំណុំរឿងនោះមុនពេលចេញសេចក្តីសម្រេច» ។ ប៉ុន្តែសាលាជំនុំជម្រះក្តីនេះត្រូវរក្សានូវ «ឆន្ទានុសិទ្ធិយ៉ាងច្រើននៅពេលសម្រេចអំពីទម្ងន់នៃកត្តាទាំងនោះបន្ទាប់ពីពិចារណាលក្ខខណ្ឌពិសេសរបស់សំណុំរឿងនោះ» ។

៣៦) ទាំងសាលាដំបូងនៃសាលាជំនុំជម្រះក្តីសម្រាប់ប្រទេសអតីតយូហ្គោស្លាវី និងសាលាដំបូងនៃសាលាជំនុំជម្រះក្តីសម្រាប់ប្រទេសរ៉្វាន់ដាបានរកឃើញថា រយៈពេលនៃការឃុំខ្លួនគឺជា «កត្តាសំខាន់ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិសម្រេចលើសំណើសុំដោះលែងបណ្តោះអាសន្ន» ។ ប៉ុន្តែនៅពេលដែលការឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរ«តម្រូវឲ្យមានសំណងជំងឺចិត្ត» វាមិនមែនជា«បុព្វហេតុល្អសម្រាប់ការដោះលែង[បណ្តោះអាសន្ននោះ]ទេ» ។ នៅក្នុងសំណុំរឿងក្រាជីសនិក សាលាដំបូងបានសម្រេចមិនឲ្យមានការដោះលែងនៅពេលដែលរយៈពេលនៃការឃុំខ្លួនមិនហួសរយៈពេលដែលតុលាការសិទ្ធិមនុស្សរកឃើញថាមិនសមហេតុសមផល ការជំនុំជម្រះត្រូវបានរំពឹងថានឹងចាប់ផ្តើមក្នុងរយៈពេលប៉ុន្មានខែទៀត ហើយជនជាប់ចោទមិនបានធ្វើឲ្យសាលាដំបូងនេះជឿជាក់ថា ប្រសិនបើត្រូវដោះលែងគាត់ប្រាកដជានឹងបង្ហាញខ្លួននៅពេលជំនុំជម្រះ និងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ ឬសាក្សី ។ ចៅក្រមរ៉ូប៊ីនសុន បានជំទាស់ទៅនឹងសេចក្តីសម្រេចនេះដោយអះអាងថា បើទោះបីជាការឃុំខ្លួនបណ្តោះអាសន្នរយៈពេលពីរឆ្នាំ ប្រហែលជាមិនយូរពេករហូតដល់រំលោភបទដ្ឋានសិទ្ធិមនុស្សបន្ថែមលើការធានាដែលជនរងគ្រោះបានផ្តល់ទាក់ទងនឹងការបង្ហាញខ្លួនសម្រាប់ការជំនុំជម្រះ វាគួរតែអាចគ្រប់គ្រាន់សម្រាប់ការដោះលែងបាន ។

៣៧) នៅក្នុងសំណុំរឿងបាហ្គោសូរ៉ា[ចុងចោទមានច្រើននាក់នៅក្នុងសំណុំរឿងនេះ] សាលាដំបូងរបស់សាលាជំនុំជម្រះក្តីសម្រាប់ប្រទេសរ៉្វាន់ដាបានពិចារណាថាតើរយៈពេលឃុំខ្លួនរបស់ជនជាប់ចោទរួមជាមួយកត្តាផ្សេងៗទៀតអាចទទួលបានការដោះលែងបណ្តោះអាសន្នឬទេ ។ ព្រះរាជអាជ្ញាបានអះអាងថា រយៈពេលនៃការឃុំខ្លួនមិនគួរគណនាថាមានរយៈពេល៦ឆ្នាំទេ ប៉ុន្តែអាចថាមានរយៈពេល៥ឆ្នាំ៤ខែ ដោយមិនគិតពីរយៈពេលនៃការឃុំខ្លួនដែលមិនមែនជាការទទួលខុសត្រូវដោយសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ ប៉ុន្តែបើទោះបីជាសាលាដំបូងមិនបានដោះស្រាយការអះអាងនេះឲ្យបានច្បាស់លាស់ក៏ដោយ វាហាក់បីដូចជាបានពិចារណាអំពីរយៈពេលឃុំខ្លួនទាំងមូលរបស់ជនជាប់ចោទ មិនមែនត្រឹមតែរយៈពេលដែលទទួលខុសត្រូវដោយសាលាជំនុំជម្រះក្តីនេះទេ ។ ដូច្នេះសាលាដំបូងបានកត់សម្គាល់ថា «នៅក្នុងករណីពិសេស ការឃុំខ្លួនបណ្តោះអាសន្នរយៈពេល៦ឆ្នាំអាចជាកត្តាមួយក្នុងការសម្រេចអំពីលក្ខខណ្ឌវិសាមញ្ញទាំងឡាយដែលអាចបណ្តាលឲ្យមានការដោះលែងជនជាប់ចោទ» ។

## III. សេចក្តីសន្និដ្ឋាន

៣៨) អង្គជំនុំជម្រះវិសាមញ្ញមានតួនាទីសំខាន់ក្នុងការនាំយកយុត្តិធម៌មកឲ្យប្រទេសកម្ពុជា ។ នេះមិនត្រឹមតែទាំងតួនាទីស្នូលក្នុងការជំនុំជម្រះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រព្រឹត្តនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតួនាទីជាគំរូដល់ប្រព័ន្ធយុត្តិធម៌កម្ពុជាទៀតផង ។ អស់រយៈពេល៨ឆ្នាំដែល ឌុច ត្រូវជាប់ឃុំឃាំងដោយមិនមានការព្យាយាមច្បាស់លាស់ណាមួយនាំយកឌុចទៅជំនុំជម្រះ ។ ឌុចមិនមែនជាអ្នកជាប់ឃុំឃាំង

តែម្នាក់នៅក្នុងប្រទេសកម្ពុជាដែលត្រូវឃុំខ្លួនរយៈពេលយូរដោយមិនបានទទួលដំណើរការជំនុំជម្រះទេ ។ វាជាភាពស្របច្បាប់និងជាកេរដំណែលរបស់អង្គជំនុំជម្រះវិសាមញ្ញ ដែលអង្គជំនុំជម្រះនេះត្រូវធ្វើអ្វីគ្រប់យ៉ាងនៅក្រោមអំណាចរបស់ខ្លួនដើម្បីធានាដល់សិទ្ធិរបស់បុគ្គលដែលស្ថិតនៅក្រោមយុត្តាធិការរបស់ខ្លួន ។ ដូច្នេះវាអាចជាការរួមចំណែកយ៉ាងសម្បើមដល់កិច្ចប្រឹងប្រែងផ្សះផ្សាជាតិយូរអង្វែងនៅក្នុងប្រទេសកម្ពុជា ហើយទំហំនៃការផ្សះផ្សាជាតិនេះគឺលាតសន្ធឹងហួសឆ្ងាយពីកិច្ចការដែលមានព្រំដែនកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញនិងរយៈពេលខ្លីនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

៣៩) ក្នុងគោលបំណងនេះ អង្គបុរេជំនុំជម្រះគួរតែរកឃើញថា សហចៅក្រមស៊ើបអង្កេតមានយុត្តាធិការក្នុងការពិនិត្យមើលអំពីភាពស្របច្បាប់នៃការឃុំខ្លួនបណ្តោះអាសន្នរបស់ ឌុច ហើយអង្គបុរេជំនុំជម្រះខ្លួនឯងគួរតែពិចារណាថាតើសិទ្ធិរបស់ ឌុច មានការរំលោភបំពានឬទេ ។ ថាតើអង្គបុរេជំនុំជម្រះរកឃើញថាការពន្យារពេលក្នុងការជំនុំជម្រះ ឌុច អាចផ្តល់នូវការដោះលែងបណ្តោះអាសន្នឬអត់ ឬរកឃើញផ្ទុយទៅវិញថាដំណោះស្រាយផ្សេងទៀតអាចសមរម្យជាង ដោយពិចារណាអំពីសំណួរនេះពីដំណាក់កាលដំបូងបំផុតនៃការជំនុំជម្រះបង្ហាញអំពីភាពធ្ងន់ធ្ងរនៃបញ្ហា និងបង្កើតជាគំរូល្អបំផុតនៃដំណើរការជំនុំជម្រះត្រឹមត្រូវសម្រាប់តុលាការកម្ពុជាផ្សេងទៀត ។

**អែន ហែនដែល**

**ទីប្រឹក្សាច្បាប់មជ្ឈមណ្ឌលឯកសារកម្ពុជា**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧**

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០៧ នួន ជា ត្រូវបាននាំខ្លួនមកកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមដីកាបង្គាប់ឲ្យនាំខ្លួន។ ការចូលបង្ហាញខ្លួនលើកដំបូងនឹងប្រព្រឹត្តិធ្វើឡើងនាថ្ងៃនេះ ហើយនាពេលជាមួយគ្នាផងដែរ គាត់នឹងត្រូវបានប្រាប់ឲ្យដឹងអំពីបទចោទប្រកាន់ទៅលើរូបគាត់។

សេចក្តីប្រកាសព័ត៌មានពិស្តារនឹងធ្វើឡើងនាពេលដ៏ខ្លីខាងមុខ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**

**លេខ/No: 002/19-09-2007**

# ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន
# Provisional detention Order
# Ordonnance de placement en détention provisoire

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា** ភេទ ប្រុស កើតនៅ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩២៦ នៅ ភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ

ឪពុកឈ្មោះ ឡៅ លីវ (ស្លាប់) ម្តាយឈ្មោះ ដុស ពាញ (ស្លាប់) ប្រពន្ធឈ្មោះ លី គីមសេង (រស់) មានកូន ០៣ នាក់ មានទីលំនៅបច្ចុប្បន្ននៅភូមិផ្សារព្រហ្ម ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន

ត្រូវដាក់អោយស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សមនុស្សជាតិ និង ការលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ១៩៤៩ ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៥ មាត្រា ៦ មាត្រា ២៩ ថ្មី និង មាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថ្ងៃទី២៧ តុលា ២០០៤។

បានឃើញការជជែកដេញដោលដែលបានធ្វើនៅថ្ងៃនេះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

## ១- ស្ថានភាពអង្គហេតុ និង អង្គច្បាប់

១- នៅក្នុងករណីបច្ចុប្បន្ន (ដោយមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការ ដែលអាចអោយយើងកំណត់ជាបទល្មើសផ្សេងទៀតដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ និង ដែលអាចដាក់បន្ទុកលើជនត្រូវចោទ) **ឈ្មោះ នួន ជា** ត្រូវបានចោទអំពី ៖

- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** (មនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ឃុំឃាំង ការធ្វើទុកបុកម្នេញ ការសំលាប់ផុតពូជ ការនិរទេស ការជន្លៀសប្រជាពលរដ្ឋដោយបង្ខំ ការដាក់ជាទាសករ និង អំពើអមនុស្សធម៌ដទៃទៀត) និង

- **បទឧក្រិដ្ឋសង្គ្រាម**ដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩ (ការសំលាប់ដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តអមនុស្សធម៌ ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើអោយឈឺចាប់ខ្លាំងដោយចេតនាដល់រាយកាយ និង សុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬ ជន្លៀសដោយបង្ខំ ឬ ការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)

២- ជននេះត្រូវបានដាក់បន្ទុកថាបានធ្វើ នៅលើទឹកដីនៃប្រទេសកម្ពុជារវាងថ្ងៃ ១៧ មេសា ១៩៧៥ និង ថ្ងៃទី ៦ ខែ មករា ១៩៧៩ ៖

- ក្នុងឋានៈ ជាអាទិ៍ ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ប្រធានសភាប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ នាយករដ្ឋមន្ត្រីស្តីទី និង អនុប្រធាននៃគណៈកម្មាធិការយោធាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា

- ផែនការ មេគំនិត ដឹកនាំ បញ្ជា សម្របសម្រួល និងផ្តល់ជំនួយ ក្នុងការប្រព្រឹត្តនូវបទល្មើសទាំងឡាយខាងលើ ដោយប្រើប្រាស់នូវអំណាច និង ការគ្រប់គ្រងដោយពេញលេញរបស់ខ្លួនដែលមានលើមន្ទីរសន្តិសុខផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ (មន្ទីរឃុំឃាំងទាំងឡាយ) និង ដោយដឹកនាំ តាមរយៈការដាក់ឲ្យអនុវត្ត និងការធ្វើឲ្យគេគោរពនូវនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលមានលក្ខណៈជាការជន្លៀសប្រជាជនដោយបង្ខំ ការដាក់ជាទាសករ ការធ្វើការងារដោយបង្ខំ ឬ អំពើអមនុស្សធម៌ដទៃទៀត

- នយោបាយជាទូទៅ និង ជាប្រព័ន្ធ សំដៅលើជនស៊ីវិល

- ដោយបញ្ជាក់ថា ក្នុងកំឡុងពេលទាំងអស់ ឬមួយផ្នែកនៃចន្លោះថ្ងៃទី១៧ មេសា ១៩៧៥ និង ថ្ងៃទី៦ មករា ១៩៧៩ កម្ពុជាប្រជាធិបតេយ្យ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្ថិតនៅក្នុងស្ថានភាពនៃជំលោះប្រដាប់អាវុធអន្តរជាតិជាមួយគ្នា។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel: +855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

៣- សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញស្នើសុំអោយមានការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ ដោយហេតុថាមានហេតុផលជាក់លាក់ដែលជឿថា **នួន ជា** បានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ និងថា ការឃុំខ្លួនបណ្ដោះអាសន្នមានលក្ខណៈចាំបាច់ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី ដូចជាអ្នកដែលធ្លាប់ស្ថិតនៅក្រោមអំណាចរបស់គាត់ និង ការពារការបំផ្លាញភស្តុតាងនានា។ ម្យ៉ាងវិញទៀត ការឃុំខ្លួនបណ្ដោះអាសន្នមានលក្ខណៈចាំបាច់ដើម្បីធានារក្សាទុកវត្តមានជននេះសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ ដោយពិនិត្យមើលលើលទ្ធភាពដែលអាចរត់គេចខ្លួន និង ដើម្បីរក្សាសុវត្ថិភាពដល់ជនត្រូវចោទផ្ទាល់។ ជាចុងក្រោយ ការឃុំខ្លួននេះមានសារៈសំខាន់ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ។

៤- **នួន ជា** ជំទាស់នឹងអង្គហេតុដែលដាក់បន្ទុកលើខ្លួន ដោយគូសបញ្ជាក់ថាគាត់នឹងមានភាពអៀនខ្មាស់បើបានប្រព្រឹត្តអំពើបែបនោះមែន និង អះអាងថា ៖ *"យើងមិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងមូលដ្ឋានទេ ដូច្នេះយើងមិនបានដឹងអំពីអ្វីដែលកើតមានឡើងនោះទេ"*។ ជនត្រូវចោទបញ្ជាក់ថាអំណាចពិតប្រាកដក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ស្ថិតនៅក្នុងដៃគណៈកម្មាធិការយោធាដែលគាត់មិនស្ថិតនៅក្នុងនោះទេ។ គាត់បានបន្ថែមថាគាត់គឺជាសមាជិកអំណាចនីតិបញ្ញត្តិ គាត់មិនដែលធ្វើច្បាប់កាប់សម្លាប់ជាតិឯងនោះទេ។ គាត់លើកឡើងថា គាត់ខ្លួនឯងក៏បានបាត់បង់សមាជិកគ្រួសារប្រហែល៤០ នាក់ផងដែរនៅក្នុងព្រឹត្តការណ៍សម័យនោះ។ គាត់ជំទាស់ជានិច្ចចំពោះការដែលគេនិយាយមិនឈប់អំពីជនរងគ្រោះ ១.៧ លាននាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនដែលនិយាយអំពីការស្លាប់ដែលបង្កឡើងដោយជនដទៃទៀតនៅមុនឆ្នាំ១៩៧៥ ឬ នៅក្រោយឆ្នាំ១៩៧៩។ ជនត្រូវចោទលើកឡើងថា លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវបានបំពេញទេ ដោយហេតុថា ចាប់តាំងពីគាត់បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាមក គាត់រស់នៅដោយមានសេរីភាពដោយមិនដែលមានបញ្ហាអ្វីកើតឡើងទេ។ គាត់បញ្ជាក់ផងដែរថា គាត់គ្មានចេតនានៅក្នុងការបំផ្លាញភស្តុតាង ឬ ដាក់សម្ពាធលើអ្នកណាម្នាក់ឡើយ ពីព្រោះគាត់មិនមានធាតុឃោរឃៅទេ និង គាត់ក៏ធ្លាប់បួសរៀនផងដែរ។ ម្យ៉ាងទៀត គាត់ក៏មិនដែលធ្លាប់ត្រូវបានគំរាមកំហែងដោយជនណាម្នាក់ដែរ។ ផ្ទុយទៅវិញ គាត់ទទួលបានការស្រលាញ់រាប់អានជាច្រើន ។ ក្រៅពីនេះ គាត់រស់នៅក្បែរព្រំដែនប្រទេសថៃជាច្រើនឆ្នាំមកហើយ ដូចនេះ គាត់អាចនឹងរត់គេចខ្លួនបានយ៉ាងស្រួល ប្រសិនបើគាត់ចង់រត់គេចនោះ។ គាត់ប្រកាសថា គាត់ចង់បំភ្លឺដល់ប្រជាជនកម្ពុជា និង ពិភពលោកទាំងមូលអំពីសត្រូវពិតប្រាកដរបស់កម្ពុជា ដោយបញ្ជាក់ថា គាត់ជាជនស្នេហាជាតិ និង មិនមែនជាជនកំសាកទេ ហើយគាត់ក៏មិនសុខចិត្តអោយកិត្តិយសរបស់ប្រទេសជាតិអាប់អោនដែរ។

## ២- សំអាងហេតុសេចក្ដីសម្រេច

៥- តាមរយៈឯកសារ និង ចម្លើយសាក្សីជាច្រើនដែលដាក់បន្ទុកលើ **នួន ជា** បង្កើតបានជាហេតុផលដែលអាចអោយជឿជាក់ថា **នួន ជា** បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុក។ អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ

ទោះជាវាមានរយៈពេល ៣០ ឆ្នាំ ក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះវាមិនមែនការហួសហេតុពេកដែលអះអាងថានៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឲ្យមានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហឹង្សា ឬ អាចប៉ះពាល់ដល់សន្តិសុខរបស់ជនត្រូវចោទផ្ទាល់។ ម្យ៉ាងវិញទៀត តួនាទីឋានានុក្រមជាពិសេសរបស់ **នួន ជា** ("បងធំទី២"នៃរបបនោះ) នាំអោយសង្ស័យថា ជននេះព្យាយាមនិងរៀបចំធ្វើការដាក់សម្ពាធលើសាក្សី និង ជនរងគ្រោះ។ ក្រៅពីនេះ ទោសឧក្រិដ្ឋជាប់មន្ទីរឃុំឃាំងមួយជីវិតដែល **នួន ជា** ត្រូវប្រឈម អាចនាំឲ្យមានការភ័យខ្លាចថា ជននេះអាចស្វែងរកការគេចខ្លួនពីតុលាការ។

៦- ជាផលវិបាក យល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានកសារៈសំខាន់ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ និង មានភាពចាំបាច់ផងដែរដើម្បីធានារក្សាទុកវត្តមានជនត្រូវចោទសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ និង ដើម្បីរក្សាសណ្តាប់ធ្នាប់សារធារណៈ និង ដើម្បីការពារការពារសុវត្ថិភាពផ្ទាល់របស់ជននេះ ដែលមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរ៉ឹង និង មានប្រសិទ្ធិភាពអាចធានាអោយមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះទេ ហើយថាការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចគោលដៅខាងលើនេះ។

## ហេតុដូច្នេះ សម្រេច

ឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **នួន ជា** ចំនួនរយៈពេលអតិបរមា ១ ឆ្នាំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០០៧

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**
**Co-juges d'instruction**

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេសជាក្រោយ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

យើង **លី ច័ន្ទតុលា និង ហាម ហ៊ើល** បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី........ខែ........... ឆ្នាំ...........

**ជនត្រូវចោទ មេធាវីជនត្រូវចោទ សហព្រះរាជអាជ្ញា ការិយាល័យរដ្ឋបាល ក្រឡាបញ្ជី**

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា:

- ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទ មានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់ រៀងរាល់ ១២០ ថ្ងៃម្តង ហើយ ត្រូវផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និង លក្ខខ័ណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ អាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេត ត្រូវសម្រេចអំពីសំណើរនេះ។
- ជនត្រូវចោទ អាចធ្វើការកត់សម្គាល់ មុនពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្ត ការឃុំខ្លួនជនត្រូវចោទនេះ។ ជនត្រូវចោទ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។
- ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេ អាចធ្វើសំណើសុំដោះលែងទៅ សហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្តូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំ សាជាថ្មីម្តងទៀត ក្នុងរយៈពេលមិនឱ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅក្រៅឃុំពីពេលមុន។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## សេចក្តីប្រកាសព័ត៌មាន

**១២ វិច្ឆិកា ២០០៧**

លោក **អៀង** សារី និង អ្នកស្រី **អៀង ធីរិទ្ធ** ត្រូវឃាត់ខ្លួន និង នាំមកអង្គជំនុំជម្រះវិសាមញ្ញ នៅថ្ងៃទី១២ ខែវិច្ឆិកា ២០០៧ ។ ពួកគេបានជួបជាមួយមន្ត្រីនៃអង្គភាពគាំពារការការពារក្តី ដើម្បីជ្រើសរើសសហមេធាវីរបស់ពួកគេ ។

លោក **អៀង សារី** បានជ្រើសរើសលោក **អាង ឧត្តម** ជាសហមេធាវីកម្ពុជា ដើម្បីតំណាងឲ្យគាត់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ ពីឆ្នាំ ១៩៩៤ ដល់ ១៩៩៧ លោក **អាង ឧត្តម** ប្រកបវិជ្ជាជីវៈជាមេធាវីព្រហ្មទណ្ឌ នៅគំរោងអ្នកការពារក្តីកម្ពុជា(CDP) និងអង្គការជំនួយការផ្នែកច្បាប់នៃកម្ពុជា (LAC) ។ ចាប់ពីឆ្នាំ១៩៩៩ លោកមេធាវី **អាង ឧត្តម** បង្កើតការិយាល័យមេធាវីដោយខ្លួនឯង ហើយលោកជាប្រធានអង្គភាពច្បាប់នៃមជ្ឈមណ្ឌលអភិវឌ្ឍន៏សង្គម (CSD) ពីឆ្នាំ២០០៦ ។

លោក **អៀង សារី** បានសំរិតសំរាំងបេក្ខភាពសហមេធាវីបរទេសចំនួនពីររូប ហើយសហមេធាវីបរទេសនឹងចាត់តាំងនៅសប្តាហ៍ក្រោយ ។

អ្នកស្រី **អៀង ធីរិទ្ធ** បានជ្រើសរើសលោក **ផាត់ ពៅស៊ាង** ជាសហមេធាវីកម្ពុជា ដើម្បីតំណាងឲ្យគាត់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ ចាប់តាំងពីឆ្នាំ១៩៩៦ លោក **ផាត់ ពៅស៊ាង** ជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។លោក **ផាត់ ពៅស៊ាង** ចាប់អាជីពជាមេធាវីនៅឆ្នាំ ១៩៩៧ ដោយបានការពាររឿងក្តីព្រហ្មទណ្ឌជាច្រើនករណី ហើយធ្វើជាទីប្រឹក្សាច្បាប់ឲ្យគណៈកម្មាធិការនីតិបញ្ញត្តិ និង តុលាការ ។

អ្នកស្រី **អៀង ធីរិទ្ធ** បានជ្រើសរើសកញ្ញា Diana Ellis QC ជាសហមេធាវីបរទេស ។ កញ្ញា Ellis ចូលជាសមាជិកនៃគណៈមេធាវីអង់គ្លេសនិងវែល នៅឆ្នាំ ១៩៧៨ និងត្រូវបានចាត់តាំងគោរម្យងារជា **Queen's Counsel** នៅឆ្នាំ ២០០១ ។ កញ្ញា Diana Ellis មានបទពិសោធន៏ច្រើននៅក្នុងការពាររឿងក្តីព្រហ្មទណ្ឌធ្ងន់ធ្ងរ ។ ជាការកត់សំគាល់ កញ្ញា Diana Ellis ធ្លាប់ជាមេធាវីការពារជនជាប់ចោទឈ្មោះ Ferdinand Nahimana នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉ាវ៉ាន់ដា ដែលជាសវនាការដំបូងគេបង្អស់ប្រព្រឹត្តទៅនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ទៅលើបទចោទដែលពាក់ព័ន្ធជាមួយតួនាទីនៃសារព័ត៌មាន នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៏ ។

ជនត្រូវចោទទាំងពីរបានអះអាងថា ពួកគេពុំមានមធ្យោបាយបង់ប្រាក់សេវាសហមេធាវីរបស់ពួកគេទេ ។ ហេតុដូច្នេះគំរោងការជំនួយផ្នែកច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ នឹងបង់ប្រាក់កម្រៃសេវាក្រុមការពារក្តីរបស់ពួកគេ ស្របពេលការអះអាងនេះ កំពុងត្រូវបានវាយតំលៃ ។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ**/Investigation/Instruction
**លេខ**/No: 002/19-09-2007-ECCC/OCIJ

## សេចក្តីសម្រេចឃាត់ខ្លួន
Décision de placement en Garde á Vue
Police Custody Decision

យើង, **យូ ប៊ុនឡេង** និង **Marcel Lemonde**, សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ២ ២១ ៤៥ ៥១ ៥៧ និង ៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ
**អៀង សារី** ភេទ ប្រុស កើតនៅឆ្នាំ ១៩២៥ នៅភូមិ លឿង វ៉ា ឃុំ លឿង វ៉ា ស្រុក ត្រាវិញ ខេត្តត្រាវិញ (កម្ពុជាក្រោម)
ប្រពន្ធឈ្មោះ **អៀង ធីរិត** (រស់) មានកូន ០៤ នាក់ ឪពុកឈ្មោះ **គឹម រៀម** (ស្លាប់) ម្តាយឈ្មោះ **ត្រាន់ ធិឡឺយ** (ស្លាប់) មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៤៧ B ផ្លូវលេខ ២១ ក្រុម ៣៦ មណ្ឌល ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុងភ្នំពេញ។

យល់ឃើញថា ឈ្មោះ **អៀង សារី** ត្រូវបានដាក់អោយស្ថិតនៅក្រោមការពិនិត្យថ្ងៃនេះ ហើយមេធាវីរបស់ជននេះស្នើសុំអោយលើកពេលកិច្ចពិភាក្សាដេញដោលមុនពេលសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីអាចមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី

យល់ឃើញថាការស្នើសុំនេះមានលក្ខណៈស្របច្បាប់ស្របតាមវិធាន ៦៣-១ នៃវិធានផ្ទៃក្នុងដែលចែងថា " *ជនត្រូវចោទត្រូវមានរយៈពេលគ្រប់គ្រាន់ដើម្បីការពារខ្លួន* " ប៉ុន្តែវិធានផ្ទៃក្នុងមិនបានចែងអំពីការលើកពេលកិច្ចពិភាក្សាដេញដោលនេះឡើយ

យល់ឃើញថាអនុលោមតាមវិធាន ២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើក្នុងពេលដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញ មានបញ្ហាចោទឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុង សហចៅក្រមស៊ើបសួរអាចសម្រេចសេចក្តី "*ដោយយោងជាពិសេសដល់គោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និង នីតិវិធីព្រហ្មទណ្ឌជាធរមាន។ នៅក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងត្រូវដាក់ជូនគណៈកម្មាធិការវិធាន និង នីតិវិធីក្នុងរយៈពេលឆាប់រហ័សដែលអាចធ្វើទៅបាន*" ។

យល់ឃើញថាសំណើសុំធ្វើវិសោធនកម្មទើបតែត្រូវបានដាក់ជូនគណៈកម្មាធិការវិធាន និង នីតិវិធីដើម្បីអាចអោយរៀបចំការលើកពេលកិច្ចពិភាក្សាដេញដោល ហើយកំពុងរង់ចាំសេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គ និង យល់ឃើញថាដើម្បីគោរពសិទ្ធិការពារក្តី ជាការចាំបាច់ដែលត្រូវអនុវត្តវិធាន ២ ដោយយកមកអនុវត្ត ដូចគ្នានូវបញ្ញត្តិនៃវិធាន ៤៥ (៤) នៃវិធានផ្ទៃក្នុង និង សម្រេចឃាត់ខ្លួនលោក **អៀង សារី** សម្រាប់រយៈពេល ៤៨ ម៉ោង។

## ហេតុដូច្នេះ សម្រេច

- បង្គាប់ឃាត់ខ្លួនជាបន្ទាន់ឈ្មោះ អៀង សារី នៅមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងថេរៈវេលា អតិបរិមា ៤៨ ម៉ោង (សែសិបប្រាំបី) ដោយគិតចាប់ពីពេលជូនដំណឹងអំពីដីកានាំខ្លួន និង ក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងបទបញ្ញត្តិនៃវិធាន ៥១ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- ប្រកាសថាការចូលខ្លួនជាលើកដំបូងនឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដោយយោងតាមវិធាន ៥៧ និង ៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ធ្វើនៅភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ១៥ និង ៣០ នាទី

**សហចៅក្រមស៊ើបអង្កេត**
**Co-Investigating Judges**
**Co-juges d'instruction**

MARCEL Lemonde យូ ប៊ុន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Kingdom of Cambodia**

**Nation Religion King**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**

**Criminal Case File /Dossier pénal**

**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ**/Investigation/Instruction

**លេខ**/No: 002/19-09-2007-ECCC/OCIJ

## សេចក្តីសម្រេចឃាត់ខ្លួន

Décision de placement en Garde á Vue

Police Custody Decision

យើង, **យូ ប៊ុនឡេង** និង **Marcel Lemonde**, សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤

បានឃើញវិធាន ២ ២១ ៤៥ ៥១ ៥៧ និង ៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ

**អៀង ធីរិត** ហៅ ភា ភេទ ស្រី កើតនៅឆ្នាំ ១៩៣២ នៅខេត្តបាត់ដំបង ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ ប្តីឈ្មោះ **អៀង សារី** (រស់) មានកូន ០៤ នាក់ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ ៤៧ B ផ្លូវលេខ ២១ ក្រុម ៣៦ មណ្ឌល ៤ សង្កាត់ទន្លេបាសាក់ ខណ្ឌ ចំការមន ក្រុងភ្នំពេញ។

យល់ឃើញថា ឈ្មោះ **អៀង ធីរិត** ត្រូវបានដាក់អោយស្ថិតនៅក្រោមការពិនិត្យថ្ងៃនេះ ហើយមេធាវីរបស់ជននេះស្នើសុំអោយលើកពេលកិច្ចពិភាក្សាដេញដោលមុនពេលសម្រេចលើការឃុំខ្លួនបណ្តោះអាសន្ន ដើម្បីអាចមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារក្តី។

យល់ឃើញថាការស្នើសុំនេះមានលក្ខណៈស្របច្បាប់ស្របតាមវិធាន ៦៣-១ នៃវិធានផ្ទៃក្នុងដែលចែងថា " *ជនត្រូវចោទត្រូវមានរយៈពេលគ្រប់គ្រាន់ដើម្បីការពារខ្លួន* " ប៉ុន្តែវិធានផ្ទៃក្នុងមិនបានចែងអំពីការលើកពេលកិច្ចពិភាក្សាដេញដោលនេះឡើយ។

យល់ឃើញថាអនុលោមតាមវិធាន ២ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ប្រសិនបើក្នុងពេលដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញ មានបញ្ហាចោទឡើងដែលមិនមានចែងក្នុងវិធានផ្ទៃក្នុង សហចៅក្រមស៊ើបសួរអាចសម្រេចសេចក្តី "*ដោយយោងជាពិសេសដល់គោលការណ៍ជាសារវន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និង នីតិវិធីព្រហ្មទណ្ឌជាធរមាន។ នៅក្នុងករណីនេះ សំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុងត្រូវដាក់ជូនគណៈកម្មាធិការវិធាន និង នីតិវិធីក្នុងរយៈពេលឆាប់រហ័សដែលអាចធ្វើទៅបាន*" ។

យល់ឃើញថាសំណើសុំធ្វើវិសោធនកម្មទើបតែត្រូវបានដាក់ជូនគណៈកម្មាធិការ វិធាន និង នីតិវិធី ដើម្បីអាចអោយរៀបចំការលើកពេលកិច្ចពិភាក្សាដេញដោល ហើយកំពុងរង់ចាំសេចក្តីសម្រេចរបស់កិច្ចប្រជុំពេញអង្គ និង យល់ឃើញថាដើម្បីគោរពសិទ្ធិការពារក្តី ជាការចាំបាច់ដែលត្រូវអនុវត្តវិធាន ២ ដោយយកមកអនុវត្តដូចគ្នានូវបញ្ញត្តិនៃវិធាន ៥៥ (៥) នៃវិធានផ្ទៃក្នុង និង សម្រេចឃាត់ខ្លួនលោកស្រី **អៀង ធីរិត** សម្រាប់រយៈពេល ៤៨ ម៉ោង។

## ហេតុដូច្នេះ សម្រេច

- បង្គាប់ឃាត់ខ្លួនជាបន្ទាន់ឈ្មោះ **អៀង ធីរិត** នៅមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងថេរៈវេលា អតិបរិមា ៤៨ ម៉ោង (សែសិបប្រាំបី) ដោយគិតចាប់ពីពេលជូនដំណឹងអំពីដីកានាំខ្លួន និងក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងបទបញ្ញត្តិនៃវិធាន ៥១ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។
- ប្រកាសថាការចូលខ្លួនជាលើកដំបូងនឹងត្រូវធ្វើឡើងនៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដោយយោងតាមវិធាន ៥៧ និង ៦៣ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ធ្វើនៅភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង17និង20នាទី

សហចៅក្រមស៊ើបអង្កេត
Co- Investigating Judges
Co-juges d'instruction

MARCEL Lemonde យូ ប៊ុនឡេង

# ការកែប្រែរចនាសម្ព័ន្ធតុលាការក្នុងកាត់ៈ កំណែទម្រង់គតិយុត្តផ្នែកព្រហ្មទណ្ឌជាតិ និងការផ្តល់អំណាចក្នុងតំបន់

***(តពីលេខមុន)***

## ***ក) តុលាការពិសេសនៅសេរ៉ាឡេអូន***

*ក្រោយពីការផុតរលត់ទៅនៃសង្គ្រាមស៊ីវិលដ៏មហាវិនាសកម្ម ដែលបានឆក់យកអាយុជីវិតប្រជាជនប្រមាណជា៧៥.០០០ នាក់ បានបង្ខំឲ្យប្រជាជនមួយភាគបីនៃប្រជាជនសរុបផ្លាស់ទីលំនៅ និងបង្ហាញឲ្យឃើញនូវលក្ខណៈឃោរឃៅដ៏ធំធេង រដ្ឋាភិបាលរបស់សេរ៉ាឡេអូននិងអង្គការសហប្រជាជាតិបានបង្កើតតុលាការពិសេសសេរ៉ាឡេអូននេះឡើង ។ តុលាការនេះរៀបចំឡើងដើម្បីកាត់ទោសអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះការបញ្ជាឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការបំពានធ្ងន់ធ្ងរផ្សេងៗទៀតទៅលើច្បាប់មនុស្សធម៌អន្តរជាតិក៏ដូចជាឧក្រិដ្ឋកម្មដែលផ្តន្ទាទោសដោយច្បាប់ក្នុងស្រុករបស់ប្រទេសសេរ៉ាឡេអូនផ្ទាល់តែម្តងនៅក្នុងទឹកដីប្រទេសសេរ៉ាឡេអូន ។*

*សន្ធិសញ្ញាមួយរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលសេរ៉ាឡេអូន ដែលជាលក្ខន្តិកៈសម្រាប់តុលាការពិសេសសេរ៉ា-ឡេអូន បានបង្កើតតុលាការនេះក្នុងឆ្នាំ២០០២ ។ នៅពេលដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិយូហ្គោស្លាវីនិងតុលាការឧក្រិដ្ឋកម្មរ៉្វាន់ដា ត្រូវបានបង្កើតឡើងដោយមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអនុលោមតាមជំពូក៧នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ហើយដែលមានយុត្តាធិការតែទៅលើបទឧក្រិដ្ឋអន្តរជាតិប៉ុណ្ណោះនោះ តុលាការពិសេសសេរ៉ាឡេអូនគឺជាតុលាការដែលមានមូលដ្ឋានផ្អែកលើសន្ធិសញ្ញា ហើយមានយុត្តាធិការនិងសមាសភាពចម្រុះ ។ ប្រសើរជាងមានលក្ខណៈត្រឹមតែជាផ្នែកមួយរបស់អង្គការសហប្រជាជាតិឬស្ថិតនៅក្រោមការគ្រប់គ្រងចាត់*


*សកម្មភាពជនជាតិចាមមុស្លីមបំពេញពាក្យបណ្តឹង*

ចែងរបស់អង្គការសហប្រជាជាតិ តុលាការនេះជាអង្គភាពឯករាជ្យមួយដាច់ដោយឡែកពីការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសេរ៉ាឡេអូន ។ ការណ៍នេះបានធ្វើឲ្យតុលាការមានលក្ខណៈខុសប្លែកពីតុលាការអន្តរជាតិនិងតុលាការចម្រុះឯទៀត ដែលមិនមែនជាលទ្ធផលនៃកិច្ចព្រមព្រៀងគ្នារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលក្នុងស្រុក ។ រចនាសម្ព័ន្ធថ្មីនិងប្លែកពីគេរបស់តុលាការពិសេសសេរ៉ាឡេអូនមិនអាចត្រូវបានពិពណ៌នាថាជាការចម្លងតាមដោយចេតនានូវគំរូតុលាការចម្រុះនៅកូសូវ៉ូ ឬទីម័រខាងកើត ឬថាជាសាលាក្តីពិសេសឡើយ ។ តុលាការនេះតំណាងឲ្យការព្យាយាមប្រកបដោយគំនិតច្នៃប្រឌិតដោយអង្គការសហប្រជាជាតិដើម្បីបង្កើតឲ្យមានតុលាការឧក្រិដ្ឋកម្មអន្តរជាតិមានប្រសិទ្ធភាពដែលមានលក្ខណៈបើកចំហច្រើនជាងចំពោះការចូលរួមនិងអំណាចរបស់ប្រជាជនក្នុងស្រុក ។ តុលាការពិសេសសេរ៉ាឡេអូនខុសប្លែកពីគំរូតុលាការនៅកូសូវ៉ូត្រង់ថា តុលាការនេះមិនត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធយុត្តិធម៌របស់សេរ៉ាឡេអូន ប៉ុន្តែជាតុលាការមួយដែលមិនមែនជាតុលាការក្នុងស្រុកដែលមានយុត្តាធិការប្រកួតប្រជែងគ្នា និងមានយុត្តាធិការជាចម្បងទៅលើតុលាការក្នុងស្រុករបស់ប្រទេសសេរ៉ាឡេអូន ។

ទោះបីជាយ៉ាងណាក៏ដោយ តុលាការនេះមានលក្ខណៈដូចគ្នានឹងតុលាការចម្រុះដទៃទៀតត្រង់ថា ជ្រើសរើសបុគ្គលិកក្នុងស្រុកនិងអន្តរជាតិ (ដោយមានចៅក្រមភាគច្រើននៅក្នុងអង្គជំនុំជម្រះជាចៅក្រមបរទេស) និងការអនុវត្តច្បាប់មានការប្រឡាច់បញ្ចូលគ្នារវាងច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់ក្នុងស្រុករបស់សេរ៉ាឡេអូន បើទោះបីជាការចោទប្រកាន់ដែលបានធ្វើឡើងកន្លងមកផ្អែកតែទៅលើច្បាប់អន្តរជាតិក៏ដោយ ។ តុលាការនេះប្រើប្រាស់ការសម្រេចចិត្តរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅរ៉្វាន់ដា (ដោយអនុលោមតាមការបកស្រាយច្បាប់មនុស្សធម៌អន្តរជាតិ) និងការសម្រេចចិត្តរបស់តុលាការកំពូលសេរ៉ាឡេអូន (ដោយអនុលោមតាមការបកស្រាយច្បាប់ក្នុងស្រុករបស់សេរ៉ាឡេអូន) ធ្វើជាប្រទីបបំភ្លឺផ្លូវ ។

មកទល់ពេលនេះ តុលាការពិសេសសេរ៉ាឡេអូនកំពុងត្រូវបានអះអាងថា ជាតុលាការមានប្រសិទ្ធភាព ចំណាយតិច និងមានលក្ខណៈងាយស្រួលចូលរួមជាងសម្រាប់ប្រជាជនក្នុងស្រុក និងមានការផ្តុតបញ្ចេះផ្នែកនយោបាយពីសំណាក់ក្រុមអតីតជនល្មើសតិចតួចជាងសាលាក្តីពិសេសឬតុលាការចម្រុះពីរទៀត ។ វាក៏ទទួលបានការទទួលស្គាល់ច្រើនជាងផងដែរពីសំណាក់អ្នកចេះដឹងនិងសង្គមស៊ីវិលក្នុងស្រុកនិងទទួលបានជោគជ័យច្រើនជាងក្នុងការលើកកម្ពស់កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

កិច្ចព្រមព្រៀងផ្លូវការក្នុងបង្កើតតុលាការនេះ ទើបតែនឹងត្រូវបានធ្វើឡើងនៅពាក់កណ្តាលខែមករា ឆ្នាំ២០០២ប៉ុណ្ណោះ ។ នៅត្រឹមដំណាច់ខែសីហា ឆ្នាំ២០០៤ ដំណើរការរដ្ឋបាលនិងដំណោះស្រាយជម្លោះដ៏ស្មុគស្មាញជាច្រើនត្រូវបានបញ្ចប់ឬជិតបញ្ចប់ៈ ការស៊ើបអង្កេតលើឧក្រិដ្ឋកម្មស្របតាមស្តង់ដារអន្តរជាតិ ការកសាងអគារឃុំឃាំងដ៏សមរម្យ ការកសាងអគារនិងទីធ្លាតុលាការបន្ទាប់ពីមានការប្រកួតប្រជែងគួរឲ្យកត់សម្គាល់ ... ការទទួលបានថាមពលអគ្គិសនីខ្នាត១.៦មេហ្គាវ៉ាត់សម្រាប់ប្រើប្រាស់នៅក្នុងតុលាការ ការកសាងគ្លីនិកសុខភាព ការដំឡើងប្រព័ន្ធទាក់ទងដោយប្រើរលកសំឡេង ការកសាងសមត្ថភាពសន្តិសុខនិងបទដ្ឋាន ។ ការបង្កើតគេហទំព័រ ការបង្កើតឲ្យមានកម្មវិធីផ្សព្វផ្សាយមួយដ៏ទូលំទូលាយនិងមានច្រើនសណ្ឋាន ការបង្កើតការងារនិងវគ្គបណ្តុះបណ្តាលដល់បុគ្គលិកក្នុងស្រុកនិងបរទេសរាប់រយនាក់មានតាំងពីការងារបកប្រែរហូតដល់ការដឹកជញ្ជូន និងការចាប់ផ្តើមការកាត់ក្តីរួមគ្នាបានចំនួនពីរលើក ។ ទាំងអស់នេះគឺជាសមិទ្ធផលដ៏ធំធេងដែលធ្វើឲ្យតុលាការពិសេសនេះមានមោទកភាព ។

ការវិភាគលម្អិតនិងពោរពេញទៅដោយអត្ថន័យរបស់មជ្ឈមណ្ឌលអន្តរជាតិដើម្បីយុត្តិធម៌អន្តរកាលអំពីការងាររបស់តុលាការពិសេសសេរ៉ាឡេអូន គឺជាការវាយតម្លៃមួយដ៏វិជ្ជមានបំផុតនៅក្នុងអំឡុងពេលដែលតុលាការនេះមានអត្ថិភាព ។ បើទោះបីជារបាយការណ៍នេះបង្ហាញពីបញ្ហាប្រឈមច្រើនដែលតុលាការជួបប្រទះនៅក្នុងរយៈពេលជាច្រើនខែបន្តបន្ទាប់មកទៀតក្តី របាយការណ៍នេះបានកត់សម្គាល់ថា បន្ទាប់ពីប្រតិបត្តិការបានរយៈពេល ៨ខែមក តុលាការពិសេសសេរ៉ាឡេអូនបានបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពីអាណត្តិរបស់ខ្លួន ហើយការគ្រប់គ្រងចាត់ចែងនៅក្នុងតុលាការហាក់បីដូចជាមានប្រសិទ្ធភាពគួរសម ។ របាយការណ៍

នេះបន្ថែមថា មកទល់ពេលនេះតុលាការចៀសវាងបាននូវកំណើនយ៉ាងច្រើននិងយ៉ាងគំហុកនៃសាលាក្តីពិសេស ហើយពេលវេលាដែលនៅសល់សម្រាប់តុលាការនិងបញ្ជាកន្ទុះថវិកាបានដាក់សម្ពាធយ៉ាងធ្ងន់មកលើតុលាការ ។

ត្រឹមតែរយៈពេល៣ឆ្នាំប៉ុណ្ណោះ ក្រោយពេលបង្កើតតុលាការ ការកាត់ក្តីចំនួន៣លើកទៅលើជនជាប់ចោទចំនួន៩នាក់កំពុងត្រូវបានប្រព្រឹត្តនៅចំពោះមុខអង្គជំនុំជម្រះចំនួនពីរ ហើយនៅត្រឹមខែសីហា ឆ្នាំ២០០៥ សាក្សីជាង១៥០នាក់បានធ្វើជាកសិណសាក្សី ហើយការចោទប្រកាន់ក្នុងការកាត់ក្តីចំនួនមួយក្នុងចំណោមការកាត់ក្តីទាំងបីលើកត្រូវបានបញ្ចប់ ។ ការបង្កើតឲ្យមានអង្គជំនុំជម្រះលើកទីពីរ នៅខែមករា ឆ្នាំ២០០៥ គឺជាការបោះជំហានឈានទៅមុខមួយយ៉ាងសំខាន់ដែលលើកកម្ពស់ប្រសិទ្ធភាពរបស់តុលាការតាមរយៈការជំរុញឲ្យមានការកាត់ក្តីលើកទី៣ចាប់ផ្តើមនៅក្នុងខែមីនា ឆ្នាំ២០០៥ ។ ក្នុងអំឡុងពេលកាត់ក្តីដែលចាប់ផ្តើមក្នុងខែមិថុនា ឆ្នាំ២០០៤ តុលាការពិសេសបានដំណើរការច្រើននៅក្នុងការដោះស្រាយករណីដ៏សែនពិបាកដោយអង្គជំនុំជម្រះបានបង្ហាញនូវប្រសិទ្ធភាពនិងវិធីធ្វើអន្តរាគមន៍យ៉ាងសកម្មនៅក្នុងការគ្រប់គ្រងចាត់ចែងការជំនុំជម្រះ ។ ក្រឡាបញ្ជីបានលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងចាត់ចែងការជំនុំជម្រះជាបន្តបន្ទាប់ ។ ការងាររបស់ការិយាល័យមេធាវីចុងចោទតំណាងឲ្យគំនិតច្នៃប្រឌិតមួយសម្រាប់តុលាការអន្តរជាតិនិងតុលាការចម្រុះ ។ តុលាការពិសេសក៏បានបង្កើតឲ្យមានកម្មវិធីការពារនិងឧបត្ថម្ភគាំទ្រសាក្សីដែលមានលក្ខណៈល្អប្រសើរនិងទូលំទូលាយផ្តល់សន្តិសុខនិងថ្នាំសង្កូវ ផ្តល់ការប្រឹក្សាផ្នែកចិត្តសង្គម ការស៊ើបអង្កេតលើករណីគំរាមកំហែង និងការផ្លាស់ប្តូរទីលំនៅនៅក្នុងករណីចាំបាច់ ។ កម្មវិធីដែលមានលក្ខណៈល្អប្រសើរនិងច្នៃប្រឌិតបំផុតនោះអាចថាជាកម្មវិធីផ្សព្វផ្សាយព័ត៌មានរបស់តុលាការដើម្បីបង្កើនការយល់ដឹងអំពីការងារតុលាការក្នុងចំណោមជនជាតិសេរ៉ាឡេអូន ដែលរួមមានការបណ្តុះបណ្តាលប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ការផលិតឯកសារសោតទស្សន៍និងខ្សែភាពយន្តអំពីសកម្មភាពនៅទូទាំងប្រទេសនិងការរួមប្រជុំរបស់សហគមន៍ ។

ទោះបីជាមានសមិទ្ធិផលច្រើនបែបនេះក៏ដោយ ក៏នៅតែមានការព្រួយបារម្ភខ្លះៗអំពីដំណើរការរបស់តុលាការនេះដែរ ។ តុលាការពិសេសនេះនឹងទទួលបានជោគជ័យ ប្រសិនបើតុលាការឲ្យតម្លៃភាពចម្រុះថាជាស្នូលសំខាន់បំផុតរបស់ខ្លួនដើម្បីធានាថាទស្សនៈរបស់ប្រជាជនសេរ៉ាឡេអូនត្រូវបានស្តាប់ឮនៅក្នុងចំណោមអ្នកដែលមានសិទ្ធិសម្រេចនៅក្នុងតុលាការ ។ តាមទស្សនៈមេធាវីខាងសិទ្ធិមនុស្សល្បីៗនិងអតីតរដ្ឋអាជ្ញាតុលាការពិសេស អាដុលតេហ្សនកូល រដ្ឋាភិបាលសេរ៉ាឡេអូនបានប្រព្រឹត្តកំហុសធ្ងន់យ៉ាងធ្ងន់ធ្ងរ នៅពេលខ្លួនធ្វើវិសោធនកម្មលើលក្ខន្តិកៈដើម្បីដកចេញនូវលក្ខខណ្ឌដែលថារដ្ឋអាជ្ញារងត្រូវមានសញ្ជាតិសេរ៉ាឡេអូន ។ បញ្ញត្តិទាំងនេះត្រូវបានបង្កើតឡើងដើម្បីជ្រើសរើសនិងបណ្តុះបណ្តាលមន្ត្រីសេរ៉ាឡេអូនឲ្យបានកាន់តែច្រើនថែមទៀតនៅក្នុងតុលាការគ្រប់ជាន់ថ្នាក់តាមរយៈកម្មវិធីកសាងសមត្ថភាពកម្រិតខ្ពស់នានា ។ មានអន្តរកម្មតិចតួចរវាងចៅក្រមនិងបុគ្គលិកតុលាការពិសេសជាមួយចៅក្រមនិងបុគ្គលិកតុលាការជាតិ បើទោះបីជាការជំរុញឲ្យមានការប្រាស្រ័យទាក់ទងគ្នានេះនឹងជះឥទ្ធិពលធ្ងន់ធ្ងរទៅលើប្រព័ន្ធយុត្តិធម៌ក្នុងស្រុកដែលជាទិដ្ឋភាពមួយក្នុងការពង្រឹងនីតិរដ្ឋនៅសេរ៉ាឡេអូនក៏ដោយ ។ តុលាការនេះគួរតែបានធ្វើឲ្យមានទំនាក់ទំនងគ្នារវាងគំនិតផ្តួចផ្តើមនិងការផ្សព្វផ្សាយឲ្យបានល្អប្រសើរជាងមុនពេលទៅដល់សង្គមស៊ីវិលៈ គឺបង្កើនកម្មវិធីវិទ្យុនិងការចូលរួមឲ្យបានកាន់តែច្រើននៅក្នុងការផ្សព្វផ្សាយជាសាធារណៈ ។

តុលាការពិសេសសេរ៉ាឡេអូនជួបឧបសគ្គដោយសារមរណភាពរបស់ជនជាប់ចោទសំខាន់ពីររូបគឺ ហ៊្វូដេ សានកូ និង សាមបូការី និងដោយសារការបាត់ខ្លួននិងការសន្មតថាការស្លាប់របស់ជនជាប់ចោទទី៣ ឈ្មោះ ចននី ប៉ូល កូរូម៉ា ។ ជនជាប់ចោទទី៤ ឈ្មោះ ឆាល ថេល័រ បានរត់គេចរួចពីការចាប់ខ្លួននៅក្នុងប្រទេសនីហ្សេរីយ៉ាអស់រយៈពេលជាច្រើនឆ្នាំ ដោយមានការដឹងឮយ៉ាងសុសសាយនិងគាំទ្រពីសំណាក់មេដឹកនាំនានាក្នុងពិភពលោក ។ ប៉ុន្តែដើម្បីបោះជំហានមួយយ៉ាងវែងឆ្ពោះទៅរកការផ្តល់យុត្តិធម៌សម្រាប់អំពើឃោរឃៅដែលបានកើតឡើងនៅទ្វីបអាហ្វ្រិកប៉ែកខាងលិច គាត់ត្រូវបានប្រធានាធិបតីនីហ្សេរីយ៉ា អូបាសានចូប្រគល់ខ្លួនទៅឲ្យប្រធានាធិបតីដែលទើបជ្រើសតាំងថ្មីរបស់ប្រទេសលីបេរីយ៉ា ឈ្មោះ អេឡែន ចនស៊ុន ស័រលីហ្វ ដែលភ្លាមៗនោះ

បានបញ្ជូនគាត់ទៅកាន់តុលាការពិសេសនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០០៦ ។ ប្រការគួរឲ្យភ្ញាក់ផ្អើល ថេល័រ បានបង្ហើបឲ្យដឹងថា គាត់នឹងធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីធ្វើឲ្យអន្តរាយដល់ការកាត់ទោសគាត់ ដោយការជជីកសួរអំពីនីត្យានុកូលភាពរបស់តុលាការ ធ្វើការចោទប្រកាន់ដើម្បីធ្វើឲ្យអាប់ឱនទាំងតុលាការនិងអ្នកទាំងឡាយដែលគាំទ្រឲ្យមានការកាត់ទោសគាត់ និងប្រើប្រាស់ក្រុមអ្នកតំណាងគាត់និងអ្នកធ្វើច្បាប់ខ្លះដើម្បីទាមទារឲ្យមានការប្រានចោលនូវការសម្រេចប្រគល់ខ្លួនគាត់ឲ្យទៅតុលាការ ការបន្តភាពវឹកវរនិងភាពចលាចលរយៈពេលយូរនៅម៉ុនរ៉ូវៀ ។ បើទោះបីជាការកាត់ទោសថេល័រ ជាការសន្យាផ្តល់យុត្តិធម៌ទៅឲ្យជនរងគ្រោះសេរ៉ាឡេអូនដោយសារសង្គ្រាមដ៏សាហាវដែលបានទទួលរងចាំអស់រយៈពេលដ៏យូរនិងជាការសន្យាលើកកម្ពស់នីតិរដ្ឋនៅក្នុងតំបន់មួយដែលបំផ្លិចបំផ្លាញដោយសារអំពើហិង្សាទោះក៏ដោយ ការកាត់ទោសនេះត្រូវបានកំណត់ថានឹងធ្វើឡើងនៅអឺរ៉ុបច្រើនជាងនៅប្រទេសសេរ៉ាឡេអូន ។ នេះជារឿងពិតមួយដែលត្រូវបានសារព័ត៌មាននិងសង្គមស៊ីវិលនៅសេរ៉ាឡេអូនថ្កោលទោសជាទូទៅ ។ ចំណុចមិនល្អមួយទៀតរបស់តុលាការគឺអស្ថិរភាពផ្នែកថវិការបស់ខ្លួនត្រូវបានបង្ខំតាំងពីដំបូងឲ្យផ្អែកទាំងស្រុងទៅលើវិភាគទានស្ម័គ្រចិត្ត នោះតុលាការសេរ៉ាឡេអូនបានជួបប្រទះនូវកង្វះថវិកាភ្លាមៗដែរ ។ នៅខែមីនា ឆ្នាំ២០០៤ បន្ទាប់ពីមានសំណើរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិសុំឲ្យមានថវិកាជំនួយចំនួន៤០លានដុល្លារ ដើម្បីជួយដោះស្រាយការលំបាកផ្នែកហិរញ្ញវត្ថុរបស់តុលាការ ហើយមហាសន្និបាតអង្គការសហប្រជាជាតិបានផ្តល់ថវិកាចំនួន ៣៣លានដុល្លារ ដើម្បីជួយដល់ប្រតិបត្តិការតុលាការនេះរហូតចុងឆ្នាំ២០០៥ ។ ទោះបីជាយ៉ាងនេះក៏ដោយ ជំនួយនេះមិនអាចទូទាត់ការចំណាយសម្រាប់ប្រតិបត្តិការចុងក្រោយរបស់ខ្លួនឬក៏ដំណាក់កាលក្រោយបញ្ចប់អាណត្តិរបស់ខ្លួនបានគ្រប់គ្រាន់ទេ ។

បញ្ហានេះមិនអាចបន្ទោសទៅលើបុគ្គលិកតុលាការ ដែលធ្វើការបានច្រើនដោយប្រើធនធានតិចតួចនោះទេ គួរតែបន្ទោសទៅលើរដ្ឋាភិបាលនានាដែលមិនបានរួមវិភាគទានដោយស្ម័គ្រចិត្ត ឬទៅលើអ្នកដែលបានសន្យា ក្នុងការខកខានមិនបានគោរពតាមការសន្យារបស់ខ្លួន ។ ដូចគ្នានេះដែរ អង្គសន្និបាតក៏មានទំនួលខុសត្រូវចំពោះការមិនអនុម័តផ្តល់ថវិកាបន្ថែមដែរ ។ ទោះបីជាយ៉ាងនេះក៏ដោយ ថវិកាមិនទៀងទាត់របស់តុលាការបានឆ្លុះបញ្ចាំងឲ្យឃើញជាអវិជ្ជមាននូវភាពងាយរងគ្រោះរបស់តុលាការចម្រុះទូទៅដែលមិនអាចពឹងផ្អែកលើវិភាគទានដែលបានវាយតម្លៃនៅក្នុងអង្គការសហប្រជាជាតិដូចដែលតុលាការអន្តរជាតិបណ្តោះអាសន្នអាចធ្វើបាន ។

តុលាការពិសេសសេរ៉ាឡេអូន ហាក់បីដូចជាល្អជាងគំរូតុលាការចម្រុះដែលមួយផ្នែកធំដោយសារតែមានការដឹកនាំដ៏ល្អរបស់អតីតក្រឡាបញ្ជី រ៉ូប៊ីន វីនសេន អតីតរដ្ឋអាជ្ញា ដេវីត ក្រេន និងគណៈកម្មាធិការគ្រប់គ្រង ។ ដូចដែលបានរៀបរាប់កន្លងមក តុលាការបានបន្ថែមចំណុចខ្លាំងទៅឲ្យតុលាការចម្រុះនិងមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់ បើទោះបីជាជួបប្រទះការលំបាកក្តី រួមទាំងការបង្កើតរចនាសម្ព័ន្ធមួយដោយមានត្រឹមតែថវិកាបន្តិចបន្តួចនិងមិនប្រាកដប្រជានៅក្នុងប្រទេសក្រីក្របំផុតមួយដែលទទួលរងការបំផ្លិចបំផ្លាញដោយសារជម្លោះ ។ វាហាក់បីដូចជាឆាប់រហ័សពេកក្នុងការវាយតម្លៃថា តុលាការនេះជាជោគជ័យមួយយ៉ាងប្រាកដ ឬក៏ធ្វើការកត់សម្គាល់ថា តុលាការនេះនឹងទទួលបានជោគជ័យក្នុងការបង្កើតឲ្យមាននីតិរដ្ឋនៅក្នុងប្រទេសមួយដែលនៅតែរងគ្រោះដោយសារកង្វះជំនឿជឿជាក់ទៅលើស្ថាប័នរដ្ឋ អំពើពុករលួយ អតិផរណា ការមិនសប្បាយចិត្តរបស់អតីតក្រុមយោធា កង្វះខាតខាងឱកាសសេដ្ឋកិច្ច និងការកាត់បន្ថយបុគ្គលិករបស់ *UNAMSIL* ក៏ប៉ុន្តែសមិទ្ធផលរបស់តុលាការនេះមានទំហំធំធេងបើគិតទៅដល់ការលំបាកជាច្រើនដែលតុលាការនេះជម្នះបាន ។

### ឃ) អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ក្នុងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា ចន្លោះពេលពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាប្រហែលជា១,៧លាននាក់ ដែលត្រូវជាប្រមាណមួយភាគបួននៃប្រជាជនសរុបត្រូវបានសម្លាប់ ឬស្លាប់ដោយអត់អាហារ និងជំងឺ ។ នៅពេលដែលមេដឹកនាំខ្មែរក្រហមបានព្យាយាមប្រែក្លាយប្រទេសកម្ពុជាឲ្យទៅជារដ្ឋកុម្មុយនីស្តមួយដោយពឹងផ្អែកលើវិស័យកសិកម្ម

ទាំងស្រុងខ្មែរក្រហមបានរៀបចំផែនការយ៉ាងល្អិតល្អន់និងបានអនុវត្តគោលនយោបាយ សម្លាប់រង្គាល និងការវេទនាគួរឲ្យរន្ធត់មកលើប្រជាជន ។ អន្តរាគមន៍របស់ប្រទេសវៀតណាមបានផ្តួលរំលំខ្មែរក្រហមនិងបានបន្តុបរដ្ឋាភិបាលកម្ពុជាមួយ ។ ខ្មែរក្រហមដែលទទួលបរាជ័យបានដកថយទៅកាន់មូលដ្ឋានទ័ពដ៏រឹងមាំរបស់ខ្លួននៅតាមព្រំប្រទល់ថៃ ដែលនៅទីនោះពួកគេត្រូវបានជួយនិងផ្តល់ជំនួយដោយប្រទេសចិន ថៃ និងសហរដ្ឋអាមេរិក ។ អ្នកទាំងនោះត្រូវបានបំពាក់អាវុធឡើងវិញនិងបន្តប្រព្រឹត្តឧក្រិដ្ឋកម្មមកលើមនុស្សជាតិដោយបើកការវាយប្រយុទ្ធមកលើកម្ពុជាក្នុងឋានៈជាកងកម្លាំងឧទ្ទាម ។

ជំនួយឧបត្ថម្ភដ៏សកម្មរបស់សហរដ្ឋអាមេរិក និងប្រទេសចិនទៅឲ្យពួកប្រល័យពូជសាសន៍ខ្មែរក្រហមនៅក្នុងប្រទេសថៃ បានធ្វើឲ្យកិច្ចខិតខំរបស់អន្តរជាតិដើម្បីឲ្យមានការដាក់ទណ្ឌកម្មទៅលើអ្នកប្រព្រឹត្តរាលពិឃាតនេះ នៅឯអង្គការសហប្រជាជាតិនិងនៅក្នុងវេទិកាផ្សេងទៀតក្លាយជាអសារបង់ ។ លើសពីនេះភាពឯកាដែលរបបកុម្មុយនីស្តកម្ពុជាជួបប្រទះក្នុងអំឡុងសង្គ្រាមត្រជាក់បន្ទាប់ពីការផ្តួលរលំនៃរបបខ្មែរក្រហមបានធានាឲ្យមានការទទួលស្គាល់ ឬជំនួយពីអន្តរជាតិតិចតួច ឬគ្មានទាល់តែសោះ សម្រាប់ការស្វះស្វែងរកយុត្តិធម៌ជាបណ្តោះអាសន្នដោយកម្ពុជានៅប្រទេសកម្ពុជា ។ ឧទាហរណ៍ ក្រោយពីការផ្តួលរំលំខ្មែរក្រហម រដ្ឋាភិបាលកម្ពុជាដែលស្ថិតនៅក្រោមឥទ្ធិពលវៀតណាមបានធ្វើការកាត់ទោស ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខនៅក្នុងឆ្នាំ១៩៧៩ ដោយបានប្រមែប្រមូលឯកសារដ៏មានតម្លៃអំពីអំពើឃោរឃៅរបស់ខ្មែរក្រហមបានយ៉ាងសន្ធឹកសន្ធាប់ ។ ថ្វីបើវាជាការកាត់ក្តីដំបូងបង្អស់របស់ពិភពលោកទៅលើអំពើប្រល័យពូជសាសន៍ ស្របទៅតាមគោលនយោបាយរបស់អង្គការសហប្រជាជាតិ និងជាការកាត់ក្តីដំបូងរបស់រដ្ឋាភិបាលមួយដោយផ្អែកការចោទប្រកាន់របស់ខ្លួនទៅលើការរំលោភបំពានសិទ្ធិមនុស្សក៏ដោយ ក៏ការខិតខំនេះត្រូវបានច្រានចោលដោយសហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្តសង្គ្រាមត្រជាក់របស់ខ្លួនថា ជាតុលាការកង់គូរូ ព្រោះថាពិរុទ្ធភាពរបស់ចុងចោទត្រូវបានចាត់ទុកថាជាការសន្និដ្ឋានមួយលឿនពេក ហើយចុងចោទត្រូវបានកាត់ទោសដោយកំបាំងមុខ ។ ដូចគ្នានេះដែរ កិច្ចខិតខំប្រឹងប្រែងដទៃទៀតដើម្បីព្យាយាមធ្វើឲ្យមានគំនិតផ្តួចផ្តើមប្រកបដោយអត្ថន័យដើម្បីផ្តល់យុត្តិធម៌បណ្តោះអាសន្នត្រូវបានធ្វើមិនដឹងមិនឮ ឧទាហរណ៍ដូចជាការព្យាយាមរបស់រដ្ឋាភិបាលកម្ពុជានិងសង្គមស៊ីវិលក្នុងការបង្កើតឲ្យមានសារមន្ទីរមួយចំនួននិងទិវាចងកំហឹងជាដើម ។ ករណីលើកលែងដែលគួរឲ្យកត់សម្គាល់ចំពោះការមើលស្រាលរបស់សហគមន៍អន្តរជាតិទៅលើកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការផ្តល់យុត្តិធម៌បណ្តោះអាសន្នគឺការទទួលស្គាល់យ៉ាងទូលំទូលាយនូវកម្មវិធីប្រល័យពូជសាសន៍កម្ពុជារបស់សាកលវិទ្យាល័យយែល និងដៃគូរបស់ខ្លួនគឺមជ្ឈមណ្ឌលឯកសារកម្ពុជាដែលត្រូវបានឃោសនាផ្សព្វផ្សាយយ៉ាងត្រឹមត្រូវ ថាជាប្រភេទគណៈកម្មការស្វែងរកការពិតក្រៅផ្លូវការមួយ ។

អន្តរជាតិយកចិត្តទុកដាក់ច្រើនជាងមុនមកលើកម្ពុជានៅពេលដែលខ្មែរក្រហមបានបែកខ្ញែកគ្នាអស់ ក្រោយពីមានការប្រកាសលើកលែងទោសដោយរដ្ឋាភិបាលកម្ពុជាជាថ្នូរនឹងការចុះចូលរបស់កងទ័ពខ្មែរក្រហមដ៏ច្រើន (នៅឆ្នាំ១៩៩៦) និងមរណភាពរបស់ ប៉ុល ពត ក្នុងឆ្នាំ១៩៩៨ ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីកម្ពុជាលោក ហ៊ុន សែន និងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានស្នើសុំឲ្យមានជំនួយពីអង្គការសហប្រជាជាតិ ដើម្បីនាំខ្លួនបុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍យកមកកាត់ទោស ។ ការចរចាយ៉ាងតឹងតែងបានបន្តអស់រយៈពេល៦ឆ្នាំរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា និងនៅក្នុងក្របខ័ណ្ឌរដ្ឋាភិបាលកម្ពុជា ។

នៅទីបំផុត អនុស្សរណៈយោគយល់គ្នាមួយបានក្លាយជាប្រធានបទចរចារវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ។ អនុស្សរណៈនេះត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ ហើយត្រូវបានអនុម័តជាឯកច្ឆន្ទដោយសភាជាតិរបស់កម្ពុជានៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ ។ អនុស្សរណៈនេះបង្កើតឲ្យមានយន្តការសម្រាប់តុលាការព្រហ្មទណ្ឌចម្រុះមួយដំបូងបង្អស់ដែលនឹងអនុវត្តច្បាប់រដ្ឋប្បវេណី ហើយដែលនឹងនាំទៅរកការអនុម័តច្បាប់ស្តីពីការបង្កើត

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ផ្តល់សិទ្ធិឲ្យសហចៅក្រមស៊ើបអង្កេតទទួលបន្ទុកការស៊ើបអង្កេត និងឲ្យសហព្រះរាជអាជ្ញាត្រៀមចោទប្រកាន់ទៅលើជនជាប់សង្ស័យ ហើយក៏នឹងមានវត្តមានចៅក្រមជាតិនិងអន្តរជាតិដែលបម្រើការងារនៅទីនោះ និងជារឿងមួយគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា ចៅក្រមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញត្រូវតែជាជនជាតិកម្ពុជា ដែលខុសប្លែកគ្នាពីតុលាការពិសេសនៅប្រទេសសេរ៉ាឡេអូននៅត្រង់ថា ការតែងតាំងចៅក្រមអាចត្រូវបានធ្វើឡើងដោយសេរ៉ាឡេអូនខ្លួនឯង ដោយអ្នកទាំងនោះមិនចាំបាច់ជាជនជាតិសេរ៉ាឡេអូននោះទេ ។ ការិយាល័យរដ្ឋបាលអង្គជំនុំជម្រះនេះនឹងដឹកនាំដោយប្រធានម្នាក់ជាជនជាតិកម្ពុជា (លោក ស៊ាន វិសុទ្ធ) និងអនុប្រធានម្នាក់ដែលមិនមែនជាជនជាតិកម្ពុជា ។ តុលាការនេះក៏នឹងមានយុត្តាធិការចម្រុះលើឧក្រិដ្ឋកម្មដែលផ្តន្ទាទោសដោយច្បាប់ក្នុងស្រុករបស់កម្ពុជានិងច្បាប់អន្តរជាតិ ។ ជាអកុសល លក្ខន្តិកៈរបស់អង្គជំនុំជម្រះនេះក៏ដូចជាច្បាប់អន្តរជាតិភាគច្រើនផងដែរ មិនសំដៅទៅលើឧក្រិដ្ឋកម្មជាក់លាក់ណាមួយដែលពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហមទេ លើកលែងតែឧក្រិដ្ឋកម្មប្រល័យពូជសាសន៍វប្បធម៌ ។ តុលាការនេះមានទីតាំងនៅជាយរាជធានីទីក្រុងភ្នំពេញ នៅក្នុងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ហើយការប្រើប្រាស់ភាសាជាផ្លូវការនៅក្នុងតុលាការនេះគឺជាភាសាខ្មែរ ដោយមានការប្រែសម្រួលជាភាសាអង់គ្លេស និងបារាំង ។

រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនឹងចែករំលែកបន្ទុកថវិកាចំនួន៥៦,៣លានដុល្លារ ដែលជាគម្រោងថវិកាដែលត្រូវបានប៉ាន់ស្មានសម្រាប់រយៈពេល៣ឆ្នាំ ដែលក្នុងនោះវិភាគទានដោយស្ម័គ្រចិត្តពីអង្គការសហប្រជាជាតិមានចំនួន៤៣លានដុល្លារ (២១លានដុល្លារនៃចំនួននេះនឹងត្រូវផ្តល់ដោយប្រទេសជប៉ុន) ហើយរដ្ឋាភិបាលកម្ពុជានឹងត្រូវបំពេញថវិកាដែលនៅខ្វះចំនួន ១៣,៣លានដុល្លារ ។ សម្រាប់ការចំណាយផ្សេងៗពីនេះ អង្គការសហប្រជាជាតិដែលនឹងត្រូវទទួលខុសត្រូវប្រាក់បៀវត្សរ៍របស់បុគ្គលិកអន្តរជាតិ ហើយអាជ្ញាធរកម្ពុជានឹងចំណាយប្រាក់បៀវត្សរ៍សម្រាប់បុគ្គលិកកម្ពុជា ។ បុគ្គលិកកម្ពុជានឹងទទួលបានប្រាក់បៀវត្សរ៍ត្រឹមតែ៥០ភាគរយនៃប្រាក់បៀវត្សរ៍ដែលបុគ្គលិកអង្គការសហប្រជាជាតិទទួលបានប៉ុណ្ណោះ ។ ទោះជាមានភាពមិនស្មើភាពគ្នានេះក៏ដោយ តំណាងរបស់រដ្ឋាភិបាលកម្ពុជានៅមានសុទិដ្ឋិនិយមថា បុគ្គលិកតុលាការនឹងអាចជម្នះបញ្ហានេះបាន ហើយសហការគ្នាបានល្អនៅក្នុងវង្វង់ការងារ ។ រដ្ឋាភិបាលកម្ពុជាបានថ្លែងថា ខ្លួននឹងរួមវិភាគទានជាសាច់ប្រាក់ចំនួន១,៥លានដុល្លារ ហើយនឹងព្យាយាមស្វែងរកថវិកាចំនួន១៣,៣លានដុល្លារទៀត តាមរយៈជំនួយទ្វេភាគីដោយផ្ទាល់ ។ រដ្ឋាភិបាលកម្ពុជាក៏នឹងរួមវិភាគទានជាវត្ថុដែលគិតជាទឹកប្រាក់មានចំនួន៥,២លានដុល្លារផងដែរក្នុងនោះមានដីធ្លីអគារ ការចំណាយក្នុងពេលឃុំខ្លួនជនជាប់ចោទ ការចំណាយថ្លៃសុខភាព ការចំណាយក្នុងការផ្តល់សន្តិសុខសម្រាប់តុលាការ និងការស៊ើបអង្កេត ការការពារសាក្សី និងការផ្តល់ទីផ្នាការដោយឥតគិតថ្លៃដល់បុគ្គលិកអន្តរជាតិសម្រាប់រយៈពេល៣ឆ្នាំ ។ ប្រសិនបើបូកសរុបវិភាគទានជាសម្ភារជាមួយនឹងវិភាគទានជាសាច់ប្រាក់ចំនួន១,៥លានដុល្លារនោះ វិភាគទានសរុបរបស់កម្ពុជាមានប្រមាណជា១០ភាគរយនៃថវិកាសរុបដែលត្រូវចំណាយសម្រាប់តុលាការនេះ ។

អង្គជំនុំជម្រះវិសាមញ្ញត្រូវបានរំពឹងទុកថា នឹងដំណើរការរយៈពេល៣ឆ្នាំក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់រានមានជីវិតតិចជាង១០នាក់ ដែលភាគច្រើនក្នុងចំណោមនោះស្ថិតនៅក្នុងពន្ធនាគាររួចជាស្រេចទៅហើយ (ដូចជា តាម៉ុក និង ឌុច) ។ អង្គជំនុំជម្រះវិសាមញ្ញនឹងមិនកាត់ទោសជនដែលដល់ដែលមានតួនាទីមធ្យម ឬតូចតាចនោះទេ អាស្រ័យហេតុនេះការកាត់ក្តីដោយអង្គជំនុំជម្រះវិសាមញ្ញនឹងមានលក្ខណៈជានិមិត្តរូប ។ តុលាការនេះក៏មិនអាចកាត់ទោសមេដឹកនាំខ្មែរក្រហមជាច្រើនដែលទទួលខុសត្រូវដោយផ្ទាល់ចំពោះអំពើឃោរឃៅយ៉ាងធំធេងនេះ ដូចជាអ្នកដែលបានស្លាប់បាត់បង់ជីវិតទៅហើយនៅក្នុងការធ្វើវិសុទ្ធកម្ម ឬដោយសារការសម្លាប់នៅក្នុងរបបខ្មែរក្រហមនិងក្នុងពេលក្រោយមកទៀតនោះរួមទាំង ប៉ុល ពត ផង ។ **(នៅមានត)**

**អេតែល ហ៊ីហ្គនេត**

# បទពិសោធន៍របស់ ស្រេង ធា នៅក្នុងរបបកម្ពុជាកម្ពុជាប្រជាធិបតេយ្យ

ស្រេង ធា ហៅ អ៊ឹង អៀងធា កើតនៅភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ មុនឆ្នាំ១៩៧៥ ធា រស់នៅសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និង បានប្រលងបញ្ចប់ថ្នាក់នៅវិទ្យាល័យទួលស្វែង (បច្ចុប្បន្នសារមន្ទីរទួលស្លែង) ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបង្ខំឲ្យគ្រួសារ ធា ចេញពីផ្ទះដោយបានប្រាប់ថា នៅទីនេះគ្មានអ្វីសម្រាប់បរិភោគទេដូច្នេះត្រូវទៅរស់នៅទៅតំបន់រំដោះ ព្រោះនៅទីនោះអង្គការបានរៀបកន្លែងស្នាក់នៅ និងមានអាហារបរិភោគគ្រប់គ្រាន់ ។ ស្រេង មិនចង់ចាកចេញពីផ្ទះទេ ប៉ុន្តែដោយឃើញគ្រួសារមួយចំនួនដែលប្រកែកមិនព្រមចេញត្រូវពួកខ្មែរក្រហមបាញ់គំរាម ខ្លះត្រូវចាប់ចង និងខ្លះត្រូវបាញ់សម្លាប់ចោលនៅនឹងកន្លែង ។ ឃើញដូច្នេះ ធា ក៏សម្រេចចិត្តធ្វើដំណើរចេញទៅតាមស្ពានព្រះមុនីវង្សឆ្ពោះទៅវត្តចំពុះក្អែកដែលជាស្រុកកំណើត ។ នៅលើស្ពានពោរពេញដោយហ្វូងមនុស្សកកស្ទះព្រោះគ្រួសារខ្លះនៅរារែកមិនចង់ចាកចេញ ព្រោះពួកខ្មែរក្រហមឃោសនាថា ៣ថ្ងៃក្រោយនឹងអនុញ្ញាតឲ្យមកនៅផ្ទះចាស់របស់ខ្លួនវិញ ។ ធា ទៅស្នាក់នៅវត្តចំពុះក្អែកបានមួយសប្តាហ៍ ប៉ុន្តែដោយគ្មានម្ហូបអាហារសម្រាប់បរិភោគ ក៏សម្រេចចិត្តធ្វើដំណើរទៅស្រុកកោះធំ ព្រោះមានអ្នកស្គាល់រស់នៅទីនោះ ។ ដោយមិនអាចធ្វើដំណើរតាមថ្មើរជើងបាន ព្រោះមានឪពុកម្តាយជរា ធា បានរៀបចំអីវ៉ាន់ដាក់លើទូករួចចែវឆ្ពោះទៅទិសខាងត្បូង រហូតម៉ោង៨ទៀបភ្លឺទើបទៅដល់ ។ ស្រេង ធា ទៅស្នាក់នៅផ្ទះចាស់មួយខ្នងដែលគេបោះបង់ចោលក្នុងភូមិតាមេស ឃុំកោះធំខ ស្រុកកោះធំ ខេត្តកណ្តាល ។ នៅទីនោះ ធា ពុំមានអាហារសម្រាប់បរិភោគ ហើយឪពុកម្តាយចាស់ជរាទៀត ដោយមានការអាណិតអាសូរអ្នកភូមិបានផ្តល់ជា ពោត សណ្តែក អង្ករឲ្យគ្រួសារ ធា សម្រាប់ដាំហូបបណ្តោះអាសន្ន ។

ក្រោយមក ធា ត្រូវអង្គការរើសបញ្ចូលក្នុងសហករណ៍ភូមិ ធ្វើការងារដូចជា បោចស្មៅ ដាំពោត ធ្វើស្រែចម្ការ ។ ឆ្នាំ១៩៧៧ ប្អូនប្រុសរបស់ ធា ឈ្មោះ ចៃ ធ្វើជាកងចល័តនៅឃុំកំពង់កុង បានយកបបរដែលអង្គការចែកឲ្យយកទៅគ្រលែងចោល ។ បន្ទាប់មក ចៃ ត្រូវពួកឈ្លបចាប់យកទៅឃុំឃាំង រួចសម្លាប់ដោយចោទប្រកាន់ថាប្រឆាំងនឹងអង្គការ ។ ចំណែកប្អូន ២នាក់ទៀត ខេង និង ស្រេង ត្រូវអង្គការបញ្ជូនតាមកប៉ាល់ទៅខេត្តបាត់ដំបង ។

រំលងបានមួយរយៈ ធា ក៏ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើកងចល័តនៅបឹងធំខាងកើតទន្លេ ។ នៅទីនោះប្រធានកងឈ្មោះ កុល បានដាក់កម្រិតឲ្យជីកប្រឡាយដែលមានជម្រៅ ១,៣០ម៉ែត្រ ទៅ ២,៣០ម៉ែត្រ និងទទឹង ៣ម៉ែត្រ ប្រសិនបើធ្វើមិនគ្រប់ផែនការដាក់ឲ្យ ត្រូវមានទោស ឬមិនបើករបបអាហារឲ្យ ។ ធា ខិតខំប្រឹងប្រែងធ្វើការងារមិនដែលត្អូញត្អែរឡើយ រហូតមានដំបៅហើមរលួយនៅស្មងជើងដោយសារប៉ះនឹងបង្គីពេលរែកដី ។ បន្ទាប់មកប្រធានកងបានផ្លាស់ ធា ឲ្យមកធ្វើជាអ្នកដួលដុលបង្គី និង





សកម្មភាពជនជាតិចាមមុស្លីមបំពេញពាក្យបណ្តឹង

ប៉ែលចាស់ៗដើម្បីយកទៅប្រើប្រាស់បន្តទៀត ។ ថ្ងៃមួយប្រធានកងបានសួររកអ្នកដែលចេះកាត់កញ្ចក់ធ្វើអំពូលដាក់ចង្កៀងប្រេងកាតបាំងខ្យល់ ប៉ុន្តែគ្មាននរណាចង់ធ្វើកិច្ចការនេះឡើយព្រោះពុំមានឧបករណ៍គ្រប់គ្រាន់ ។ ដោយពុំមានមនុស្ស កុល បានចាត់តាំង ឆា ឲ្យធ្វើកិច្ចការនេះ ។ ដំបូង ឆា យកញញួរមកដំបំបាក់កញ្ចក់បណ្តាលឲ្យកញ្ចក់បែក ។ ឆា មានការភិតភ័យយ៉ាងខ្លាំង ព្រោះខ្លាចអង្គការចាប់កំហុស ។ ដោយគ្មានជម្រើស ឆា យកបំណែកពាងដែលបែកយកទៅឆូតលើកញ្ចក់រហូតមានស្នាម ទើបវាយបំបាក់រួចដុសឲ្យស្មើយកទៅដាក់ចង្កៀង ។ ចាប់តាំងពីពេលនោះមក ប្រធានកងតែងតែមកពិភាក្សាជាមួយ ឆា នៅមុនពេលធ្វើកិច្ចការអ្វីមួយ ដូចជាពេលបូកសរុបការងារនិងធ្វើរបាយការណ៍ ឡើងអាននៅពេលធ្វើមីទីងក្នុងឃុំ ឬស្រុក ហើយថែមទាំងមិនអនុញ្ញាតឲ្យ ឆា យកប្រពន្ធទៀត ព្រោះទុកឲ្យនៅជួយមើលកិច្ចការរបស់គាត់ ។ ប៉ុន្តែទោះបី ឆា ទទួលបានការស្រឡាញ់រាប់អានពីប្រធានកង



សកម្មភាពជនជាតិចាមមុស្លីមបំពេញពាក្យបណ្តឹង

យ៉ាងណាក្តី ក៏គាត់មិនមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគដែរ រហូតធ្វើឲ្យគាត់បាក់កម្លាំងនិងកើតជំងឺនោមឈាម ។ ដោយពុំមានថ្នាំពេទ្យសម្រាប់ព្យាបាល ឆា បានដើរដកគល់ជ្មី ម្លាស់ ស្លឹកស្បូវ ឬស្សីព្រៃយកមកដុំដាំទឹកផឹករហូតបានជាសះស្បើយ ។ នៅចុងឆ្នាំ១៩៧៨ ប្រធានកងបានផ្លាស់ឲ្យទៅកាប់ឬស្សីនៅព្រៃកសិនតាមបណ្តោយព្រំដែនវៀតណាមដែលកងទ័ពខ្មែរក្រហមវាយយកបាន ។ ឆា យកឬស្សីដែលកាប់បានមកសង់ជារោងសម្រាប់កងចល័តស្នាក់នៅធ្វើស្រែ ។ ចំណែករបបអាហារ ឆា ទទួលបានបាយ៣ពេលក្នុងមួយថ្ងៃ ថែមទាំងមានចែករបបខោអាវឲ្យស្លៀកពាក់ទៀតផង ។ ឆា ធ្វើការនៅព្រៃកសិនរហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលដល់ ទើប ឆា ត្រឡប់មករស់នៅស្រុកកំណើតវិញ ។

នៅក្នុងរបបខ្មែរក្រហម ឆា បាត់បងប្អូន៣នាក់ ។ ម្នាក់ខ្មែរក្រហមយកទៅសម្លាប់និង២នាក់ទៀតបញ្ជូនទៅធ្វើការនៅខេត្តបាត់ដំបងដែលបាត់ដំណឹងរហូតមកដល់សព្វថ្ងៃនេះ ។ **ឆា សីនឌី**

# ដំណឹងសួររកក្រុមគ្រួសារ

ខ្ញុំបាទ អ៊ុង ហៃសាយ អាយុ៦០ឆ្នាំ សព្វថ្ងៃរស់នៅប្រទេសបារាំង ។ សូមសួររកឈ្មោះ ÷ ១) គៀង យុលៀន ត្រូវជាម្តាយ ២) អ៊ុង ហៃស៊ី (បងប្រុស) ៣) អ៊ុង ហៃស៊ុ (ប្អូនប្រុស) ៤) អ៊ុង រតនធីតា (ប្អូនស្រី ៥) ចិត្ត ត្រូវជាក្មួយ ។ មុនឆ្នាំ១៩៧៥ អ្នកទាំងអស់រស់នៅផ្ទះមុំផ្លូវអាចារ្យស្វា (បច្ចុប្បន្នផ្លូវយូហ្គោស្លាវី) បើកហាងលក់ម៉ាស៊ីនបូមទឹក នៅមុំហាងថៃសានជិតរោងកុនលុច្សនិងជាម្ចាស់រោងកុនបូកគោ ។ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ម្តាយ គៀង (យុលៀន) ត្រូវខ្មែរក្រហមជម្លៀសទៅភាគខាងលិចទីក្រុងភ្នំពេញជាមួយជនួងរបស់គាត់ឈ្មោះ អ៊ឹង ហុងសាត ។ ប៉ុន្តែតាមរយៈបងប្អូនជីដូនដែលធ្លាប់បានជួបបាននិយាយថា បានឃើញគាត់ជម្លៀសទៅខាងនៅកៀនស្វាយ ។ នៅខែកុម្ភៈ ឆ្នាំ២០០៧ ខ្ញុំបាទបានយករូបថតម្តាយទៅសាកសួរអ្នករស់នៅមុំវត្តព្រៃសណ្តែក (កំពង់ថ្ម) ខេត្តបាត់ដំបងប្រាប់ថា ធ្លាប់ឃើញ អ៊ឹង ហុងសាត ប៉ុន្តែមិនបានឃើញម្តាយ គៀង យុលៀន ទេ ។ ថ្មីៗនេះខ្ញុំធ្លាប់បានផ្សព្វផ្សាយតាមរយៈទូរទស្សន៍ជាតិកម្ពុជានិងទៅរកឈ្មោះទាំងអស់នេះនៅមន្ទីរទួលស្លែង ប៉ុន្តែមិនបានទទួលដំណឹងអ្វីទាំងអស់ ។

ដូច្នេះប្រសិនបើបងប្អូនណាបានស្គាល់ភិនភាគបុគ្គលឈ្មោះដូចបានរៀបរាប់ខាងលើនេះ សូមមេត្តាជួយផ្តល់ព័ត៌មានមកអាសយដ្ឋានផ្ទះលេខ៩៧៨ ផ្លូវ៧០ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥) ១៦ ៦៤២ ៦០៩ ឬ (៨៥៥) ១៦ ៦០០ ៨៨៦ ។ សូមអរគុណ ។

**លិខិតពីមិត្តអ្នកអាន**

ព្រះវិហារ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៧

ជម្រាបជូនលោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា

លោកប្រធាន ខ្ញុំតែងតែអានទស្សនាវដ្តីស្វែងរកការពិតរបស់លោក និងស្តាប់វិទ្យុអំពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ដោយយល់ឃើញទស្សនៈនេះល្អនិងត្រឹមត្រូវសម្រាប់ជាគតិអប់រំវិទ្យាសាស្ត្រពិតនិងប្រកបដោយឧត្តមប្រយោជន៍សម្រាប់ជាតិមាតុភូមិរបស់យើង ។ តាមអំណះអំណាងដែលផ្សាយកន្លងមក ខ្ញុំមានសំណួរមួយចង់សួរលោកប្រធានថាៈ «លោកស្រី រ៉ូឡង់ពេជ អតីតប្រពន្ធរបស់ គង់ ស៊ីគឿន ដែលបានធ្វើការនៅការិយាល័យការបរទេសជិនាន់របបប៉ុលពត ឬកម្ពុជាប្រជាធិបតេយ្យ តើអាចជាសាក្សីបំភ្លឺបញ្ជាក់ការពិតនៅរបបខ្មែរក្រហមបានទេ?» បើតាមទស្សនៈរបស់ខ្ញុំឃើញថា លោកស្រី រ៉ូឡង់ពេជ ជាជនជាតិបារាំង ហើយមានតែគាត់ម្នាក់គត់ដែលអាចបញ្ជាក់បានថា គាត់ជាមនុស្សម្នាក់បានស្គាល់កិច្ចការគ្រប់គ្រងការបរទេសរបស់លោក អៀង សារី តាំងពីឆ្នាំ១៩៧៥ដល់ថ្ងៃវៀតណាមចូលកាន់កាប់មាតុភូមិយើង ។ម្យ៉ាងទៀត «តើមានជនបរទេសប៉ុន្មាននាក់ចូលមកធ្វើសាក្សីក្នុងអង្គជំនុំជម្រះក្តីនេះ?» ក្នុងអង្គជំនុំជម្រះក៏មានជនបរទេសជាសហចៅក្រម សហព្រះរាជអាជ្ញា និងមេធាវីផង «ជនបរទេសតើអាចធ្វើជាសាក្សីបានឬទេ?» សូមលោកប្រធានមេត្តាជួយបំភ្លឺឲ្យខ្ញុំបានយល់ផង ឬសូមលោកប្រធានមេត្តាផ្តល់សំណួរនេះទៅសាលាក្តីខ្មែរក្រហមជួយបំភ្លឺ ប្រសិនជាអាចធ្វើទៅបាន ។

សូមលោកប្រធានទទួលនូវក្តីគោរពរាប់អានដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ ។

យឹម ណារិន



អៀង ធីរិទ្ធ
ថតដោយ ឆាំង យុ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 95, November 2007 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.